# ព្រឹទ្ធសភា

# SENATE MAGAZINE

## ទស្សនាវដ្ដីខែកក្កដា

នីតិកាលទី ៥







លេខ ២៩៧ ឆ្នាំទី២៥ ព.ស.២៥៦៩ គ.ស.២០២៥

Issue 297 Volume 25 BC 2569 BE 2025

# មាតិកា







## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា ( ១-៤៨ )


- សម្តេចតេជោ **ហ៊ុន សែន** ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាដើម្បីពិនិត្យសំណើរបស់រដ្ឋសភា ..... ១
- សម្តេចតេជោ **ហ៊ុន សែន** ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៤..... ២
- ព្រឹទ្ធសភាឯកភាពលើសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ..... ៣
- សម្តេចតេជោ **ហ៊ុន សែន** ទទួលយកការកិច្ចជាអគ្គសុភាជាន់ខ្ពស់ សម្រាប់កងកម្លាំងប្រដាប់អាវុធ ..... ៦
- សម្តេចតេជោ **ហ៊ុន សែន** អញ្ជើញជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ក្នុងខេត្តឧត្តរមានជ័យ ..... ៧
- កម្ពុជាមិនទាន់ត្រូវការប្រទេសទី៣ ក្នុងការជួយដោះស្រាយបញ្ហាព្រំដែនកម្ពុជា-ថៃ ..... ៨
- ទីម័រឡេស្តេអរគុណកម្ពុជាក្នុងការជួយជ្រោមជ្រែងទីម័រឡេស្តេ ចូលជាសមាជិកអាស៊ាន ..... ១០
- សម្តេចតេជោ **ហ៊ុន សែន** ទទួលជួបសវនាការជាមួយឯកឧត្តមប្រធានសភាអារ៉ាប៊ីសាអូឌីត ..... ១២
- សម្តេចតេជោ **ហ៊ុន សែន** ទទួលជួបសម្តែងការគួរសមរបស់ឯកឧត្តមនាយករដ្ឋមន្ត្រីសិង្ហបុរី ..... ១៤
- អនុរដ្ឋមន្ត្រីការបរទេសឥណ្ឌា កោតសរសើរសម្តេចតេជោជាមេដឹកនាំដ៏កម្រនៅលើពិភពលោកដែលមានចក្ខុវិស័យវែងឆ្ងាយ ..... ១៦
- សម្តេចតេជោ **ហ៊ុន សែន** បន្តស្នើបារាំងផ្តល់ឯកសារពាក់ព័ន្ធនឹងព្រំដែនកម្ពុជា-ថៃ ដើម្បីដោះស្រាយបញ្ហាដោយសន្តិវិធី ..... ១៨
- សម្តេចតេជោ **ហ៊ុន សែន** អនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតឆែក ចូលជួបសម្តែងការគួរសមនិងជម្រាបលា..... ២០
- សម្តេចតេជោ **ហ៊ុន សែន** អនុញ្ញាតឱ្យឯកឧត្តម PARK Jung-Wook ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េ ចូលជួបសម្តែងការគួរសមនិងជម្រាបលា ..... ២២
- សម្តេចតេជោ **ហ៊ុន សែន** តែងតាំងឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត Dato Sri Prof. Dr. Tahir ជាទីប្រឹក្សា ដើម្បីរួមចំណែកកសាងអភិវឌ្ឍកម្ពុជា និងពង្រឹងទំនាក់ទំនងកម្ពុជា-ឥណ្ឌូណេស៊ី..... ២៤
- សម្តេចតេជោ **ហ៊ុន សែន** ចាត់ទុកដំណើរទស្សនកិច្ចរបស់ឯកឧត្តម Wang Zhimin ជាការបង្ហាញនូវទំនាក់ទំនងមិត្តភាព និងការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន គ្រប់ជុំរដូវកាល ក្នុងយុគសម័យថ្មី..... ២៦
- សម្តេចតេជោ **ហ៊ុន សែន** ចង្អុលបង្ហាញឱ្យប្រទេសទីម័រឡេស្តេនិងកម្ពុជា បំពេញសក្តានុពលទៅវិញទៅមក ..... ២៨
- អគ្គលេខាធិការអន្តរសភាអាស៊ាន៖ ប្រវត្តិសាស្ត្រនិងការតស៊ូរបស់**សម្តេចតេជោ** ជាមេរៀនសម្រាប់កសាងសន្តិភាព និងសុខដុមរមនាសម្រាប់អាស៊ាន..... ៣០
- សម្តេចតេជោ **ហ៊ុន សែន៖** សាលានាយទាហាន ពលទាហាន នៅតាមបណ្តាភូមិភាគនានា ត្រូវរៀបចំក្នុងកាលៈទេសៈដ៏សមស្រប ដើម្បីអនុវត្តកាតព្វកិច្ចយោធានៅឆ្នាំ២០២៦..... ៣២
- កម្ពុជាមិនមានការទាត់ចោល ឬលុបចោលក្រុមហ៊ុនដែលចូលមកដំណើរការនៅកម្ពុជាមិនថាតូច ឬធំនោះទេ ដើម្បីបង្កជំនឿទុកចិត្តដល់វិនិយោគិននានា..... ៣៤
- សម្តេចតេជោ **ហ៊ុន សែន** ផ្តល់អនុសាសន៍ដល់ក្រុមហ៊ុននៃប្រទេសកាតា ពិនិត្យលទ្ធភាពវិនិយោគលើការកែច្នៃស្បៀង និងវត្ថុធាតុដើមកសិកម្មនៅកម្ពុជា ..... ៣៦
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុញ្ញាតឱ្យគណៈប្រតិភូមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ ..... ៣៨
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុញ្ញាតឱ្យគណៈប្រតិភូសភាតួកគីយេប្រចាំអន្តរសភាអាស៊ាន ចូលជួបសម្តែងការគួរសម..... ៤០
- ឯកឧត្តម **អ៊ុច បូររិទ្ធ** ទទួលជួបពិភាក្សាការងារជាមួយលោកស្រីការធារីស្តីទីនៃស្ថានទូតសហរដ្ឋអាម៉េរិកប្រចាំកម្ពុជា..... ៤១
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញធ្វើបទអន្តរាគមន៍ក្រោមប្រធានបទ៖ «ហ្វ្រង់កូហ្វូនី ជាយុថ្កានៅក្នុងពិភពលោកមួយដែលកំពុងមានវិបត្តិ» នៅសភាប្រើភាសាបារាំង..... ៤៣
- សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ..... ៤៤


## សកម្មភាពគណៈកម្មការនានារបស់ព្រឹទ្ធសភា ( ៤៩-៨០ )


- គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តកំពង់ស្ពឺ ខេត្តកោះកុង និងមន្ទីរជំនាញពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់ខ្លួន ..... ៤៩
- គណៈកម្មការទី១០ព្រឹទ្ធសភា ឈ្វេងយល់អំពីការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួន នៅខេត្តស្ទឹងត្រែង ព្រះវិហារ និងខេត្តឧត្តរមានជ័យ ..... ៥១
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ សំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ និងអាជ្ញាធរស្រុកស្រីស្នំ..... ៥៣
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ សំណេះសំណាលជាមួយអាជ្ញាធរស្រុកគិរីវង់ និងស្រុកទ្រាំង ខេត្តតាកែវ..... ៥៥
- ក្រុមសមាជិកព្រឹទ្ធសភា សំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀន ក្នុងភូមិភាគទី៧..... ៥៧
- ក្រុមសមាជិកព្រឹទ្ធសភា ចែកអំណោយជូនប្រជាពលរដ្ឋ នៅឃុំកំពង់ស្វាយ និងឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ..... ៥៩
- កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា ..... ៦១
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨..... ៦៦
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ..... ៧៦
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស ..... ៨០
- ការទទួលពាក្យបណ្តឹង ..... ៨០


## សកម្មភាពអគ្គលេខាធិការដ្ឋាន ( ៨១-៨៤ )


- ឯកឧត្តម ឡាយ សំកុល ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមិថុនា និងកំណត់ទិសដៅការងារខែកក្កដា ឆ្នាំ២០២៥..... ៨១
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ..... ៨៣



**អ្នកគ្រប់គ្រងទូទៅ**

ឯកឧត្តម ឡាយ សំកុល

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**

ឯកឧត្តម ខេង សិទ្ធិគុណ

ឯកឧត្តម ជាម សុផលមករា

ឯកឧត្តម ជួន ណា

លោក ជួន សុខជី

លោក ទេព មករា

លោក កុក វ៉េ

លោក សុង សុខភាត្ត

**អ្នកគ្រប់គ្រងផ្ទាល់**

លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**

ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**

លោក ជុំ ច័ន្ទរតនា

លោក ធុន គីមជី

លោកស្រី សុខ សុជាតា


**ក្របមុខ**

*- សម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយនាយទាហាន ពលទាហាន ក្នុងអង្គភាពអន្តរាគមន៍ទ័លជ៥ ទិស១ ខេត្តព្រះវិហារ។*

*- ឯកឧត្តមបណ្ឌិត Abdullah Mohammed Ibrahm Al-Sheikh ប្រធានសភា នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត និងសម្តេចតេជោ ហ៊ុន សែន។*

*- លោកជំទាវ Maria Fernanda Lay ប្រធានរដ្ឋសភា នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ និងសម្តេចតេជោ ហ៊ុន សែន។*

# សម្តេចតេជោ ហ៊ុន សែន ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសំណើរបស់រដ្ឋសភា




*សម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា*

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភានីតិកាលទី៥ បានរៀបចំកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នារសៀលថ្ងៃសុក្រ ទី១១ ខែកក្កដា ឆ្នាំ២០២៥ នៅវិមានព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន២ រួមមាន៖

**១-ពិនិត្យសំណើរបស់រដ្ឋសភា សុំពិនិត្យហើយឱ្យយោបល់លើសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។**

**២-ផ្សេងៗ ។**

ឆ្លងតាមការពិនិត្យនិងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានសម្រេចបញ្ជូនសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទៅគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃព្រឹទ្ធសភា ដើម្បីពិនិត្យសិក្សានិងនាំយោបល់របស់គណៈកម្មការ មកជម្រាបជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងអង្គប្រជុំព្រឹទ្ធសភា៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

# សម្តេចតេជោ ហ៊ុន សែន ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៤



*សម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា*

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភានីតិកាលទី៥ នៅព្រឹកថ្ងៃចន្ទ ទី១៤ ខែកក្កដា ឆ្នាំ២០២៥ វេលាម៉ោង ៨:៣០នាទីព្រឹក បានរៀបចំកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៤ រួមមាន៖

**១-ពិនិត្យនិងសម្រេចលើសំណើរបស់គណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃព្រឹទ្ធសភា សុំដាក់សេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទៅក្នុងរបៀបវារៈសម័យប្រជុំ ព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។**

**២-ពិនិត្យនិងសម្រេចលើសំណើរបស់សមាជិកព្រឹទ្ធសភា ស្នើសុំកោះប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។**

**៣-កំណត់កាលបរិច្ឆេទ របៀបវារៈ និងសមាសភាពលេខាធិការសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥។**

**៤-ផ្សេងៗ៕**

ឆ្លងតាមការពិនិត្យនិងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានកំណត់យកថ្ងៃចន្ទ ទី១៤ ខែកក្កដា ឆ្នាំ២០២៥ វេលាម៉ោង៩:៣០នាទីព្រឹក នៅវិមានព្រឹទ្ធសភា ដើម្បីបើកសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ដើម្បីពិនិត្យហើយឱ្យយោបល់លើសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន


*ទិដ្ឋភាពក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

# ព្រឹទ្ធសភាឯកភាពលើសេចក្ដីស្នើច្បាប់ធម្មនុញ្ញស្ដីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា




*ឯកឧត្តម អ៊ុច បូរិទ្ធ* *សម្ដេចតេជោ ហ៊ុន សែន* *ឯកឧត្តមបណ្ឌិត ជន់ វឌ្ឍនា*

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ នាព្រឹកថ្ងៃចន្ទ ទី១៤ ខែកក្កដា ឆ្នាំ២០២៥ ដោយមានវត្តមានសមាជិកព្រឹទ្ធសភាចូលរួមចំនួន៦០រូប។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈតែមួយ គឺ ពិនិត្យហើយឱ្យយោបល់លើសេចក្ដីស្នើច្បាប់ធម្មនុញ្ញស្ដីពីវិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។



*សម្ដេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា*

សេចក្ដីស្នើច្បាប់ធម្មនុញ្ញនេះ ត្រូវបានលោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃព្រឹទ្ធសភា អញ្ជើញឡើងរាយការណ៍ជូនអង្គប្រជុំអំពីលទ្ធផលនៃការពិនិត្យសិក្សាសេចក្ដីស្នើច្បាប់ថា រៀបចំឡើងក្នុងគោលបំណង ដើម្បីលើកកម្ពស់ឧត្ដមគតិជាតិ បន្សុទ្ធមនសិការស្មារតីស្នេហាជាតិ និងរក្សាគោលជំហរស្មោះត្រង់ឥតងាករេរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ចំពោះជាតិមាតុភូមិនិងប្រជាជនកម្ពុជានៅគ្រប់កាលៈទេសៈទាំងអស់ ជាពិសេសការតម្កល់ផលប្រយោជន៍ជាតិជាធំ ស្របតាមមាត្រា៤៩ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងថា «ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។ ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ ហើយមិនត្រូវធ្វើសកម្មភាពណាមួយទោះដោយផ្ទាល់ក្ដី ឬដោយប្រយោលក្ដី នាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជានិងប្រជាពលរដ្ឋខ្មែរឡើយ។ ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិនិងការពារមាតុភូមិ។ កាតព្វកិច្ចការពារ

មាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់»។

**លោកជំទាវបណ្ឌិត** បានបញ្ជាក់ថា សេចក្តីស្នើច្បាប់ធម្មនុញ្ញនេះ ក៏ជាឧបករណ៍គតិយុត្តិដ៏សំខាន់ ដើម្បីធានានិងការពារសន្តិភាព ស្ថិរភាព អធិបតេយ្យជាតិ ទប់ស្កាត់ប្រឆាំងនឹងការជ្រៀតជ្រែកពីខាងក្រៅចូលមកក្នុងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ជាពិសេសការប្រឆាំងនឹងអំពើក្បត់ជាតិ និងអំពើគប់គិតជាមួយបរទេស ដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខជាតិនិងឧត្តមប្រយោជន៍ជាតិ។ ការធ្វើវិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានេះ បានបង្ហាញឱ្យឃើញអំពីភាពរឹងមាំនៃក្របខ័ណ្ឌច្បាប់ក្នុងការពង្រឹងកិច្ចការពារជាតិ ស្របតាមស្តង់ដានិងនិយាមអន្តរជាតិ។



*លោកជំទាវបណ្ឌិត ចាន់ សុទ្ធាវី ឡើងអានរបាយការណ៍*

**លោកជំទាវបណ្ឌិត** បានបញ្ជាក់បន្ថែមថា នាពេលថ្មីៗនេះ ស្ថិតនៅក្នុងស្ថានភាពដែលប្រទេសជាតិកំពុងតែប្រឈមនឹងការឈ្លានពានទឹកដី ហើយនៅពេលដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងខិតខំប្រឹងប្រែងទប់ស្កាត់ការគំរាមកំហែងដ៏ស្មុគស្មាញពីបរទេស ដើម្បីរក្សាការពារអធិបតេយ្យជាតិ បូរណភាពទឹកដី សន្តិភាព ស្ថិរភាព និងសុវត្ថិភាពជូនប្រជាពលរដ្ឋ បែរជាជនជ្រុលនិយមមួយក្តាប់តូច គប់គិតជាមួយបរទេស ព្យាយាមបិទបាំងអំពើឈ្លានពានរបស់បរទេស បកស្រាយព្រឹត្តិការណ៍ខុសស្រឡះពីការពិតនិងធ្វើសកម្មភាពប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍ជាតិនិងប្រជាពលរដ្ឋ ដែលនេះឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងជាក់ស្តែងពីភាពគ្មានទំនួលខុសត្រូវចំពោះជាតិនិងបំផ្លាញផលប្រយោជន៍ជាតិខ្លួនឯង។

**លោកជំទាវបណ្ឌិត** បានលើកឡើងថា ការរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់ការដកសញ្ជាតិខ្មែរនេះ ក៏មិនមែនជារឿងចម្លែក ឬជារឿងថ្មី ដែលទើបកើតមានលើកទី១នៅក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជានោះទេ។ ផ្អែកតាមការសិក្សាស្រាវជ្រាវកាលពីសម័យមុន កម្ពុជាក៏មានច្បាប់កំណត់អំពីការដកសញ្ជាតិខ្មែរដែរ ដូចជា ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ដែលត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់និងមានច្បាប់ស្តីពី ការបាត់បង់សញ្ជាតិខ្មែរ ដែលត្រូវបានប្រកាសឱ្យប្រើ តាមព្រះរាជក្រមលេខ ៣៧៧/ ៦៨-ប.រ. ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៦៨។ មិនតែប៉ុណ្ណោះ នៅបណ្តាប្រទេសជាច្រើន ដូចជា បារាំង, អាម៉េរិក




*ទិដ្ឋភាពក្នុងសម័យប្រជុំព្រឹទ្ធសភាវិសាមញ្ញ នីតិកាលទី៥*

អង់គ្លេស, អាល្លឺម៉ង់, អូស្ត្រាលី, អ៊ីតាលី, បែលហ្ស៊ិក, ឥណ្ឌា, សាធារណរដ្ឋកូរ៉េ និងសិង្ហបុរី ជាដើម សុទ្ធតែមានច្បាប់កំណត់អំពីការដកសញ្ជាតិពីពលរដ្ឋរបស់ខ្លួន ជាពិសេសក្នុងករណីប្រព្រឹត្តអំពើដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់ជាតិ ឬអំពើធ្វើឱ្យប៉ះពាល់ដល់វិស័យសន្តិសុខជាតិ។



*ឯកឧត្តម អង្គ វង្ស វឌ្ឍានា អញ្ជើញការពារសេចក្តីស្នើច្បាប់*



*ឯកឧត្តម កើត រិទ្ធ អញ្ជើញការពារសេចក្តីស្នើច្បាប់*

បន្ទាប់ពីសមាជិកព្រឹទ្ធសភាចំនួន៥រូប ឡើងមានមតិយោបល់និងឆ្លើយបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា ដោយឯកឧត្តម **អង្គ វង្ស វឌ្ឍានា** តំណាងក្រុមតំណាងរាស្ត្រហត្ថលេខីនិងឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រួចមក អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្តីស្នើច្បាប់ទាំងមូល ដោយឥតកែប្រែចំនួន ៥៨សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

សូមជម្រាបថា សេចក្តីស្នើច្បាប់ធម្មនុញ្ញនេះ រៀបចំឡើងមាន ២មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមលើកដំបូងចំនួន១២៥សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៧៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*ទិដ្ឋភាពសមាជិក សមាជិកាព្រឹទ្ធសភាលើកដៃអនុម័តលើសេចក្តីស្នើច្បាប់*

# សម្តេចតេជោ ហ៊ុន សែន ទទួលយកភារកិច្ចជាអគ្គភស្តុភារជាន់ខ្ពស់ សម្រាប់កងកម្លាំងប្រដាប់អាវុធ



*សម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា*

សម្តេចអគ្គមហាសេនាបតីតេជោ នាយឧត្តមសេនីយ៍ផុតលេខផ្កាយមាសប្រាំ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បានយល់ព្រមទទួលយកតាមសំណើរបស់មេបញ្ជាការទាំងឡាយនូវភារកិច្ចជាអគ្គភស្តុភារជាន់ខ្ពស់ សម្រាប់កងកម្លាំងប្រដាប់អាវុធ ក្នុងឱកាសដែល**សម្តេច** អញ្ជើញប្រជុំជាមួយមេបញ្ជាការកងអង្គភាពចំណុះទិសទី២និងទី៣ នៃទីបញ្ជាការស្រោលទី៣ ក្រុងសំរោង ខេត្តឧត្តរមានជ័យ នាព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥។

ការប្រកាសទទួលយកតាមសំណើរបស់មេបញ្ជាការកងទ័ពទាំងឡាយនូវភារកិច្ចជាអគ្គភស្តុភារជាន់ខ្ពស់ សម្រាប់កងកម្លាំងប្រដាប់អាវុធ គឺជាការបង្ហាញយ៉ាងច្បាស់ អំពីការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់**សម្តេចតេជោ** ក្នុងការជួយគាំទ្រ និងធានាលើការផ្គត់ផ្គង់ដល់កងកម្លាំងប្រដាប់អាវុធ ដែលកំពុងតែប្រឈមមុខជាមួយសត្រូវ។ **សម្តេចតេជោ** បានបញ្ជាក់ថា សូមកងកម្លាំងទាំងឡាយកុំខ្លាចនៅក្នុងការវាយប្រហារជាមួយសត្រូវដែលឈ្លានពានយើង។

សម្តេចតេជោ **ហ៊ុន សែន** ជាអគ្គមេបញ្ជាការកំពូលដែលបានយកចិត្តទុកដាក់ខ្ពស់បំផុតចំពោះយោធានិងជាអគ្គមេបញ្ជាការដែលពោរពេញទៅដោយយុទ្ធសាស្រ្តបង្ក្រាបវាយយកលើសមរភូមិសង្គ្រាម។ សូមបញ្ជាក់ថា កងទ័ពនិងអាវុធយុទ្ធភណ្ឌរបស់កម្ពុជាត្រូវបានចល័តពីបន្ទាយឆ្មោះមកកាន់ខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ត្រៀមបម្រុងជាប្រចាំ ដើម្បីការពារទឹកដីក្នុងករណីមានការឈ្លានពានពីកងទ័ពថៃ នៅទិសខេត្តឧត្តរមានជ័យនិងខេត្តព្រះវិហារ បន្ទាប់ពីទាហានថៃបានចូលមកបាញ់ទាហានកម្ពុជាស្លាប់កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥៕



*ទិដ្ឋភាពក្នុងកិច្ចប្រជុំជាមួយមេបញ្ជាការកងអង្គភាពចំណុះទិសទី២និងទី៣ នៃទីបញ្ជាការស្រោលទី៣ ខេត្តឧត្តរមានជ័យ*

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន

# សម្តេចតេជោ ហ៊ុន សែន អញ្ជើញជួបសំណេះសំណាលជាមួយ សមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ក្នុងខេត្តឧត្តរមានជ័យ




*សម្តេចតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា*

បន្ទាប់ពីជួបប្រជុំជាមួយមេបញ្ជាការអង្គភាពចំណុះទិសទី២និងទិសទី៣ នៃទីបញ្ជាការស្រោលទិសទី៣ នៃក្រុងសំរោង ខេត្តឧត្តរមានជ័យរួចមក នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២៦ ខែមិថុនា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ នាយឧត្តមសេនីយ៍ផុតលេខផ្កាយមាសប្រាំ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញបន្តជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ នៃខេត្តឧត្តរមានជ័យចំនួន២៤៨នាក់។

បន្ទាប់ពីស្តាប់សេចក្តីរាយការណ៍របស់ឯកឧត្តម **មាន ចាន់យ៉ាដា** អភិបាលខេត្តឧត្តរមានជ័យរួចមក សម្តេចតេជោ **ហ៊ុន សែន** បានមានប្រសាសន៍ថា សមាជិកក្រុមប្រឹក្សាទាំងអស់ គឺកើតចេញពីការបោះឆ្នោតរបស់ប្រជាពលរដ្ឋ។ ដូច្នេះត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រជាជន ទើបប្រជាជនបោះឆ្នោតឱ្យបន្តទៀត។ **សម្តេច**បានរំលឹកថា មន្ត្រីគឺជាខ្ញុំបម្រើរបស់ប្រជាជន។

**សម្តេចតេជោ** បានកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ ដែលបានខិតខំបម្រើប្រជាពលរដ្ឋ។ **សម្តេច**បានបញ្ជាក់អំពីបញ្ហាទំនាស់ព្រំដែនកម្ពុជា-ថៃ ជាស្ថានភាពនយោបាយរបស់ប្រទេសជិតខាង គឺប្រទេសថៃបានរុញច្រានឱ្យមានវិវាទជាមួយកម្ពុជា។ **សម្តេចតេជោ** បានណែនាំដល់ក្រុមប្រឹក្សាជំរុញឱ្យប្រជាពលរដ្ឋដាំដុះផលិតផលកសិកម្ម ប្រែក្លាយវិបត្តិទៅជាកាលានុវត្តភាពនិងលើកទឹកចិត្តឱ្យមានការផលិតនិងផ្គត់ផ្គង់នៅក្នុងខេត្ត ឬដល់កងកម្លាំងប្រដាប់អាវុធ។ ប្រទេសយើងកំពុងមានវិវាទជាមួយប្រទេសថៃ ហើយស្ថានការណ៍ពេលនេះ មិនដូចកាលពីឆ្នាំ២០១១នោះទេ។

**សម្តេចតេជោ** បានណែនាំដល់ប្រជាពលរដ្ឋត្រូវជីកលេណដ្ឋាន ដើម្បីការពារខ្លួននិងកុំភ្លេចបង្កបង្កើនផល ទោះបីជាសភាពការណ៍បានកើតឡើងនៅទល់ដែនក៏ដោយ។ បន្ថែមពីនេះ **សម្តេចតេជោ** បានលើកឡើងអំពីគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ដែលក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវតែយកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាព ក្នុងការប្រយុទ្ធ-ប្រឆាំងគ្រឿងញៀន ល្បែងស៊ីសង ដែលជាកង្វល់រួម និងជាកង្វល់ដោយឡែកសម្រាប់គ្រួសារនីមួយៗ។



*សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ នៃខេត្តឧត្តរមានជ័យ ចូលរួមក្នុងពិធីសំណេះសំណាល*

**សម្តេចតេជោ**បានលើកឡើងអំពីការបិទព្រំដែនដោយឯកតោភាគីរបស់កងទ័ពថៃ ដែលប្រៀបដូចជាការបិទខ្ទប់ខ្លួនឯង រួមទាំងព្រំដែនជាមួយភូមា ឡាវ និងម៉ាឡេស៊ី ដែលកំពុងតែមានបញ្ហាដូចគ្នា។ **សម្តេច**បានបន្តថា សម្រាប់កម្ពុជា គឺចង់បានព្រំដែនជាមួយប្រទេសជិតខាង គឺជាព្រំដែនមិត្តភាព សន្តិភាព សហប្រតិបត្តិការ និងការអភិវឌ្ឍន៍រីកចម្រើន៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន

# កម្ពុជាមិនទាន់ត្រូវការប្រទេសទី៣ ក្នុងការជួយដោះស្រាយបញ្ហាព្រំដែនកម្ពុជា-ថៃ





*ឯកឧត្តម Nagashima Akihisa និងសម្តេចតេជោ ហ៊ុន សែន*

ក្នុងឱកាសទទួលជួបសម្តែងការគួរសមរបស់ឯកឧត្តម Nagashima Akihisa សមាជិករដ្ឋសភានិងជាទីប្រឹក្សាពិសេសនាយករដ្ឋមន្ត្រីជប៉ុន នាព្រឹកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៥ នៅវិមានព្រឹទ្ធសភា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានជម្រាបអំពីស្ថានភាពពិតប្រាកដនៃជម្លោះរវាងកម្ពុជា-ថៃ ដែលចាប់ផ្តើមដោយទាហានថៃចូលមកបាញ់សម្លាប់យុទ្ធជនកម្ពុជាក្នុងទឹកដីកម្ពុជា កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ និងការសម្រេចបិទព្រំដែនដោយឯកតោភាគីរបស់ទាហានថៃ ដែលធ្វើឱ្យបញ្ហាព្រំដែនរវាងប្រទេសទាំងពីរមានភាពតានតឹង។

**សម្តេចតេជោ** បានគូសបញ្ជាក់ថា កម្ពុជាមិនទាន់ត្រូវការប្រទេសទី៣ ក្នុងការជួយដោះស្រាយបញ្ហាព្រំដែនកម្ពុជា-ថៃ ទេ។ អ្វីដែលកម្ពុជាត្រូវការ គឺការដោះស្រាយដោយសន្តិវិធីប្រើប្រាស់ច្បាប់អន្តរជាតិ តាមរយៈតុលាការយុត្តិធម៌អន្តរជាតិ (ICJ) ។ **សម្តេច**បានស្នើ**ឯកឧត្តមទីប្រឹក្សាពិសេសនាយករដ្ឋមន្ត្រីជប៉ុន** ជម្រាបប្រាប់**នាយករដ្ឋមន្ត្រីជប៉ុន** បានជ្រាបនិងជំរុញភាគីថៃដោះស្រាយបញ្ហាដោយសន្តិវិធី ដោយឈរលើយន្តការនៃច្បាប់អន្តរជាតិ តាមរយៈតុលាការយុត្តិធម៌អន្តរជាតិ (ICJ)។

នៅក្នុងឱកាសនោះ **សម្តេចតេជោ** បានចាត់ទុកដំណើរទស្សនកិច្ចរបស់**ឯកឧត្តមទីប្រឹក្សាពិសេសនាយករដ្ឋមន្ត្រីជប៉ុន**នៅកម្ពុជា គឺជាផ្នែកមួយនៃការពង្រឹងពង្រីកទំនាក់ទំនងនិងសហប្រតិបត្តិការរវាងកម្ពុជា-ជប៉ុន ឱ្យកាន់តែល្អប្រសើរបន្ថែមទៀត។

**សម្តេចតេជោ** បានបង្ហាញអំពីការពេញចិត្តចំពោះទំនាក់ទំនងរវាងកម្ពុជា-ជប៉ុន ដែលមានការរីកចម្រើនជាបន្តបន្ទាប់ ចាប់តាំងពីជំនាន់ឯកឧត្តម **ស៊ីនហ្សូ អាបេ** រហូតមកដល់ពេលនេះ គឺកម្ពុជានិងជប៉ុន បានឈានដល់កម្រិតដៃគូយុទ្ធសាស្ត្រជាមួយគ្នា។ ទន្ទឹមនឹងនោះ **សម្តេចតេជោ** បានកត់សម្គាល់ទាក់ទងនឹងវិស័យដោះមីននិងបានរំលឹកអំពីការបញ្ជូនកងទ័ពកម្ពុជា ទៅចូលរួមរក្សាសន្តិភាពក្រោមឆត្រអង្គការសហប្រជាជាតិ ដែលក្នុងចំណោមកងទ័ពទាំងអស់នោះ ក៏បានបំពេញបេសកកម្មជួយដោះមីននៅតាមបណ្តាប្រទេសគោលដៅនានា។ **សម្តេច**បានអរគុណជប៉ុន ចំពោះ

ការបណ្តុះបណ្តាលជំនាញដោះមីននិងជួយជ្រោមជ្រែងទាំងបច្ចេកទេសនិងសម្ភារៈដល់កងកម្លាំងរបស់កម្ពុជា។

នៅក្នុងជំនួបនោះ **ឯកឧត្តមទីប្រឹក្សាពិសេសនាយករដ្ឋមន្ត្រីជប៉ុន** បានរំលឹកអំពីសហប្រតិបត្តិការដ៏ល្អរវាងកម្ពុជា និងជប៉ុនកាលពីពេលកន្លងទៅក៏ដូចជាពេលបច្ចុប្បន្ន ដែលនឹងបន្តរីកចម្រើនទៅមុខទៀត។ ឯកឧត្តមបានបញ្ជាក់អំពីទំនាក់ទំនងរវាងប្រទេសទាំងពីរ ជាពិសេសដំណើរទស្សនកិច្ចប្រកបដោយផ្លែផ្ការរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសជប៉ុន កាលពីពេលថ្មីៗនេះ។

ជាមួយគ្នានោះ ឯកឧត្តមបានសម្តែងនូវការអរគុណចំពោះកម្ពុជា ជាពិសេស**សម្តេចតេជោ**ផ្ទាល់ ដែលបានអនុញ្ញាតឱ្យនាវាជើងទឹករបស់ជប៉ុនចូលចតនៅកំពង់ផែរាមកាលពីពេលថ្មីៗនេះ ដែលជាផ្នែកមួយដ៏សំខាន់ ក្នុងការជំរុញទំនាក់ទំនងនិងសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើនថែមទៀត លើវិស័យការពារជាតិ។ ក្រៅពីនោះ ឯកឧត្តមបានលើកឡើងអំពីសហប្រតិបត្តិការជាមួយកម្ពុជា នៅក្នុងវិស័យដោះមីន និងការចូលរួមចំណែករបស់ជប៉ុនក្នុងការជួយដោះមីននៅក្នុងប្រទេសកម្ពុជាកាលពីពេលកន្លងទៅ៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន







*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# ទីម័រឡេស្តេអរគុណកម្ពុជាក្នុងការជួយជ្រោមជ្រែងទីម័រឡេស្តេ ចូលជាសមាជិកអាស៊ាន

ក្នុងឱកាសចូលជួបសម្តែងការគួរសមនិងជម្រាបលាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃអង្គារ ទី១ ខែកក្កដា ឆ្នាំ២០២៥ នៅវិមានព្រឹទ្ធសភា ឯកឧត្តម Emenegildo KupaLopes ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ បានសម្តែងនូវការអរគុណយ៉ាងជ្រាលជ្រៅចំពោះប្រទេសកម្ពុជា ជាពិសេសសម្តេចតេជោ **ហ៊ុន សែន** ដែលបានជួយជ្រោមជ្រែងប្រទេសទីម័រឡេស្តេឱ្យក្លាយជាសមាជិកពេញសិទ្ធិរបស់អាស៊ាន នៅខែតុលា



*ឯកឧត្តម Ermenegildo KupaLopes និងសម្តេចតេជោ ហ៊ុន សែន*

ឆ្នាំ២០២៥ខាងមុខនេះ។ នេះជាគុណបំណាច់ដ៏ធំធេងរបស់**សម្តេចតេជោ** ដែលបានចូលរួមចំណែកដល់ទីម័រឡេស្តេ ហើយឈ្មោះ **សម្តេចតេជោ** នឹងស្ថិតនៅជាប់ជាមួយប្រជាជនទីម័រឡេស្តេគ្រប់កាលៈទេសៈ។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានបង្ហាញនូវក្តីនឹករលឹកអនុស្សាវរីយ៍ជាច្រើន ក្នុងពេលឯកឧត្តមបំពេញបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា អស់រយៈពេល៥ឆ្នាំកន្លងទៅ។ ឯកឧត្តមបានចាត់ទុកប្រទេសកម្ពុជា ជាប្រទេសទី២របស់ឯកឧត្តម។ ថ្វីដ្បិតតែពេលនេះ ឯកឧត្តមបានបញ្ចប់អាណត្តិការទូតនៅកម្ពុជាក៏ដោយ ក៏បេះដូងរបស់ឯកឧត្តមនៅជាប់ជាមួយប្រជាជននិងថ្នាក់ដឹកនាំកម្ពុជា។

ក្នុងជំនួបនោះ **សម្តេចតេជោ** បានមានប្រសាសន៍ថា ក្នុងអាណត្តិបេសកកម្មការទូតរបស់ឯកឧត្តមនៅកម្ពុជា ឯកឧត្តមបានបន្សល់ទុកនូវអនុស្សាវរីយ៍ជាច្រើនជាមួយកម្ពុជា ក្នុងការពូនជ្រំទំនាក់ទំនងរវាងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរ។ **សម្តេច**បានចាត់ទុកឯកឧត្តមជាឯកអគ្គរដ្ឋទូតមួយ ដែលបានរឹតចំណងមិត្តភាពរវាងប្រទេសកម្ពុជានិងប្រទេសទីម័រឡេស្តេ។ ទន្ទឹមគ្នានោះ **សម្តេចតេជោ** បានផ្តាំផ្ញើការសួរសុខទុក្ខជូនចំពោះ**ឯកឧត្តមនាយករដ្ឋមន្ត្រី**និង**ឯកឧត្តមប្រធានាធិបតីទីម័រឡេស្តេ**។ **សម្តេចតេជោ** បានរំលឹកអំពីដំណើរទស្សនកិច្ចរបស់**សម្តេច**ទៅកាន់ប្រទេសទីម័រឡេស្តេ កាលពីពេលកន្លងទៅថ្មីៗ ដែលទទួលបាននូវភាពជោគជ័យនិងត្រូវបានទទួលស្វាគមន៍យ៉ាងរាក់ទាក់ពីសំណាក់**ឯកឧត្តមប្រធានាធិបតីទីម័រឡេស្តេ** ដែលបានបើកឡានដោយផ្ទាល់ជូនដំណើរ**សម្តេច**និងមាន**ឯកឧត្តមនាយករដ្ឋមន្ត្រី**នៅឈរអមពីក្រោយ។ នេះជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយដែលបានកើតឡើងក្នុងទំនាក់ទំនងរវាងកម្ពុជានិងទីម័រឡេស្តេ។ ជាមួយគ្នានោះ **សម្តេចតេជោ**ក៏បានរំលេចផងដែរ អំពីដំណើរជីវិតការងាររបស់**សម្តេច**ក្នុងកិច្ចការអន្តរជាតិនិងមានមោទនភាព ដែលអាចជួយទីម័រឡេស្តេឱ្យចូលជាសមាជិកអង្កេតការណ៍ក្នុងឆ្នាំ២០២២និងចូលជាសមាជិកពេញសិទ្ធិរបស់អាស៊ាននៅខែតុលា ឆ្នាំ២០២៥ ខាងមុខ។

ក្នុងឱកាសនោះផងដែរ **សម្តេចតេជោ** បានប្រាប់**ឯកឧត្តមឯកអគ្គរដ្ឋទូត** អំពីស្ថានភាពជម្លោះព្រំដែនរវាងប្រទេសកម្ពុជានិងប្រទេសថៃ ដែលចាប់ផ្តើមដោយទាហានថៃចូលមកបាញ់សម្លាប់ទាហានកម្ពុជា កាលពីថ្ងៃទី២៨ ខែឧសភា



*ឯកឧត្តម Ermenegildo KupaLopes និងសម្តេចតេជោ ហ៊ុន សែន*

ឆ្នាំ២០២៥ និងការសម្រេចបិទព្រំដែនជាឯកតោភាគីរបស់ទាហានថៃ។ **សម្តេច**បានបញ្ជាក់ថា កម្ពុជាមិនចង់មានសង្គ្រាមជាមួយប្រទេសជិតខាងទេ។ កម្ពុជាចង់ដោះស្រាយបញ្ហាដោយសន្តិវិធីនិងស្របតាមគោលការណ៍ច្បាប់អន្តរជាតិ ប៉ុន្តែប្រសិនបើថៃនៅតែបំពាននិងឈ្លានពានកម្ពុជា កម្ពុជាត្រូវប្រើសិទ្ធិការពារនិងវាយបកត្រឡប់ទៅវិញ។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានអរគុណចំពោះ**សម្តេចតេជោ** ដែលបានពន្យល់អំពីបញ្ហាព្រំដែនកម្ពុជា-ថៃ និងគោលជំហររបស់កម្ពុជា។ ឯកឧត្តមបានកោតសរសើរចំពោះ**សម្តេចតេជោ** ក្នុងការដោះស្រាយបញ្ហាសំខាន់ៗជាច្រើនរបស់កម្ពុជា ដែលជាអ្នកយុទ្ធសាស្ត្រដ៏អស្ចារ្យមួយរូប ដែលឯកឧត្តមបានរៀនសូត្រនិងគោរពជាទីបំផុត។ ឯកឧត្តមសង្ឃឹមថា នាពេលខាងមុខ ប្រទេសទីម័រឡេស្តេនឹងយកប្រទេសកម្ពុជាជាគំរូក្នុងការដោះស្រាយបញ្ហានានា ក៏ដូចជាការអភិវឌ្ឍប្រទេសជាតិឱ្យមានភាពល្អប្រសើរបន្ថែមទៀត៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# សម្តេចតេជោ ហ៊ុន សែន ទទួលជួបសវនាការជាមួយ ឯកឧត្តមប្រធានសភាអារ៉ាប៊ីសាអូឌីត





*ឯកឧត្តមបណ្ឌិត Abdullah Mohammed Ibrahm Al-Sheikh និងសម្តេចតេជោ ហ៊ុន សែន*

នារសៀលថ្ងៃអង្គារ ទី១ ខែកក្កដា ឆ្នាំ២០២៥ នៅវិមានព្រឹទ្ធសភា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបសវនាការជាមួយឯកឧត្តមបណ្ឌិត Abdullah Mohammed Ibrahm Al-Sheikh ប្រធានសភា នៃព្រះរាជាណាចក្រអារ៉ាប៊ីសាអូឌីត ក្នុងឱកាស**ឯកឧត្តមបណ្ឌិត** ដឹកនាំគណៈប្រតិភូអារ៉ាប៊ីសាអូឌីត បំពេញទស្សនកិច្ចផ្លូវការនិងមិត្តភាព នៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងឱកាសនោះ **សម្តេចតេជោ** បានចាត់ទុកដំណើរទស្សនកិច្ចរបស់**ឯកឧត្តមបណ្ឌិត**នៅព្រះរាជាណាចក្រកម្ពុជា គឺជាផ្នែកដ៏សំខាន់ ក្នុងការជំរុញទំនាក់ទំនងនិងសហប្រតិបត្តិការរវាងអង្គការនីតិប្បញ្ញត្តិនិងនីតិប្រតិបត្តិនៃប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរ។

**ឯកឧត្តមបណ្ឌិតប្រធានសភាអារ៉ាប៊ីសាអូឌីត** បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងនិងសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ដែលមានការរីកចម្រើនជាបន្តបន្ទាប់។ **ឯកឧត្តមបណ្ឌិត** ចង់ឃើញការវិវឌ្ឍរីកចម្រើននៃទំនាក់ទំនងរវាងប្រទេសទាំងពីរកាន់តែល្អប្រសើរឡើង តាមរយៈការផ្លាស់ប្តូរដំណើរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរនិងការជំរុញទំនាក់ទំនងនិងសហប្រតិបត្តិការ លើវិស័យសេដ្ឋកិច្ចពាណិជ្ជកម្ម និងការវិនិយោគ។ ឯកឧត្តមបានបង្ហាញអំពីការចាប់អារម្មណ៍លើវិស័យកសិកម្មនិងវិស័យទេសចរណ៍នៅក្នុងប្រទេសកម្ពុជា។ ចំពោះវិស័យទេសចរណ៍ ប្រទេសទាំងពីរពុំទាន់មានជើងហោះហើរត្រង់និងចំនួនក្រុមហ៊ុនទេសចរណ៍ផ្តល់សេវាដឹកនាំអ្នកទេសចរណ៍ពីកម្ពុជា ទៅអារ៉ាប៊ីសាអូឌីតនិងពីអារ៉ាប៊ីសាអូឌីតទៅកម្ពុជា មានចំនួនតិចនៅឡើយ។

ជាការឆ្លើយតប **សម្តេចតេជោ** បានឯកភាពចំពោះការលើកឡើងរបស់**ឯកឧត្តមបណ្ឌិតប្រធានសភាអារ៉ាប៊ីសាអូឌីត**។ **សម្តេច**បានលើកឡើងអំពីសក្តានុពលរបស់ប្រទេសកម្ពុជា ដែលវិនិយោគិនអារ៉ាប៊ីសាអូឌីតគួរតែពិនិត្យសិក្សានិងវិនិយោគក្នុងវិស័យសំខាន់ៗ ជាពិសេសវិស័យកសិកម្ម។ **សម្តេច**បានបញ្ជាក់ថា វិស័យកសិកម្មនៅកម្ពុជា គឺមានសក្តានុពលច្រើនដែលត្រូវការវិនិយោគពីក្រៅប្រទេស ហើយប្រសិនបើអារ៉ាប៊ីសាអូឌីតចាប់អារម្មណ៍គួរតែវិនិយោគលើវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ដូចជាការកែច្នៃផលិតផលកសិកម្មដើម្បីធ្វើការនាំចេញ។ សព្វថ្ងៃ ប្រទេសកម្ពុជាមានសមត្ថភាពផលិតវត្ថុធាតុដើម ប៉ុន្តែកម្ពុជានៅមានកង្វះខាតក្នុងការកែច្នៃដើម្បីនាំចេញ។ តួយ៉ាងដូចជា អង្កររបស់កម្ពុជា





*ទិដ្ឋភាពក្នុងជំនួបសវនាការ*

ដែលទទួលបានការចាប់អារម្មណ៍លើទីផ្សារអន្តរជាតិ ជាអង្ករមិនមានជាតិគីមី និងទទួលបានការផ្តល់តម្លៃ ហើយអាចវាយលុកលើទីផ្សារគ្រប់ទីកន្លែង ប៉ុន្តែចំណុចសំខាន់គឺកម្ពុជានៅខ្វះការកែច្នៃផលិតផលដើម្បីនាំចេញ។

ចំពោះវិស័យទេសចរណ៍វិញ **សម្តេចតេជោ** ចង់ឃើញអារ៉ាប៊ីសាអូឌីតមានជើងហោះហើរត្រង់មកកាន់កម្ពុជា ដើម្បីបង្កើនការផ្លាស់ប្តូររវាងប្រជាជននៃប្រទេសទាំងពីរ ព្រមទាំងប្រជាជននៅតំបន់មជ្ឈិមបូព៌ាដែលអាចធ្វើដំណើរមកកាន់ប្រទេសកម្ពុជាបានផងដែរ។

ក្នុងឱកាសនោះផងដែរ **សម្តេចតេជោ** បានចែករំលែកអំពីស្ថានភាពនៃជម្លោះព្រំដែនកម្ពុជា-ថៃ ដែលចាប់ផ្តើមដោយទាហានថៃចូលមកបាញ់សម្លាប់ទាហានកម្ពុជាក្នុងទឹកដីកម្ពុជា កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥កន្លងទៅ និងការសម្រេចបិទព្រំដែនជាឯកតោភាគីនិងការគំរាមកំហែងផ្សេងៗ ពីសំណាក់ភាគីថៃ។

**ឯកឧត្តមបណ្ឌិតប្រធានរដ្ឋសភាអារ៉ាប៊ីសាអូឌីត** បានអរគុណ**សម្តេចតេជោ**ដែលបានប្រាប់អំពីមូលហេតុជម្លោះព្រំដែនកម្ពុជា-ថៃ។ **ឯកឧត្តមបណ្ឌិត**សង្ឃឹមថា ទំនាក់ទំនងនិងសហប្រតិបត្តិការរវាងប្រទេសទាំងពីរ នឹងកាន់តែរីកចម្រើនបន្ថែមទៀតនាពេលអនាគត៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន

# សម្តេចតេជោ ហ៊ុន សែន ទទួលជួបសម្តែងការគួរសមរបស់ ឯកឧត្តមនាយករដ្ឋមន្ត្រីសិង្ហបុរី



*ឯកឧត្តម ឡរ៉េន វ៉ុង និងសម្តេចតេជោ ហ៊ុន សែន*

នាព្រឹកថ្ងៃអង្គារ ទី២ ខែកក្កដា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបសម្តែងការគួរសមរបស់ឯកឧត្តម **ឡរ៉េន វ៉ុង** (Lawrence Wong) នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសិង្ហបុរី នៅវិមានព្រឹទ្ធសភា ក្នុងឱកាសដែលឯកឧត្តម ដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងឱកាសនោះ **សម្តេចតេជោ** បានចាត់ទុកដំណើរទស្សនកិច្ចរបស់**ឯកឧត្តមនាយករដ្ឋមន្ត្រី**នៅព្រះរាជាណាចក្រកម្ពុជា គឺជាការជំរុញបន្ថែមទៀតនូវទំនាក់ទំនងនិងសហប្រតិបត្តិការរវាងកម្ពុជានិងសិង្ហបុរី ឱ្យកាន់តែល្អប្រសើរ ដើម្បីជាគុណប្រយោជន៍សម្រាប់ប្រជាជននិងប្រទេសទាំងពីរ។

**សម្តេចតេជោ** បានលើកឡើងអំពី ទំនាក់ទំនងដ៏ល្អប្រពៃរវាងប្រទេសកម្ពុជានិងប្រទេសសិង្ហបុរី ចាប់តាំងពី ៦០ឆ្នាំមុន ក្រោមព្រះរាជដឹកនាំរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋនិងឯកឧត្តម **លីក្វាន់យូ** (Lee Kuan Yew) នាយករដ្ឋមន្ត្រីដំបូងបង្អស់របស់សិង្ហបុរី ដែលទំនាក់ទំនងដ៏ល្អនេះ ត្រូវបានពង្រឹងពង្រីកជាបន្តបន្ទាប់។

**សម្តេចតេជោ** ក៏បានលើកឡើងផងដែរអំពីការពង្រីកទំនាក់ទំនងនិងសហប្រតិបត្តិការរវាងប្រទេសទាំងពីរបន្ថែមទៀត ជាពិសេសលើវិស័យពាណិជ្ជកម្ម សេដ្ឋកិច្ច និងវិស័យទេសចរណ៍។ **សម្តេច**ចង់ឱ្យមានជើងហោះហើរត្រង់ពីសិង្ហបុរីមកកាន់កម្ពុជាកាន់តែច្រើនថែមទៀត ជាពិសេសនៅពេលដែលកម្ពុជាដាក់ឱ្យដំណើរការអាកាសយានដ្ឋានអន្តរជាតិតេជោ នាពេលឆាប់ៗខាងមុខ។

ក្នុងឱកាសនោះផងដែរ **សម្តេចតេជោ** បានជម្រាបអំពីមូលហេតុពិតនៃស្ថានភាពជម្លោះព្រំដែនកម្ពុជា-ថៃ ដែលចាប់ផ្តើមដោយទាហានថៃចូលមកបាញ់សម្លាប់ទាហានកម្ពុជា ក្នុងទឹកដីកម្ពុជា កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ កន្លងទៅ និងការសម្រេចបិទព្រំដែនជាឯកតោភាគី ព្រមទាំងការគំរាមកំហែងផ្សេងៗពីសំណាក់ភាគីថៃ។





*ឯកឧត្តម ឡូរ៉េន វ៉ុង និងសម្តេចតេជោ ហ៊ុន សែន*

**សម្តេចតេជោ** បានគូសបញ្ជាក់ថា កម្ពុជាមិនចង់មានបញ្ហាជាមួយប្រទេសជិតខាងនោះទេ។ កម្ពុជាចង់ដោះស្រាយបញ្ហាដោយសន្តិវិធីនិងឈរលើច្បាប់អន្តរជាតិ ប៉ុន្តែប្រសិនបើនៅតែបំពាននិងឈ្លានពានកម្ពុជា នោះកម្ពុជានឹងត្រូវប្រើសិទ្ធិការពារខ្លួនវាយបកត្រឡប់ទៅវិញ។

នៅក្នុងជំនួបនោះ **ឯកឧត្តមនាយករដ្ឋមន្ត្រី** បានសម្តែងនូវសេចក្តីរីករាយចំពោះទំនាក់ទំនងនិងសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរ ដែលមានការរីកចម្រើនជាលំដាប់ ជាពិសេសនៅឆ្នាំ២០២៥នេះ គឺជាខួបទី៦០ឆ្នាំ នៃទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ។

**ឯកឧត្តមនាយករដ្ឋមន្ត្រី** បានអរគុណចំពោះ**សម្តេចតេជោ** ដែលបានពន្យល់អំពីបញ្ហាព្រំដែនកម្ពុជា-ថៃ និងគោលជំហរដ៏ត្រឹមត្រូវរបស់កម្ពុជា។ ឯកឧត្តមសង្ឃឹមថា ភាគីទាំងពីរនឹងដោះស្រាយបញ្ហាដោយសន្តិវិធី ដោយឈរលើគោលការណ៍ច្បាប់អន្តរជាតិ៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន





*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# អនុរដ្ឋមន្ត្រីការបរទេសឥណ្ឌា កោតសរសើរសម្តេចតេជោជាមេដឹកនាំដ៏កម្រ នៅលើពិភពលោកដែលមានចក្ខុវិស័យវែងឆ្ងាយ





*ឯកឧត្តម ប៉ាប៊ីត្រា ម៉ាហ្គីរីតា និងសម្តេចតេជោ ហ៊ុន សែន*

ឯកឧត្តម **ប៉ាប៊ីត្រា ម៉ាហ្គីរីតា** (Pabitra Margherita) អនុរដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋឥណ្ឌា បានសម្តែងនូវការកោតសរសើរចំពោះសម្តេចតេជោ **ហ៊ុន សែន** ជាមេដឹកនាំដ៏កម្រនៅលើពិភពលោក ដែលមានចក្ខុវិស័យវែងឆ្ងាយ។ ឯកឧត្តមបានលើកឡើងយ៉ាងដូច្នេះ ក្នុងពេលដែលឯកឧត្តមអញ្ជើញចូលជួបសម្តែងការគួរសម សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃចន្ទ ទី៧ ខែកក្កដា ឆ្នាំ២០២៥ នៅវិមានព្រឹទ្ធសភា ក្នុងឱកាសឯកឧត្តមអញ្ជើញដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ច នៅព្រះរាជាណាចក្រកម្ពុជា។

**ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេស** បានសម្តែងនូវមោទនភាពដែលបានជួបពិភាក្សាជាមួយ**សម្តេចតេជោ** ដែលជាតស្សូរជននយោបាយជាន់ខ្ពស់ ជារដ្ឋបុរសមួយដ៏មានឥទ្ធិពល និងជាតួអង្គដ៏សំខាន់ក្នុងការរុញច្រានទំនាក់ទំនងនិងសហប្រតិបត្តិការរវាងប្រទេសកម្ពុជានិងប្រទេសឥណ្ឌា ឱ្យកាន់តែរីកចម្រើនជាបន្តបន្ទាប់។ ឯកឧត្តមសង្ឃឹមថា ទំនាក់ទំនងរវាងប្រទេសទាំងពីរនឹងកាន់តែរីកចម្រើនឡើងបន្ថែមទៀត។

ឯកឧត្តមបានរំលឹកអំពីតួនាទីដ៏សំខាន់របស់កម្ពុជា ជាពិសេស**សម្តេចតេជោ** ដែលបានជួយសម្របសម្រួលឱ្យឥណ្ឌាក្លាយជាដៃគូសន្ទនាជាមួយអាស៊ានកាលពីឆ្នាំ២០០២។ នេះជាគុណូបការៈរបស់**សម្តេចតេជោ** ដែលបានជួយជ្រោមជ្រែងប្រទេសឥណ្ឌា នៅក្នុងកាលៈទេសៈនោះ។

នៅក្នុងជំនួបនោះ **សម្តេចតេជោ** បានចាត់ទុកដំណើរទស្សនកិច្ចរបស់**ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេសឥណ្ឌា** មកកាន់ព្រះរាជាណាចក្រកម្ពុជា គឺជាការពង្រឹងពង្រីកទំនាក់ទំនងនិងសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ឱ្យកាន់តែមានភាពល្អប្រសើរឡើងថែមទៀត។

**សម្តេចតេជោ** បានថ្លែងអំណរគុណចំពោះប្រទេសឥណ្ឌា ដែលបានជួយជួសជុលប្រាង្គប្រាសាទនានានៅកម្ពុជា ចាប់តាំងពីឆ្នាំ១៩៨៨មក ដែលពេលនោះកម្ពុជាកំពុងស្ថិតក្រោមការហ៊ុមព័ទ្ធសេដ្ឋកិច្ចនិងនយោបាយ។ នៅក្នុងអំឡុងពេលនោះ ប្រទេសឥណ្ឌាបានបញ្ជូនជំនួយគាំទ្រដល់កម្ពុជា ដែលជាផ្នែកមួយដ៏សំខាន់ ក្នុងពេលដែលកម្ពុជាកំពុងតែជួប

បញ្ហាខ្វះស្បៀង។ ទន្ទឹមគ្នានោះ **សម្តេច**ក៏បានលើកឡើងអំពីការជួយរបស់ឥណ្ឌា ក្នុងការបណ្តុះបណ្តាលធនធានមនុស្សរបស់កម្ពុជា ជាពិសេសលើផ្នែកបច្ចេកវិទ្យានិងសុខាភិបាល ដែលបានចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។

**សម្តេចតេជោ** បានជំរុញឱ្យប្រទេសទាំងពីរពង្រីកទំនាក់ទំនងបន្ថែមទៀត លើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគដែលកំពុងនៅមានសក្តានុពល។

ក្នុងឱកាសនោះ **សម្តេចតេជោ** បានជម្រាបអំពីមូលហេតុនិងសាវតារ នៃជម្លោះព្រំដែនកម្ពុជា-ថៃ។ ប្រទេសថៃតែងតែបង្វែរបញ្ហាផ្ទៃក្នុងខ្លួនមកកាន់ព្រំដែនកម្ពុជា ដែលនេះជាទម្លាប់របស់ថៃ។ **សម្តេច**បានគូសបញ្ជាក់ថា **សម្តេច**មិនមែនជាអ្នកនយោបាយអត់គុណធម៌ទេ **សម្តេច**ធ្វើអ្វីៗ ដើម្បីការពារនូវបូរណភាពទឹកដីនិងមិនឱ្យគេជេរប្រមាថចំពោះប្រទេសជាតិនិងប្រជាជន ហើយបញ្ហាដែលកើតឡើងនៅផ្ទៃក្នុងរបស់ប្រទេសថៃដែលបង្វែរមកកាន់កម្ពុជា **សម្តេច**គ្រាន់តែបោះដុំភ្លើងដែលគេបោះមកកាន់កម្ពុជាត្រឡប់ទៅទីក្រុងបាងកកវិញតែប៉ុណ្ណោះ កុំឱ្យវាជះឥទ្ធិពលអវិជ្ជមានមកកាន់កម្ពុជា។ **សម្តេច**បានបន្ថែមថា បញ្ហាព្រំដែននេះ គឺចាប់ផ្តើមពីការគូរផែនទីជាឯកតោភាគីរបស់ថៃ ការចូលមកបាញ់សម្លាប់ទាហានកម្ពុជា កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ និងការសម្រេចបិទព្រំដែនជាឯកតោភាគីរបស់ទាហានថៃ។ កម្ពុជាមិនចង់មានសង្គ្រាមជាមួយប្រទេសជិតខាងទេ កម្ពុជាចង់បានការដោះស្រាយដោយសន្តិវិធី ប្រើប្រាស់ច្បាប់អន្តរជាតិតាមរយៈយន្តការតុលាការយុត្តិធម៌អន្តរជាតិ (ICJ)។

ក្នុងឱកាសនោះផងដែរ **ឯកឧត្តមអនុរដ្ឋមន្ត្រីការបរទេស** បានថ្លែងអំណរគុណ**សម្តេចតេជោ** ដែលបានពន្យល់អំពីស្ថានភាពនៃបញ្ហាព្រំដែនកម្ពុជា-ថៃ ដែលកំពុងកើតមានជាមួយគ្នា។ ជាមួយគ្នានោះ ឯកឧត្តមបានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើនរបស់ប្រទេសកម្ពុជានិងភាពរួសរាយរាក់ទាក់របស់ប្រជាជនកម្ពុជា ក្រោមការដឹកនាំរបស់**សម្តេចតេជោ** និងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# សម្តេចតេជោ ហ៊ុន សែន បន្តស្នើបារាំងផ្តល់ឯកសារពាក់ព័ន្ធនឹងព្រំដែនកម្ពុជា-ថៃ ដើម្បីដោះស្រាយបញ្ហាដោយសន្តិវិធី



*ឯកឧត្តម ហ្សាក់ ប៉េឡេ និងសម្តេចតេជោ ហ៊ុន សែន*

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តស្នើបារាំងផ្តល់ឯកសារពាក់ព័ន្ធនឹងព្រំដែនកម្ពុជា-ថៃ ដូចដែលឯកឧត្តម **អេម៉ានុយអែល ម៉ាក្រុង** ប្រធានាធិបតីបារាំងបានលើកឡើងក្នុងជំនួបជាមួយសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាកាលពីពេលកន្លងទៅ។

**សម្តេចតេជោ** បានលើកឡើងយ៉ាងដូច្នេះ ក្នុងឱកាសដែល**សម្តេច**អនុញ្ញាតឱ្យ ឯកឧត្តម **ហ្សាក់ ប៉េឡេ** (Jacques PELLET) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងជម្រាបលា នៅវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១០ ខែកក្កដា ឆ្នាំ២០២៥។

**សម្តេចតេជោ** បានជម្រាបអំពីស្ថានភាពពិតប្រាកដនិងជាក់ស្តែងនៃបញ្ហាជម្លោះព្រំដែនរវាងកម្ពុជា-ថៃ ដែលចាប់ផ្តើមចេញពីការគូរផែនទីដោយឯកតោភាគីរបស់ថៃ ក្នុងគោលបំណងរំលោភបំពានលើបូរណភាពទឹកដីកម្ពុជា ការសម្លាប់ទាហានរបស់កម្ពុជា ការបិទព្រំដែនដោយឯកតោភាគី និងចំណុចសំខាន់បន្ថែមទៀតនោះគឺ ការប្រមាថ និងការគំរាមមកលើកម្ពុជា ក្នុងការបិទការផ្គត់ផ្គង់អគ្គិសនី អ៊ីនធើណិត និងការគំរាមបិទមិនឱ្យនាំចូលប្រេងនិងឧស្ម័នជាដើម ដែលជាផ្នែកធ្វើឱ្យស្ថានភាពនៃប្រទេសទាំងពីរកាន់តែតានតឹង។ កម្ពុជាចង់បានការដោះស្រាយបញ្ហាដោយសន្តិវិធីតាមរយៈការចរចាដោយទ្វេភាគីនិងយន្តការច្បាប់អន្តរជាតិ ដោយបញ្ជូនទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ (ICJ)។

នៅក្នុងជំនួបនោះ **សម្តេចតេជោ** បានជំរុញឱ្យប្រទេសទាំងពីរពង្រឹងសហប្រតិបត្តិការបន្ថែមទៀតលើវិស័យដែលមានសក្តានុពល រួមមានវិស័យសុខាភិបាល ច្បាប់ និងការបណ្តុះបណ្តាលភាសាបារាំង។ **សម្តេច**បានថ្លែងអំណរគុណប្រទេសបារាំងចំពោះសហប្រតិបត្តិការនិងការជួយគាំទ្រដល់ការគាំពារបេតិកភណ្ឌ ការផ្តល់ពូជដើមកៅស៊ូ និងវត្តមានរបស់ក្រុមហ៊ុនប្រេងឥន្ធនៈនៅកម្ពុជា។





*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

នៅក្នុងឱកាសនោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានអរគុណ**សម្តេចតេជោ** ដែលបានពន្យល់យ៉ាងច្បាស់លាស់អំពីស្ថានភាពនៃបញ្ហាព្រំដែនកម្ពុជា-ថៃ។ ឯកឧត្តមបានបញ្ជាក់ថា បារាំងនឹងត្រៀមខ្លួនជានិច្ចក្នុងការផ្តល់ឯកសារពាក់ព័ន្ធនឹងបញ្ហាព្រំដែនកម្ពុជា-ថៃ ជាពិសេស គឺផែនទី ដើម្បីប្រគល់ជូនឱ្យប្រទេសទាំងពីរដោះស្រាយដោយសន្តិវិធីនិងទៅកាន់តុលាការយុត្តិធម៌អន្តរជាតិ (ICJ)។ បារាំងគាំទ្រក្នុងការដោះស្រាយបញ្ហាដោយសន្តិវិធី តាមរយៈតុលាការយុត្តិធម៌អន្តរជាតិ (ICJ)៕

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានអះអាងអំពីការបន្តជំរុញកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ក្រោមគម្រោងនានាដូចជាកិច្ចសហប្រតិបត្តិការលើវិស័យវិទ្យាសាស្ត្រ ច្បាប់ សេដ្ឋកិច្ច ពាណិជ្ជកម្ម អប់រំ យោធា ទឹកស្អាត បេតិកភណ្ឌ និងកិច្ចសហប្រតិបត្តិការក្រោមក្របខ័ណ្ឌហ្វ្រង់កូហ្វូនី។ ទន្ទឹមនឹងនោះ ឯកឧត្តមបានជម្រាបជូនអំពីការត្រៀមលក្ខណៈផ្តល់នូវការគាំទ្រដល់កម្ពុជា ក្នុងការរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ នៅឆ្នាំ២០២៦ខាងមុខ៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# សម្តេចតេជោ ហ៊ុន សែន អនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតឆែក ចូលជួបសម្តែងការគួរសមនិងជម្រាបលា

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១០ ខែកក្កដា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យ ឯកឧត្តម **ម៉ាទីន វ៉ាវ៉ា** (Martin Vávra) ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឆែក ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងជម្រាបលា បន្ទាប់ពីឯកឧត្តមបញ្ចប់បេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា។



*ឯកឧត្តម ម៉ាទីន វ៉ាវ៉ា និងសម្តេចតេជោ ហ៊ុន សែន*

ក្នុងឱកាសនោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានសម្តែងនូវសេចក្តីរីករាយនិងសាទរចំពោះការរីកចម្រើននៃកិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងឆែកនិងកម្ពុជា ជាពិសេសការចូលរួមចំណែករបស់ឆែកក្នុងការអភិវឌ្ឍវិស័យសង្គមកិច្ចនិងសុខាភិបាលរបស់កម្ពុជា។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ក្នុងការគាំទ្រគ្នាទៅវិញទៅមក ទាំងក្នុងកម្រិតទ្វេភាគីនិងពហុភាគី នៅក្នុងសហភាពអឺរ៉ុបនិងអាស៊ីប៉ាស៊ីហ្វិក។

នៅក្នុងជំនួបនោះ **សម្តេចតេជោ** បានវាយតម្លៃខ្ពស់ចំពោះសកម្មភាពនិងសមិទ្ធផលនានាដែល**ឯកឧត្តមឯកអគ្គរដ្ឋទូត**សម្រេចបានក្នុងអាណត្តិបេសកកម្មការទូតរបស់ឯកឧត្តមនៅកម្ពុជា។

**សម្តេចតេជោ** បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងជាប្រវត្តិសាស្ត្រនៃប្រទេសទាំងពីរ ដែលចាប់ផ្តើមតាំងពីជំនាន់អតីតគណបក្សសាធារណរដ្ឋសង្គមនិយមឆេកូស្លូវ៉ាគី។ ទាំងអស់នេះបានបញ្ជាក់ឱ្យឃើញអំពីការយកចិត្តទុកដាក់របស់ឆែកចំពោះកម្ពុជា។ **សម្តេចតេជោ** បានគូសបញ្ជាក់អំពីសារៈសំខាន់ចំពោះអាហារូបករណ៍របស់ឆែកផ្តល់មកកម្ពុជានិងបានថ្លែងអំណរគុណចំពោះសាធារណរដ្ឋឆែក ដែលគាំទ្រកម្ពុជាគ្រប់ដំណាក់កាលនិងការមិនទទួលស្គាល់របបខ្មែរក្រហមនិងរដ្ឋាភិបាលត្រីភាគី ព្រមទាំងវត្តមាននៃស្ថានទូតឆែកនៅទីក្រុងភ្នំពេញ គឺជានិមិត្តរូបនៃទំនាក់ទំនងដ៏រឹងមាំ នៃប្រទេសទាំងពីរ។

**សម្តេចតេជោ** បានចែករំលែកនូវសភាពការណ៍នៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន នៅមជ្ឈិមបូព៌ានិងសង្គ្រាមពន្ធគយដែលកំពុងតែជះឥទ្ធិពលដល់ពាណិជ្ជកម្មនិងសេដ្ឋកិច្ចសកលនិងនិន្នាការនៃការថមថយនៃតួនាទីរបស់អង្គការអន្តរជាតិ ជាពិសេសអង្គការពាណិជ្ជកម្មពិភពលោក។ **សម្តេចតេជោ** បានសម្តែងនូវសុទិដ្ឋិនិយមចំពោះការពង្រីកទំនាក់ទំនងរវាងសហភាពអឺរ៉ុបនិងសហគមន៍ក្រៅតំបន់ដូចជា អាស៊ាននិងអាហ្វ្រិក។



*ឯកឧត្តម ម៉ាទីន វ៉ារ៉ា និងសម្ដេចតេជោ ហ៊ុន សែន*

ក្នុងឱកាសនោះផងដែរ **សម្ដេចតេជោ** បានជម្រាបអំពី សាវតារនិងមូលហេតុនៃជម្លោះព្រំដែនកម្ពុជា-ថៃ ដែលផ្តើមឡើងដោយការគូរផែនទីជាឯកតោភាគីរបស់ថៃនិងការចូលមកបាញ់សម្លាប់ទាហានកម្ពុជា កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ និងការសម្រេចបិទព្រំដែនជាឯកតោភាគីរបស់ទាហានថៃ និងការគម្រាមកាត់ផ្តាច់អគ្គិសនី Internet ប្រេង ឧស្ម័ន ព្រមទាំងការប្រមាថមកលើកម្ពុជា។ **សម្តេច**បានបញ្ជាក់ថា កម្ពុជាចង់បានសន្តិភាព មិនត្រូវការធ្វើសង្គ្រាមជាមួយប្រទេសណាទេ។ កម្ពុជាត្រូវការដោះស្រាយជម្លោះព្រំដែនដោយសន្តិវិធី តាមរយៈយន្តការទ្វេភាគី និងតាមរយៈតុលាការយុត្តិធម៌អន្តរជាតិ (ICJ)។ **សម្ដេចតេជោ** បានសង្កត់ធ្ងន់ថា កម្ពុជាមិនចង់ធ្វើសង្គ្រាមនោះទេ ប៉ុន្តែកម្ពុជាត្រូវត្រៀមខ្លួនក្នុងការប្រើប្រាស់សិទ្ធិការពារខ្លួននិងសិទ្ធិវាយបក៕

ប្រភព៖ Telegram Channel សម្ដេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្ដែងការគួរសម*

# សម្តេចតេជោ ហ៊ុន សែន អនុញ្ញាតឱ្យឯកឧត្តម PARK Jung-Wook ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េ ចូលជួបសម្តែងការគួរសមនិងជម្រាបលា





*ឯកឧត្តម PARK Jung-Wook និងសម្តេចតេជោ ហ៊ុន សែន*

នាព្រឹកថ្ងៃអង្គារ ទី១៥ ខែកក្កដា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម PARK Jung-Wook ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េ ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងជម្រាបលា នៅវិមានព្រឹទ្ធសភា។

ក្នុងឱកាសនោះ **សម្តេចតេជោ** បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការនានារបស់ឯកឧត្តម PARK Jung-Wook ក្នុងការរួមចំណែកកសាងនិងពង្រឹងទំនាក់ទំនងរវាងប្រទេសទាំងពីរ។

នៅក្នុងឱកាសជំនួបនោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានលើកឡើងថា វាជាកិត្តិយសណាស់ ដែលបានមកបំពេញបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមបានថ្លែងអំណរគុណចំពោះ**សម្តេចតេជោ** រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដែលបានផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងល្អក្នុងការបំពេញការងាររបស់ឯកឧត្តម។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានរំលេចថា ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យរបស់**សម្តេចតេជោ** កម្ពុជាទទួលបានសន្តិភាពនិងបានក្លាយជាដៃគូយ៉ាងជិតស្និទ្ធមួយរបស់សាធារណរដ្ឋកូរ៉េ បន្ទាប់ពីប្រទេសទាំងពីរបានតភ្ជាប់ទំនាក់ទំនងការទូតឡើងវិញនៅឆ្នាំ ១៩៩៧។

**ឯកឧត្តមឯកអគ្គរដ្ឋទូត** បានលើកឡើងអំពីសមិទ្ធផលគួរឱ្យកត់សម្គាល់ ដែលប្រទេសទាំងពីរសម្រេចបាន ដូចជា កំណើនពាណិជ្ជកម្មទ្វេភាគី ការកៀរគរវិនិយោគិនកូរ៉េមកវិនិយោគនៅកម្ពុជា តាមរយៈការរៀបចំវេទិកាវិនិយោគនិងធុរកិច្ច និងកិច្ចពិគ្រោះយោបល់ជាប្រចាំជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហប្រតិបត្តិការលើវិស័យវប្បធម៌ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសហប្រតិបត្តិការនៃការអនុវត្តគម្រោងនានា ក្រោមកម្ចី ODA រួមទាំងគម្រោងសាងសង់ស្ពានមិត្តភាពកម្ពុជា-កូរ៉េ ជាដើម។ វឌ្ឍនភាពទាំងនេះ មិនអាចកើតឡើងទេ ប្រសិនបើគ្មានការរួមចំណែកនិងការគាំទ្រពីភាគីកម្ពុជា។



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសមនិងជម្រាបលា*

**សម្តេចតេជោ** បានសម្តែងនូវក្តីរីករាយចំពោះវឌ្ឍនភាពទាំងឡាយ ដែល**ឯកឧត្តមឯកអគ្គរដ្ឋទូត**បានខិតខំជំរុញនិងបានបញ្ជាក់ថា ទោះបីទំនាក់ទំនងរវាងកម្ពុជា-កូរ៉េ មានស្ថានភាពឡើងចុះ ប៉ុន្តែជាទំនាក់ទំនងមួយយ៉ាងឆាប់រហ័សនិងមានល្បឿនលឿន បន្ទាប់ពីការផ្សារភ្ជាប់ទំនាក់ទំនងការទូតឡើងវិញនៅឆ្នាំ១៩៩៧។ **សម្តេច**បានរំលេចថា កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ មានការកើនឡើងជាបន្តបន្ទាប់ស្ទើរគ្រប់វិស័យ។ ក្នុងនោះ ទំហំពាណិជ្ជកម្មទ្វេភាគី មានការកើនឡើង ចំណែកឯអ្នកវិនិយោគកូរ៉េ ក៏មានការកើនឡើងដែរ។ រីឯជើងហោះហើរកម្ពុជា-កូរ៉េ ក៏នៅតែដំណើរការ ទោះបីជានៅក្នុងអំឡុងពេលមានការរីករាលដាលជំងឺកូវីដ-១៩ និងនៅពេលដែលមានការបិទខ្ទប់ការធ្វើដំណើរតាមច្រកផ្លូវផ្សេងៗក៏ដោយ។

**សម្តេចតេជោ** បានចង្អុលបង្ហាញជាការពិចារណាឱ្យប្រទេសទាំងពីរធ្វើកិច្ចសហប្រតិបត្តិការដែលបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក។ ជាក់ស្តែង កម្ពុជាជាប្រទេសតូច ប៉ុន្តែមានកម្លាំងទិញធំ កម្ពុជាបាននាំចូលទំនិញជាច្រើនពីកូរ៉េ។ ទន្ទឹមគ្នានេះ កំណើនទេសចរកូរ៉េមកទស្សនាកម្ពុជាក៏កើនច្រើនផងដែរ។ **សម្តេច**សង្ឃឹមថា ក្នុងឱកាសគម្រប់ខួប៣០ឆ្នាំនៃការបង្កើតចំណងការទូតកម្ពុជា-កូរ៉េ នៅឆ្នាំ២០២៧ ប្រទេសទាំងពីរនឹងអាចលើកកម្ពស់ទំនាក់ទំនងទៅជា ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ។

ក្នុងឱកាសនោះផងដែរ **សម្តេចតេជោ** បានសម្តែងនូវការអបអរសាទរចំពោះភាពជោគជ័យនៅក្នុងការបោះឆ្នោតជ្រើសរើសប្រធានាធិបតីថ្មីកូរ៉េនិងវិធីសាស្ត្រនៃការគ្រប់គ្រងដោះស្រាយសភាពការណ៍ផ្ទៃក្នុងកូរ៉េ។ **សម្តេចតេជោ** និង**ឯកឧត្តមឯកអគ្គរដ្ឋទូត** ក៏បានផ្លាស់ប្តូរទស្សនៈគ្នាអំពីស្ថានភាពនយោបាយនិងសេដ្ឋកិច្ចសកលផងដែរ៕



*សម្តេចតេជោជូនវត្ថុអនុស្សាវរីយ៍ដល់ឯកឧត្តម PARK Jung-Wook*

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន

# សម្ដេចតេជោ ហ៊ុន សែន តែងតាំងឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត Dato Sri Prof. Dr. Tahir ជាទីប្រឹក្សា ដើម្បីរួមចំណែកកសាងអភិវឌ្ឍកម្ពុជា និងពង្រឹងទំនាក់ទំនងកម្ពុជា-ឥណ្ឌូណេស៊ី




*សម្ដេចតេជោ ហ៊ុន សែន និងឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត Dato Sri Prof. Dr. Tahir*

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានជម្រាបប្រាប់ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត Dato Sri Prof. Dr. Tahir ថា **សម្ដេច**បានសម្រេចក្រាបបង្គំទូលស្នើសុំ ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា តែងតាំង**ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត** ជាទីប្រឹក្សារបស់សម្ដេច ក្នុងនាមជាប្រធានព្រឹទ្ធសភា ដើម្បីរួមចំណែកក្នុងការកសាងអភិវឌ្ឍកម្ពុជា និងការពង្រឹងទំនាក់ទំនងរវាងកម្ពុជានិងឥណ្ឌូណេស៊ី។

**សម្ដេចតេជោ** បានមានប្រសាសន៍យ៉ាងដូច្នេះ ក្នុងឱកាសដែលសម្ដេចអនុញ្ញាតឱ្យឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត Dato Sri Prof. Dr. Tahir សមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់របស់ប្រធានាធិបតីឥណ្ឌូណេស៊ីនិងជាស្ថាបនិកក្រុមហ៊ុន Mayapada Group ចូលជួបសម្ដែងការគួរសម នៅវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃពុធ ទី១៦ ខែកក្កដា ឆ្នាំ២០២៥ ។

នៅក្នុងឱកាសនោះ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត** បានសម្ដែងនូវក្ដីរីករាយ ដែលទទួលបានការតែងតាំងជាទីប្រឹក្សារបស់សម្ដេចតេជោ។ ឯកឧត្តមបានចាត់ទុក **សម្ដេចតេជោ** ជាថ្នាក់ដឹកនាំដ៏ល្បីល្បាញអស្ចារ្យមួយរូប ដែលបានស្ដារកសាងកម្ពុជា រក្សាបាននូវសន្តិភាព ស្ថិរភាពនយោបាយ និងធ្វើឱ្យកម្ពុជាមានកំណើនសេដ្ឋកិច្ចលេចធ្លោជាង២០ឆ្នាំ។ ជាមួយគ្នានេះ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត** បានជម្រាបជូន **សម្ដេចតេជោ** ជ្រាបអំពីគោលបំណងនិងសកម្មភាពការងារនានារបស់ឯកឧត្តម ក្នុងការរួមចំណែកធ្វើឱ្យជីវភាពប្រជាពលរដ្ឋកម្ពុជាមានលក្ខណៈល្អប្រសើរឡើង ដូចដែលឯកឧត្តមបានធ្វើនៅឥណ្ឌូណេស៊ីនិងបណ្ដាប្រទេសមួយចំនួនទៀត។ ឯកឧត្តមបានគូសបញ្ជាក់ថា កិច្ចការមនុស្សធម៌គឺជាកិច្ចការគ្មានព្រំដែនកំណត់។ នៅក្នុងបរិបទនេះ ឯកឧត្តមបានបង្ហាញអំពី បំណងប្រាថ្នាក្នុងការចូលរួមចំណែកនិងវិភាគទាននៅកម្ពុជា ព្រមទាំងបានគោរពស្នើសុំ **សម្ដេចតេជោ** ផ្ដល់អនុសាសន៍និងមគ្គុទ្ទេសក៍ដឹកនាំ។

នៅក្នុងជំនួបនោះ **សម្ដេចតេជោ** បានចង្អុលបង្ហាញអំពី វិស័យដែល**ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត** គួរពិចារណាដើម្បីរួមចំណែកនៅកម្ពុជា ដូចជា ការអភិវឌ្ឍជនបទ និងជាពិសេសការគាំទ្រលើកិច្ចការអតីតយុទ្ធជន រួមមាន ការសាងសង់ផ្ទះនិងអណ្ដូងទឹកជាដើម។ កិច្ចការទាំងអស់នេះ គឺមានលក្ខណៈនិងសកម្មភាពស្របទៅនឹងទិសដៅដែល**ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត** បាននិងកំពុងរួមចំណែក។




*ទិដ្ឋភាពក្នុងជំនួបសម្ដែងការគួរសម*

**សម្ដេចតេជោ** បានរំលឹកអំពីប្រវត្តិនិងការតស៊ូដ៏ជូរចត់របស់**សម្ដេច** ក្នុងនាមជាទាហាន ដែលបានជំរុញឱ្យ**សម្ដេច**ផ្ដោតការយកចិត្តទុកដាក់ខ្ពស់ទៅលើកិច្ចការអតីតយុទ្ធជន។ **សម្ដេច**បានគូសបញ្ជាក់ថា ជាគុណធម៌ មិនមែនប្រើយុទ្ធជនពេលត្រូវការហើយបោះបង់ចោលនោះទេ។ នៅក្នុងន័យនេះ **សម្ដេច**បានស្នើ**ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត** ពិនិត្យលទ្ធភាពរៀបចំអភិវឌ្ឍភូមិអតីតយុទ្ធជនមួយ ដើម្បីរួមចំណែកនៅក្នុងបុព្វហេតុនេះ។

ក្នុងឱកាសនោះផងដែរ **សម្ដេចតេជោ** បានចែករំលែកទស្សនវិស័យរបស់**សម្ដេច** បន្ទាប់ពីការអនុវត្តដោយជោគជ័យនៃនយោបាយឈ្នះ-ឈ្នះ រួមមាន៖១-ការប្រែក្លាយតំបន់អតីតសមរភូមិទៅជាតំបន់អភិវឌ្ឍន៍ ២-ការប្រែក្លាយតំបន់ព្រំដែនជាមួយប្រទេសជិតខាងទៅជាតំបន់ព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះ **សម្ដេច**បានសម្ដែងនូវការសោកស្ដាយចំពោះបញ្ហាដែលកើតឡើងជាមួយប្រទេសជិតខាង ដែលវាពុំគួរកើតឡើងសោះ ដោយសារតែការធ្វើសកម្មភាពឯកតោភាគីរបស់ប្រទេសនោះ តាំងពីការប្រើប្រាស់ផែនទីនិងការបិទច្រកព្រំដែន។ **សម្ដេច**បានសង្កត់ធ្ងន់ថា ប្រទេសទាំងពីរគួរធ្វើសហប្រតិបត្តិការផ្លាស់ប្ដូរពាណិជ្ជកម្មនិងកីឡា ប្រសើរជាងការផ្លាស់ប្ដូរគ្រាប់កាំភ្លើងគ្នា និងការប្រកាន់យកការដោះស្រាយដោយសន្តិវិធី តាមរយៈច្បាប់អន្តរជាតិ តាមយន្តការតុលាការយុត្តិធម៌អន្តរជាតិ ICJ៕

ប្រភព៖ Telegram Channel សម្ដេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្ដែងការគួរសម*

# សម្តេចតេជោ ហ៊ុន សែន ចាត់ទុកដំណើរទស្សនកិច្ចរបស់ឯកឧត្តម Wang Zhimin ជាការបង្ហាញនូវទំនាក់ទំនងមិត្តភាព និងការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន គ្រប់រដូវកាល ក្នុងយុគសម័យថ្មី




*ឯកឧត្តម Wang Zhimin និងសម្តេចតេជោ ហ៊ុន សែន*

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានចាត់ទុកដំណើរទស្សនកិច្ចរបស់ឯកឧត្តម Wang Zhimin និងគណៈប្រតិភូនៅកម្ពុជា ពិតជាបង្ហាញឱ្យឃើញនូវទំនាក់ទំនងមិត្តភាព និងការកសាងរួមគ្នា «សហគមន៍វាសនារួមកម្ពុជា-ចិន គ្រប់រដូវកាល ក្នុងយុគសម័យថ្មី» ព្រមទាំងពង្រឹងឱ្យកាន់តែស្អិតល្មួតនិងស៊ីជម្រៅថែមមួយកម្រិតទៀត។

**សម្តេចតេជោ** បានលើកឡើងយ៉ាងដូច្នេះ ក្នុងឱកាសដែល**សម្តេច**អនុញ្ញាតឱ្យឯកឧត្តម Wang Zhimin សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍និងជាអនុប្រធានគណៈកម្មាធិការកិច្ចការជនជាតិ នៃសភាតំណាងប្រជាជនចិនទូទាំងប្រទេស និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា នៅព្រឹកថ្ងៃពុធ ទី១៦ ខែកក្កដា ឆ្នាំ២០២៥។

**សម្តេចតេជោ** បានគូសបញ្ជាក់ថា ទំនាក់ទំនងនិងសហប្រតិបត្តិការរវាងប្រទេសទាំងពីរ បានដើរដល់ដំណាក់កាលថ្មី ដូចដែលបានគូសបញ្ជាក់នៅក្នុងទស្សនកិច្ចផ្លូវរដ្ឋរបស់ឯកឧត្តម **ស៊ី ជីនពីង** ប្រធានាធិបតី នៃសាធារណរដ្ឋប្រជាមានិតចិន នៅព្រះរាជាណាចក្រកម្ពុជាកាលពីពេលកន្លងទៅ។

នៅក្នុងឱកាសនោះ ឯកឧត្តម Wang Zhimin បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**សម្តេចតេជោ** ដែលបានអនុញ្ញាតឱ្យឯកឧត្តមនិងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម។ ឯកឧត្តមក៏បានជម្រាបជូននូវការផ្តាំផ្ញើសួរសុខទុក្ខរបស់ឯកឧត្តម **ចាវ ឡឺជី** ប្រធានសភាតំណាងប្រជាជនចិន គោរពជូន**សម្តេចតេជោ**ផងដែរ។

ឯកឧត្តម Wang Zhimin បានវាយតម្លៃខ្ពស់ចំពោះថាមភាពនិងលទ្ធផលបន្តបន្ទាប់នៃជំនួបនានារបស់ឯកឧត្តម ក្នុងឱកាសនៃដំណើរទស្សនកិច្ច។ ឯកឧត្តមបានគូសបញ្ជាក់ថា ការបន្តផ្លាស់ប្តូរដំណើរទស្សនកិច្ចថ្នាក់ដឹកនាំគ្រប់កម្រិតរវាងប្រទេសទាំងពីរបានបន្តពូនជ្រំមិត្តភាពដែកថែបចិន-កម្ពុជាឱ្យកាន់តែខ្លាំងក្លាបន្ថែមទៀត ជាពិសេសសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការជាច្រើនត្រូវបានចុះហត្ថលេខាក្នុងដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ឯកឧត្តម **ស៊ី ជីនពីង** កាលពីពេលថ្មីៗនេះ។ ឯកឧត្តមបានបញ្ជាក់ថា សភាតំណាងប្រជាជនចិនតែងតែបន្តរក្សាទំនាក់ទំនងនិងសហប្រតិបត្តិការល្អជាមួយរដ្ឋសភានិងព្រឹទ្ធសភាកម្ពុជា ស្របតាមចក្ខុវិស័យនៃអតីតថ្នាក់ដឹកនាំប្រទេសទាំងពីរ ជាមួយនឹងមនោសញ្ចេតនាស៊ីជម្រៅនិងជិតស្និទ្ធ។

ឯកឧត្តម Wang Zhimin បានសង្កត់ធ្ងន់ថា បច្ចុប្បន្នកម្រិតនៃទំនាក់ទំនងចិន-កម្ពុជាបានឈានឡើងជាបន្តបន្ទាប់ ដែលនឹងនាំមកនូវប្រយោជន៍ជាច្រើនដល់ប្រជាជននៃប្រទេសទាំងពីរ ក្នុងការកសាងជោគវាសនារួម ដែលនឹងក្លាយជាកម្លាំងចលករនិងសុខដុមរមនារវាងប្រទេសទាំងពីរ ជាពិសេសស្ថាប័ននីតិប្បញ្ញត្តិ។

នៅក្នុងជំនួបនោះ **សម្តេចតេជោ** បានថ្លែងអរគុណចំពោះការផ្តាំផ្ញើសួរសុខទុក្ខរបស់ ឯកឧត្តម **ចាវ ឡឺជី** ប្រធានសភាតំណាងប្រជាជនចិន។ **សម្តេច**ពិតជាមានមោទនភាពណាស់ក្នុងការរួមចំណែកពង្រឹងទំនាក់ទំនងប្រទេសទាំងពីរ តាមរយៈការបន្តវេន ដែលជាមរតករបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ និងឯកឧត្តម **ម៉ៅ សេទុង** ព្រមទាំងឯកឧត្តម **ជូ អេនឡាយ**។

**សម្តេចតេជោ** បានចែករំលែកនូវសភាពការណ៍និងបញ្ហាប្រឈមជាសកល ដែលទាមទារឱ្យប្រទេសទាំងពីរមានសាមគ្គីភាព ដើម្បីជម្នះការលំបាកនានា ដែលកើតឡើងតាមរយៈការអនុវត្តដោយឯកតោភាគី។ **សម្តេច**បានបន្តថា សភាពការណ៍ប្រឈមជាសកលនេះ ក៏ជាកាលានុវត្តភាពតម្រូវឱ្យកម្ពុជា-ចិននិងចិន-អាស៊ាន ពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត សំដៅត្រៀមរៀបចំខ្លួនពង្រឹងពហុភាគីនិយមនិងលើកកម្ពស់ការគោរពច្បាប់អន្តរជាតិ។

ទន្ទឹមនេះ **សម្តេចតេជោ** បានចែករំលែកនូវទស្សនវិស័យពាក់ព័ន្ធនឹងការជំរុញសហប្រតិបត្តិការលើវិស័យទេសចរណ៍ ទំនាក់ទំនងប្រជាជននិងប្រជាជន និងសេដ្ឋកិច្ចជាដើម។ **សម្តេច**បានវាយតម្លៃខ្ពស់ចំពោះមិត្តចិន ដែលតែងតែគោរពនិងផ្តល់តម្លៃខ្ពស់ចំពោះទំនាក់ទំនងប្រទេសទាំងពីរ បើទោះបីជាកម្ពុជាជាប្រទេសតូច ហើយចិនជាប្រទេសធំក្តី។ **សម្តេចតេជោ** បានសង្កត់ធ្ងន់ថា លទ្ធផលនៃទស្សនកិច្ចផ្លូវរដ្ឋរបស់ ឯកឧត្តម **ស៊ី ជីនពីង** កាលពីពេលកន្លងទៅ បានបន្តកសាងគ្រឹះយ៉ាងរឹងមាំនិងជាផែនទីចង្អុលផ្លូវនៃទំនាក់ទំនងរយៈពេលវែងសម្រាប់ប្រទេសទាំងពីរ។

ក្នុងឱកាសនោះផងដែរ **សម្តេចតេជោ** បានផ្តាំផ្ញើការគោរពនិងការសួរសុខទុក្ខចំពោះ ឯកឧត្តម **ចាវ ឡឺជី**, ឯកឧត្តម **វ៉ាង ហ៊ូនីង** និងឯកឧត្តម **ស៊ី ជីនពីង** ព្រមទាំងបានអញ្ជើញឯកឧត្តម **ចាវ ឡឺជី** មកបំពេញទស្សនកិច្ចនៅកម្ពុជា ក្នុងពេលសមស្របណាមួយ ។

ឯកឧត្តម Wang Zhimin បានវាយតម្លៃខ្ពស់ចំពោះចំណងមិត្តភាពជាប្រពៃណីរវាងថ្នាក់ដឹកនាំជាច្រើនជំនាន់និងមកដល់ដំណាក់កាលថ្មីកាន់តែស៊ីជម្រៅ។ ឯកឧត្តមបានសាទរចំពោះការកើតឡើងជាបន្តបន្ទាប់នៃទំហំពាណិជ្ជកម្មទ្វេភាគីនិងការវិនិយោគចិននៅកម្ពុជា។ ជាមួយគ្នានេះ កំណើននៃវិស័យទេសចរណ៍ ក៏នឹងជំរុញការកើនឡើងនូវវិស័យដទៃទៀតផងដែរ។

នៅចុងបញ្ចប់ **សម្តេចតេជោ**បានជូនពរ ឯកឧត្តម Wang Zhimin និងគណៈប្រតិភូ សូមទទួលបានជោគជ័យក្នុងដំណើរទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# សម្តេចតេជោ ហ៊ុន សែន ចង្អុលបង្ហាញឱ្យប្រទេសទីម័រឡេស្តេនិងកម្ពុជា បំពេញសក្តានុពលទៅវិញទៅមក





*លោកជំទាវ Maria Fernanda Lay និងសម្តេចតេជោ ហ៊ុន សែន*

ក្នុងឱកាសទទួលជួបសម្តែងការគួរសមរបស់លោកជំទាវ Maria Fernanda Lay ប្រធានរដ្ឋសភា នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ នៅវិមានព្រឹទ្ធសភា នារសៀលថ្ងៃពុធ ទី១៦ ខែកក្កដា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានចង្អុលបង្ហាញអំពីសក្តានុពលនៃសន្តិសុខស្បៀងរបស់កម្ពុជា ខណៈដែលទីម័រឡេស្តេមានសក្តានុពលសន្តិសុខថាមពល ដែលជាកត្តាបំពេញឱ្យគ្នាទៅវិញទៅមក។ **សម្តេច** សង្ឃឹមថា រដ្ឋាភិបាលនៃប្រទេសទាំងពីរនឹងធ្វើការជាមួយគ្នាបង្កើតភាពជាដៃគូ ដើរជាមួយគ្នាក្នុងនាមជាប្រទេសអភិវឌ្ឍន៍តិចតួច និងបន្តចែករំលែកបទពិសោធគ្នាទៅវិញទៅមក។

**សម្តេចតេជោ** បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះ **លោកជំទាវប្រធានរដ្ឋសភា**និងគណៈប្រតិភូ ដែលបានមកបំពេញទស្សនកិច្ចនិងចូលរួមកិច្ចប្រជុំក្រុមអ្នកនយោបាយរបស់អន្តរសភាអាស៊ានលើកទី១៦ (AIPA Caucus)។ **សម្តេច** បានសម្តែងនូវក្តីរីករាយដែលអាស៊ានបានសម្រេចទទួលទីម័រឡេស្តេ ជាសមាជិកពេញសិទ្ធិ នៅខែតុលា ឆ្នាំ២០២៥ ខាងមុខនេះ។

នៅក្នុងជំនួបនោះ **លោកជំទាវប្រធានរដ្ឋសភា**បានសម្តែងនូវការគោរពអរគុណនិងជាកិត្តិយសចំពោះការទទួលស្វាគមន៍របស់**សម្តេចតេជោ** និងការទទួលបដិសណ្ឋារកិច្ចដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំ AIPA។ លោកជំទាវបានមានប្រសាសន៍ថា នេះជាលើកទី១ហើយ ដែលលោកជំទាវបានមកកាន់កម្ពុជានិងបានឃើញហើយយល់ដឹងអំពីកម្ពុជា។ ដោយស្ថានភាពកម្ពុជានិងទីម័រឡេស្តេមានភាពស្រដៀងគ្នា លោកជំទាវនឹងពាំនាំបទបពិសោធមេរៀនទាំងអស់នេះទៅទីម័រឡេស្តេ។ លោកជំទាវសង្ឃឹមថា ក្នុងនាមបងប្អូនអាស៊ានកម្ពុជានឹងបន្តរួមដំណើរជាមួយគ្នា ហើយជឿជាក់ថា នៅក្នុងដំណើរនេះ ទីម័រឡេស្តេអាចប្រែក្លាយការប្រឈមនានា ទៅជាកាលានុវត្តភាព។

ក្នុងឱកាសនោះ **សម្តេចតេជោ** បានថ្លែងអំណរគុណចំពោះពាក្យពេចន៍ដែលលោកជំទាវបានលើកឡើងហើយក៏បានរំលឹកអំពីការទទួលបដិសណ្ឋារកិច្ចដ៏អស្ចារ្យ ប្រកបដោយភាពកក់ទាក់ ភាពស្និទ្ធស្នាលនិងការជឿទុកចិត្ត ចំពោះ**សម្តេច**

នៅក្នុងឱកាសដែល**សម្តេច**បានទៅទស្សនកិច្ចផ្លូវការនៅទីម័រឡេស្តេ។ តាមរយៈ**លោកជំទាវប្រធានរដ្ឋសភា** **សម្តេចតេជោ** បានផ្តាំផ្ញើនូវការសួរសុខទុក្ខ **ឯកឧត្តមបណ្ឌិតប្រធានាធិបតី** និង**ឯកឧត្តមនាយករដ្ឋមន្ត្រីទីម័រឡេស្តេ**។ **សម្តេចតេជោ** បានបង្ហាញអំពីស្ថានភាពខុសគ្នារវាងកម្ពុជានិងទីម័រឡេស្តេ ទាំងទិដ្ឋភាពសេដ្ឋកិច្ចនិងសង្គម នៅពេលដែលប្រទេសទាំងពីរចូលជាសមាជិកអាស៊ានដំបូង។ ជាមួយនឹងភាពអំណត់ទន្ទឹងរង់ចាំតាំងពីឆ្នាំ២០១១ ទីម័រឡេស្តេបានបោះជំហានអភិវឌ្ឍខ្លួនទៅលើផ្នែកផ្សេងៗ រួមទាំងធនធានមនុស្ស។ **សម្តេច**បានគូសបញ្ជាក់ឡើងវិញថា ការបញ្ចូលសមាជិកអាស៊ានថ្មី មិនមែនជាបន្ទុករបស់សមាជិកចាស់នោះទេ តែជាការរួមចំណែក ហើយជាការចាំបាច់ដែលអាស៊ានត្រូវការរួបរួមក្នុងតំបន់ និងធ្វើឱ្យតំបន់មានការរីកលូតលាស់។

**សម្តេចតេជោ** បានចែករំលែកអំពីមូលដ្ឋាន និងទស្សនៈវិស័យនៃការសម្រេចចិត្តរបស់ **សម្តេច** ក្នុងការផ្ទេរអំណាចជូនថ្នាក់ដឹកនាំជំនាន់ថ្មី ដើម្បីសន្តិភាព ស្ថិរភាពយូរអង្វែង ការអភិវឌ្ឍ និងជៀសវាងនូវការច្រំដែលនៃប្រវត្តិសាស្ត្ររបស់កម្ពុជា ដែលតែងតែមានជម្លោះនៅពេលមានការផ្លាស់ប្តូរថ្នាក់ដឹកនាំ៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន







*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# អគ្គលេខាធិការអន្តរសភាអាស៊ាន៖ ប្រវត្តិសាស្ត្រនិងការតស៊ូរបស់សម្តេចតេជោ ជាមេរៀនសម្រាប់កសាងសន្តិភាព និងសុខដុមរមនាសម្រាប់អាស៊ាន




*លោកជំទាវ Ar. Siti Rozaimeriyanty Dato Haji Abdul Rahman និងសម្តេចតេជោ ហ៊ុន សែន*

ក្នុងឱកាសចូលជួបសម្តែងការគួរសម សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា នាល្ងាចថ្ងៃពុធ ទី១៦ ខែកក្កដា ឆ្នាំ២០២៥ លោកជំទាវ Ar. Siti Rozaimeriyanty Dato Haji Abdul Rahman អគ្គលេខាធិការអន្តរសភាអាស៊ាន បានគូសបញ្ជាក់ថា ប្រវត្តិសាស្ត្រ និងការតស៊ូរបស់សម្តេចតេជោ **ហ៊ុន សែន** ជាមេរៀនសម្រាប់កសាងសន្តិភាពនិងសុខដុមរមនាសម្រាប់អាស៊ាន។

**លោកជំទាវអគ្គលេខាធិការ**បានថ្លែងអំណរគុណនិងកោតសរសើរគំរូវីរភាពរបស់**សម្តេចតេជោ** ដែលបានចែករំលែកបទពិសោធអំពីប្រវត្តិតស៊ូរបស់**សម្តេច** និងការកសាងកម្ពុជានិងធម្មនុញ្ញសន្តិភាពសកល ក្នុងឱកាសនៃកិច្ចប្រជុំពេញអង្គសភាអន្តរជាតិ ដើម្បីភាពអត់ឱននិងសន្តិភាពលើកទី១១ (IPTP-11) និងមហាសន្និបាតសន្និសីទអន្តរជាតិនៃបណ្តាគណបក្សនយោបាយនៅអាស៊ីលើកទី១២ (ICAPP-12)។

**លោកជំទាវអគ្គលេខាធិការ**បានកត់សម្គាល់ជាវិជ្ជមាននូវកិច្ចពិភាក្សា គំនិតផ្តួចផ្តើមល្អៗជាច្រើន ជាពិសេសគំនិតផ្តួចផ្តើមរបស់កម្ពុជាស្តីពីបណ្ណាល័យឌីជីថលអំពីច្បាប់ ដែលបាននិងកំពុងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនកម្ពុជាផង និងអាស៊ានផង។ លោកជំទាវបានបន្តថា ដោយផ្អែកលើបទពិសោធល្អរបស់កម្ពុជានេះ កាលពីខែមិថុនា ឆ្នាំ២០២៤ កន្លងទៅ អន្តរសភាអាស៊ាន (AIPA) បានសម្ពោធ AIPA LYNC ដែលជាបណ្ណាល័យឌីជីថល រួមមាន ឯកសារច្បាប់ពីបណ្តាប្រទេសជាសមាជិកអាស៊ាន ដែលមានអ្នកចូលប្រើប្រាស់រហូតដល់ជិត៣សែននាក់។

**លោកជំទាវអគ្គលេខាធិការ**បានថ្លែងអំណរគុណនិងសាទរចំពោះគំនិតផ្តួចផ្តើមវេទិកាថ្នាក់ដឹកនាំ AIPA, AIPA Caucus និងកម្មវិធី AIPA Roadshow ដែលមាននិស្សិតប្រមាណ៤០០នាក់ រង់ចាំសួរសំណួរដោយផ្ទាល់និងរាប់ពាន់នាក់តាមប្រព័ន្ធអនឡាញ។

**លោកជំទាវអគ្គលេខាធិការ**បានសម្តែងនូវការដឹងគុណចំពោះការគាំទ្រ និងការណែនាំរបស់**សម្តេចតេជោ** នាពេលកន្លងទៅ ចាប់តាំងពីពេលដែលលោកជំទាវចូលកាន់តំណែងជាអគ្គលេខាធិការអន្តរសភាអាស៊ាននៅឆ្នាំ២០២២។

នៅក្នុងជំនួបនោះ **សម្តេចតេជោ** បានសម្តែងស្វាគមន៍យ៉ាងកក់ក្តៅចំពោះ**លោកជំទាវអគ្គលេខាធិការ** ដែលចូលរួមកិច្ចប្រជុំអន្តរសភាអាស៊ាន (AIPA) ដែលកម្ពុជារៀបចំធ្វើជាម្ចាស់ផ្ទះ និងបានស្នើលោកជំទាវបន្តចែករំលែកបទពិសោធដល់កម្ពុជា ដែលនឹងបំពេញតួនាទីជាអគ្គលេខាធិការអន្តរសភាអាស៊ានប្តូរវេនបន្តពីលោកជំទាវ នាពេលខាងមុខ។

**សម្តេចតេជោ**បានថ្លែងអំណរគុណ**លោកជំទាវអគ្គលេខាធិការ**ចំពោះការកត់សម្គាល់អំពី បទពិសោធនិងគំនិតផ្តួចផ្តើមល្អៗរបស់កម្ពុជា ព្រមទាំងសាទរចំពោះសមិទ្ធផលនានា ដែល AIPA សម្រេចបាន។ **សម្តេចតេជោ** បានបញ្ជាក់ថា កម្ពុជាបានបំពេញតួនាទីយ៉ាងសកម្មនៅក្នុងក្របខ័ណ្ឌអាស៊ាន ហើយជាក់ស្តែង **សម្តេច**បានកាន់ញញួរក្នុងឋានៈជាប្រធានអាស៊ានចំនួន៣ដង នាពេលកន្លងទៅ។ **សម្តេចតេជោ** បានសម្តែងនូវក្តីរីករាយចំពោះការបង្កើតឱ្យមានបណ្ណាល័យឌីជីថលអំពីច្បាប់ (AIPA LYNC) ដែលជាបទពិសោធល្អសម្រាប់អាស៊ានផងដែរ។ **សម្តេច**បានចាត់ទុកតួនាទីរបស់សភា និងការចូលរួមយ៉ាងផុសផុលដោយផ្ទាល់និងអនឡាញនាពេលនេះ គឺជានិមិត្តរូបនៃការចូលរួមយ៉ាងសកម្មរបស់ប្រជាជនក្នុងសមាហរណកម្មពេញលេញក្នុងអាស៊ាន។

ក្រោមទិដ្ឋភាពសកល **សម្តេចតេជោ**បានបន្តចែករំលែកស្ថានភាពមិនច្បាស់លាស់នៃពិភពលោក ដែលតម្រូវឱ្យអាស៊ានធ្វើសមាហរណកម្មជាមួយដៃគូនានា ជាពិសេសសហប្រតិបត្តិការក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន អាស៊ាន-ចិន និង RCEP ជាដើម ដើម្បីឆ្លើយតបទៅនឹងការអនុវត្តដោយឯកតោភាគី។ **សម្តេចតេជោ** បានសង្កត់ធ្ងន់ថា ការពង្រឹងភាពជាដៃគូនិងអង្គការតំបន់របស់យើង ទាំងស្ថាប័ននីតិប្រតិបត្តិនិងនីតិប្បញ្ញត្តិ នឹងជំរុញឱ្យមានកំណើនជាក់ស្តែង កំណើនពាណិជ្ជកម្មអាស៊ានគ្នាឯងនិងការពង្រីកទីផ្សារក្នុងក្របខ័ណ្ឌ RCEP ជាដើម។

**សម្តេចតេជោ** បានបន្តកត់សម្គាល់អំពីសារៈសំខាន់នៃការចែករំលែកប្រវត្តិនិងបទពិសោធ ពីអ្នកជំនាន់មុនទៅអ្នកជំនាន់ក្រោយ តួយ៉ាងបទពិសោធជាច្រើនរបស់**សម្តេច** ក្នុងការកសាងនិងរក្សាបាននូវសន្តិភាពជូនកម្ពុជា ក្រៅពីអ្វីដែល**សម្តេច**បានចែករំលែកនៅរាជធានីភ្នំពេញ ប្រទេសឥណ្ឌូណេស៊ី និងនៅប្រទេសទីម័រឡេស្តេ។ **សម្តេចតេជោ** បានសម្តែងនូវការសាទរចំពោះសមិទ្ធផលរយៈពេលជិត២ឆ្នាំ នៃថ្នាក់ដឹកនាំបន្តវេនកម្ពុជា ដែលរក្សាបាននូវស្ថិរភាពនយោបាយ ម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ច។ **សម្តេចតេជោ** បានលើកឡើងថា ស្ថាប័ននីតិប្បញ្ញត្តិគ្រប់ប្រទេសគួរគាំទ្រដល់រដ្ឋាភិបាល ដើម្បីសម្រេចបាននូវចក្ខុវិស័យនិងឧត្តមប្រយោជន៍ជូនប្រជាជន។ ក្នុងន័យនេះ **សម្តេចតេជោ** បានផ្តួចផ្តើមវេទិកាថ្នាក់ដឹកនាំព្រឹទ្ធសភា សំដៅជំរុញឱ្យមានកិច្ចសន្ទនារវាងព្រឹទ្ធសភា និងប្រែក្លាយវេទិកានេះ ទៅជារចនាសម្ព័ន្ធទ្រទ្រង់ដល់រដ្ឋាភិបាល ក៏ដូចជាយន្តការសម្រាប់អាស៊ានផងដែរ៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# សម្តេចតេជោ ហ៊ុន សែន៖ សាលានាយទាហាន ពលទាហាន នៅតាមបណ្តាភូមិភាគនានា ត្រូវរៀបចំក្នុងកាលៈទេសៈដ៏សមស្រប ដើម្បីអនុវត្តកាតព្វកិច្ចយោធានៅឆ្នាំ២០២៦





*ឯកឧត្តមឧត្តមសេនីយ៍ឯក Roy Mabagos Galido និងសម្តេចតេជោ ហ៊ុន សែន*





*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា សាលានាយទាហាន សាលាពលទាហាន នៅតាមបណ្តាភូមិភាគនានា គួរត្រូវបានរៀបចំក្នុងកាលៈទេសៈដ៏សមស្រប ដើម្បីត្រៀមអនុវត្តកាតព្វកិច្ចយោធានៅឆ្នាំ២០២៦ ដូចនឹងអ្វីដែលសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានលើកឡើង និងអនុលោមតាមច្បាប់ស្តីពី កាតព្វកិច្ចយោធា មានតាំងពី២០ឆ្នាំមុនម្ល៉េះ។

**សម្តេចតេជោ** មានប្រសាសន៍យ៉ាងដូច្នេះ ក្នុងឱកាសជំនួបជាមួយឯកឧត្តមឧត្តមសេនីយ៍ឯក Roy Mabagos Galido មេបញ្ជាការកងទ័ពជើងគោកហ្វីលីពីននិងគណៈប្រតិភូ នៅវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃសុក្រ ទី១៨ ខែកក្កដា ឆ្នាំ២០២៥។

**សម្តេចតេជោ** បានចែករំលែកអំពីប្រវត្តិនៃការហ្វឹកហ្វឺនអាជីពកងទ័ពនិងការកសាងបង្កើតកងទ័ព ជាពិសេស ចក្ខុវិស័យរបស់សម្តេចក្នុងការរក្សាធនធានមនុស្ស ដែលជាមេទ័ពចាស់មានបទពិសោធ ពីព្រោះមេទ័ពត្រូវតែរក្សានូវភាព នឹងនរនិងភាពម្ចាស់ការក្នុងការប្រយុទ្ធ។

**សម្តេចតេជោ** បានលើកឡើងថាវត្តមានរបស់ឯកឧត្តមមេបញ្ជាការនិងគណៈប្រតិភូក្នុងពេលនេះ ក៏ដូចជាកាលពីឆ្នាំកន្លងទៅបានបង្ហាញឱ្យឃើញនូវទំនាក់ទំនងយ៉ាងជិតស្និទ្ធនិងសហប្រតិបត្តិការល្អរវាងកងទ័ពជើងគោក នៃប្រទេសទាំងពីរ។ តាមរយៈទំនាក់ទំនងដ៏ល្អនេះជាកត្តាស្នូលជំរុញដល់កិច្ចសហការលើវិស័យផ្សេងៗទៀតឱ្យមានការរីកចម្រើនថែមទៀត។

នៅក្នុងជំនួបនោះ **ឯកឧត្តមមេបញ្ជាការ**បានគូសបញ្ជាក់ថា ដំណើរទស្សនកិច្ចរបស់ឯកឧត្តមនិងគណៈប្រតិភូកងទ័ពជើងគោកហ្វីលីពីននៅកម្ពុជា នឹងបន្តលើកកម្ពស់ទំនាក់ទំនងទ្វេភាគីដែលមានស្រាប់ ជាពិសេសការបន្តចែករំលែកបទពិសោធរវាងកងទ័ពហ្វីលីពីននិងកម្ពុជា តាមរយៈសកម្មភាពហ្វឹកហ្វឺនរួមគ្នា។

ក្នុងឱកាសនោះ **សម្តេចតេជោ** បានសម្តែងនូវការសាទរចំពោះការរីកចម្រើនឥតឈប់ឈរនៃទំនាក់ទំនងកងទ័ពប្រទេសទាំងពីរ។ **សម្តេច**បានវាយតម្លៃខ្ពស់ចំពោះការរៀបចំឱ្យមានវគ្គហ្វឹកហ្វឺនស្រាវជ្រាវនិងប្រយុទ្ធក្នុងទីក្រុងនាពេលបច្ចុប្បន្នហើយនេះជាផ្នែកមួយដ៏សំខាន់សម្រាប់កងទ័ពកម្ពុជាក្នុងការពង្រឹងសមត្ថភាពនិងបទពិសោធបន្ថែមលើសមត្ថភាពប្រយុទ្ធក្នុងព្រៃ។

**សម្តេចតេជោ** បានបន្តចែករំលែកប្រវត្តិនិងបទពិសោធ ក៏ដូចជាផលវិបាកនៃសង្គ្រាមរបស់កម្ពុជាទាំងនៅទីក្រុងនិងនៅព្រំដែន ដែលបានជួបប្រទះនាពេលកន្លងមក។ **សម្តេចតេជោ** បានរំលេចថា តាមរយៈការឈឺចាប់ទាំងនេះ **សម្តេច**បានដាក់ចេញនូវនយោបាយឈ្នះ-ឈ្នះ ដែលបាននាំមកនូវការឯកភាពទឹកដីនិងសុខសន្តិភាពជូនកម្ពុជាប្រមាណជិត២៧ឆ្នាំមកហើយ ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រកម្ពុជាប្រមាណ៥០០ឆ្នាំចុងក្រោយនេះ។ **សម្តេចតេជោ** បានសង្កត់ធ្ងន់ថា ការឯកភាពទឹកដីនិងសុខសន្តិភាពនេះហើយ ដែលជាបុរេលក្ខខណ្ឌក្នុងការនាំមកនូវការអភិវឌ្ឍ។

**សម្តេចតេជោ**ក៏បានលើកឡើងអំពីសក្តានុពលស្បៀងរបស់កម្ពុជាក្នុងការនាំចេញទៅទីផ្សារហ្វីលីពីននិងកាលានុវត្តភាពនៃវិស័យផ្សេងៗទៀតក្នុងការពង្រឹងភាពជាដៃគូល្អកម្ពុជា-ហ្វីលីពីន៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# កម្ពុជាមិនមានការទាត់ចោល ឬលុបចោលក្រុមហ៊ុនដែលចូលមកដំណើរការនៅកម្ពុជា មិនថាតូច ឬធំនោះទេ ដើម្បីបង្កជំនឿទុកចិត្តដល់វិនិយោគិននានា





*លោក យ៉ូស៊ីហ៊ីសា កៃនុម៉ា និងសម្តេចតេជោ ហ៊ុន សែន*

នៅប្រទេសកម្ពុជាកម្រឃើញមានការទាត់ចោល ឬលុបចោលក្រុមហ៊ុនដែលចូលមកដំណើរការនៅប្រទេសកម្ពុជា មិនថាតូច ឬធំនោះទេ។ នេះជាគោលការណ៍សម្រាប់បង្កើនជំនឿទុកចិត្តដល់វិនិយោគិននានា ចំពោះបរិយាកាសវិនិយោគនៅក្នុងប្រទេសកម្ពុជា។

នេះជាប្រសាសន៍លើកឡើងរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសជំនួបជាមួយឱ្យលោក **យ៉ូស៊ីហ៊ីសា កៃនុម៉ា** (Yoshihisa Kainuma) ប្រធាននាយកប្រតិបត្តិនៃក្រុមហ៊ុន មីនេបៀត្សូមី នៅវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃអង្គារ ទី២២ ខែកក្កដា ឆ្នាំ២០២៥។

នៅក្នុងឱកាសនោះ **សម្តេចតេជោ** បានគូសបញ្ជាក់អំពីគោលការណ៍ស្វាគមន៍ចំពោះក្រុមហ៊ុនវិនិយោគ ដោយក្រុមហ៊ុនណាមកមុន នឹងទទួលស្វាគមន៍មុន មិនថាក្រុមហ៊ុននោះតូច ឬធំនោះទេ។ **សម្តេច**បានសម្តែងនូវក្តីរីករាយដែលបានឃើញផលិតផលរបស់ក្រុមហ៊ុនជាមួយនឹងបច្ចេកវិទ្យាចុងក្រោយផលិតនៅប្រទេសកម្ពុជា (Made in Cambodia)។ **សម្តេច**ក៏បានលើកទឹកចិត្តឱ្យមានការពង្រីករោងចក្រនៅខេត្តពោធិ៍សាត់ ដែលជាអាទិភាពគោលដៅដ៏ល្អ មានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូននិងការផ្គត់ផ្គង់អគ្គិសនីគ្រប់គ្រាន់។ ជាមួយគ្នានោះ **សម្តេចតេជោ** បានសង្កេតឃើញថា រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន បានបន្តយកចិត្តទុកដាក់ចំពោះក្រុមហ៊ុនជប៉ុន ដែលបានធ្វើការពង្រីកខ្លួនជាបន្តបន្ទាប់នៅប្រទេសកម្ពុជា។

នៅក្នុងជំនួបនោះ លោក **យ៉ូស៊ីហ៊ីសា កៃនុម៉ា** បានសម្តែងនូវការអបអរសាទរចំពោះសុខភាពដ៏មាំមួនរបស់**សម្តេចតេជោ** និងបានថ្លែងអំណរគុណចំពោះ**សម្តេច**ដែលបានជួយជ្រោមជ្រែងនិងធ្វើឱ្យក្រុមហ៊ុនមីនេបៀត្សូមីទទួលបានភាពជោគជ័យក្នុងរយៈពេលដប់បួនឆ្នាំកន្លងទៅ។

លោក **យ៉ូស៊ីហ៊ីសា កៃនុម៉ា** បានជម្រាបជូន**សម្តេចតេជោ** ជ្រាបអំពីគម្រោងនៃការបើកសម្ពោធរោងចក្រដ៏ធំមួយទៀតនៅខេត្តពោធិ៍សាត់ ក្នុងខែធ្នូ ឆ្នាំ២០២៥ ជាមួយនឹងការបង្ហាញផលិតផលចុងក្រោយរបស់ក្រុមហ៊ុន ដែល



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

នឹងដាក់ឱ្យចរាចរនៅលើទីផ្សារអន្តរជាតិនៅក្នុងឆ្នាំ២០២៦ខាងមុខ។ ទន្ទឹមគ្នានោះ លោក **យ៉ូស៊ីហ៊ីសា កែនុម៉ា** បាន លើកឡើងអំពីផលប៉ះពាល់នៃការបិទច្រកព្រំដែនរបស់ថៃ ចំពោះដំណើរការវិនិយោគរបស់ក្រុមហ៊ុន ដូចជា ផលលំបាក នៃការដឹកគ្រឿងបង្គុំដែលជាខ្សែច្រវាក់ផលិតកម្មរបស់ក្រុមហ៊ុនរវាងប្រទេសទាំងពីរ។

ជាការឆ្លើយតប **សម្តេចតេជោ** បានសម្តែងនូវក្តីរីករាយនិងមោទនភាពចំពោះវឌ្ឍនភាពរបស់ក្រុមហ៊ុន ព្រមទាំង បានរំលេចអំពីប្រវត្តិនៃការចូលមកឈរជើងជាលើកដំបូងរបស់ក្រុមហ៊ុននៅប្រទេសកម្ពុជា ក្នុងខណៈដែលមានក្រុមហ៊ុន ផ្សេងៗចូលមកប្រកួតប្រជែងជាមួយ។

**សម្តេចតេជោ** បានជម្រាបអំពីឫសគល់និងសកម្មភាពតាមអំពើចិត្តរបស់ថៃ ដែលធ្វើឱ្យសភាពការណ៍តានតឹង នៅតាមព្រំដែនកម្ពុជា-ថៃ។ **សម្តេច**បានអំពាវនាវម្តងហើយម្តងទៀតទៅកាន់ភាគីថៃថា កុំឱ្យបញ្ហានៅតំបន់ព្រំដែន រីករាលដាលទៅតំបន់ផ្សេងទៀត ពីវិស័យយោធាទៅវិស័យសេដ្ឋកិច្ចសង្គមនិងទេសចរណ៍។ ទោះយ៉ាងនេះក្តី ថៃមិន ត្រឹមតែបានពង្រីកបញ្ហានោះទេ និងថែមទាំងបានគំរាមកម្ពុជា ដូចជា បញ្ហាអគ្គិសនី អ៊ីនធឺណិត ប្រេង និងឧស្ម័ន ហើយថ្មីៗនេះបញ្ហាដើរជាន់មីនរបស់ទាហានថៃ។ **សម្តេចតេជោ** បានបញ្ជាក់អំពី ការប្រកាន់គោលជំហររបស់កម្ពុជា ក្នុងការដោះស្រាយបញ្ហាដោយសន្តិវិធីនិងបានគូសបញ្ជាក់ ដោយស្នើឱ្យក្រុមហ៊ុននាំនាំទៅកាន់ភាគីថៃ នូវគោលជំហរ របស់កម្ពុជា ចំពោះការបិទច្រកព្រំដែនជាឯកតោភាគីរបស់ថៃ ពោលគឺ ធ្វើយ៉ាងណាឱ្យស្ថានភាពវិលត្រឡប់ទៅរក មុនថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៥។ **សម្តេចតេជោ** សង្ឃឹមថា វាគួរតែមានដំណោះស្រាយអន្តរកាលមួយចំពោះតែ ក្រុមហ៊ុនបរទេសវិនិយោគឆ្លងដែន ដើម្បីជួយសម្រួលដល់ដំណើរការខ្សែច្រវាក់ផ្គត់ផ្គង់ទៅមុខរបស់ក្រុមហ៊ុននៅក្នុង ការវិនិយោគរបស់ខ្លួន៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន

# សម្ដេចតេជោ ផ្ដល់អនុសាសន៍ដល់ក្រុមហ៊ុននៃប្រទេសកាតា ពិនិត្យលទ្ធភាពវិនិយោគលើការកែច្នៃស្បៀង និងវត្ថុធាតុដើមកសិកម្មនៅកម្ពុជា



*លោក Fahd Al Dosari និងសម្ដេចតេជោ ហ៊ុន សែន*

ក្នុងឱកាសអនុញ្ញាតឱ្យគណៈប្រតិភូក្រុមហ៊ុនវិនិយោគនៃប្រទេសកាតា ដឹកនាំដោយ លោក Fahd Al Dosari ប្រធានផ្នែកទំនាក់ទំនង និងជាទីប្រឹក្សាពិសេសនៃ Sheikh Mansour bin Jabor Al Thani និងគណៈប្រតិភូនៃក្រុមហ៊ុន AI Mansour Asia ចូលជួបសម្ដែងការគួរសម នៅវិមានព្រឹទ្ធសភា នាព្រឹកថ្ងៃអង្គារ ទី២២ ខែកក្កដា ឆ្នាំ២០២៥ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានផ្ដល់អនុសាសន៍ដល់ក្រុមហ៊ុនឱ្យពិនិត្យលទ្ធភាពវិនិយោគលើការកែច្នៃស្បៀង និងវត្ថុធាតុដើមកសិកម្មនៅកម្ពុជា។

**សម្ដេចតេជោ** បានបង្ហាញអំពីកាលានុវត្តភាពសម្រាប់ការកែច្នៃស្រូវ ក្នុងខណៈពេលដែលកម្ពុជា គឺជាប្រទេសមានអតិរេកស្រូវ ស្របពេលដែលកាតាគឺជាប្រទេសត្រូវការស្បៀង។ **សម្ដេច**បានបន្តថា តាមរយៈការរៀបចំប្រមូលទិញស្តុកនិងបង្កើតម៉ាស៊ីនកិនស្រូវនេះ កម្ពុជា-កាតាអាចពង្រីកការផ្គត់ផ្គង់ស្បៀងទៅកាន់ប្រទេសនានានៅមជ្ឈិមបូព៌ាដែលត្រូវការស្បៀងផងដែរ។

**សម្ដេចតេជោ** បានកត់សម្គាល់អំពី សក្ដានុពលនៃស្វាយចន្ទីកម្ពុជា ដែលនាពេលបច្ចុប្បន្ននេះ កម្ពុជាគឺជាប្រទេសផលិតគ្រាប់ស្វាយចន្ទីច្រើនជាងគេលើពិភពលោកនិងបាននាំចេញប្រមាណ៦០ម៉ឺនតោនរួចទៅហើយក្នុងមួយឆមាសដើមឆ្នាំ២០២៥នេះ។ ផ្អែកតាមតួលេខនេះ **សម្ដេចតេជោ** បានគូសបញ្ជាក់ថា កម្ពុជានឹងអាចបន្តនាំចេញគ្រាប់ស្វាយចន្ទីប្រមាណ១លានតោននៅក្នុងឆ្នាំនេះ។ នេះជាពេលវេលាដ៏សមស្របសម្រាប់ការវិនិយោគរបស់ក្រុមហ៊ុន ក្នុងការបង្កើតរោងចក្រកែច្នៃគ្រាប់ស្វាយចន្ទី។ **សម្ដេច**បានបន្តថា កម្ពុជានៅមានដំឡូងមីនិងជ័រកៅស៊ូ ដែលកម្ពុជាមិនទាន់បានកែច្នៃឱ្យអស់សក្ដានុពលនៅឡើយ ហើយទីផ្សារនៅកម្ពុជានិងនៅក្នុងតំបន់ក៏នៅមានលម្ហក្នុងការផ្គត់ផ្គង់ ដែលគួរតែក្រុមហ៊ុនសិក្សាចាប់យកឱកាសវិនិយោគនេះ។

តាងនាមឱ្យគ្រួសាររាជវង្សនៃកាតានិងក្រុមហ៊ុន AI Mansour Asia, លោក Fahd AI Dosari បានសម្ដែងនូវក្ដីសោមនស្សរីករាយ ក្នុងការបន្តពង្រឹងទំនាក់ទំនងរវាងប្រទេសទាំងពីរបន្ថែមទៀត ជាពិសេសលើការវិនិយោគក្នុងវិស័យសាធារណៈនិងឯកជន។ លោកបានគូសបញ្ជាក់ថា ក្រុមហ៊ុន AI Mansour Asia បានដាក់ទិសដៅវិនិយោគនៅអាស៊ី-អាគ្នេយ៍ ដោយចាប់ផ្ដើមការវិនិយោគនៅកម្ពុជានិងមានលោក Jay Han ជានាយកប្រតិបត្តិប្រចាំនៅកម្ពុជា។



*លោក Fahd Al Dosari និងសម្តេចតេជោ ហ៊ុន សែន*

លោក Fahd AI Dosari បានថ្លែងអំណរគុណ**សម្តេចតេជោ** ចំពោះអនុសាសន៍ណែនាំនិងបង្ហាញការចាប់អារម្មណ៍លើវិស័យកសិកម្ម កម្មន្តសាល ក៏ដូចជាគម្រោងហេដ្ឋារចនាសម្ព័ន្ធគាំទ្រវិស័យទេសចរណ៍ ដូចជា សណ្ឋាគារ ការអភិវឌ្ឍកោះ ទីកន្លែងកម្សាន្ត និងព្រលានយន្តហោះ។ លោកបានសង្កត់ធ្ងន់ថា ក្រុមហ៊ុនរបស់លោកមើលឃើញយ៉ាងច្បាស់អំពីសុខសន្តិភាព សុវត្ថិភាព និងស្ថិរភាពរបស់កម្ពុជា។ ដូច្នេះទើបក្រុមហ៊ុនចាប់ផ្តើមការវិនិយោគនៅអាស៊ីអាគ្នេយ៍ ដោយផ្តើមចេញពីការវិនិយោគនៅកម្ពុជា។

**សម្តេចតេជោ** បានថ្លែងអំណរគុណ លោក Fahd AI Dosari ចំពោះការទុកចិត្តនិងមើលឃើញអំពីសន្តិភាពនិងស្ថិរភាពនៅកម្ពុជានិងគម្រោងវិនិយោគទាំងអស់ រួមទាំងវិស័យទេសចរណ៍និងហេដ្ឋារចនាសម្ព័ន្ធ។ ជាទីបញ្ចប់ **សម្តេច** បានជូនពរគណៈប្រតិភូឱ្យទទួលបានជោគជ័យក្នុងដំណើរទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា៕

ប្រភព៖ Telegram Channel សម្តេចតេជោ

សម្រួលខ្លឹមសារ, រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

# ឯកឧត្តម អ៊ុច បូរិទ្ធ អនុញ្ញាតឱ្យគណៈប្រតិភូមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ





*លោក គីម ជុងណាម និងឯកឧត្តម អ៊ុច បូរិទ្ធ*

នារសៀលថ្ងៃព្រហស្បតិ៍ ទី២៦ ខែមិថុនា ឆ្នាំ២០២៥ វេលាម៉ោង១៥:០០នាទី ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យ លោក **គីម ជុងណាម** ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល (Global Life Sharing) នៃសាធារណរដ្ឋកូរ៉េនិងប្រតិភូមូលនិធិ ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា និងបានពិភាក្សាអំពីការងារសកម្មភាពមនុស្សធម៌និងសក្តានុពលវិនិយោគនៅកម្ពុជា។

តាងនាមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានសម្តែងស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈប្រតិភូ ក្នុងដំណើរទស្សនកិច្ចមកកម្ពុជា ជាលើកទី៣។ ឯកឧត្តមបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះទឹកចិត្តដ៏សប្បុរសរបស់មូលនិធិ តាមរយៈការផ្តល់អំណោយដ៏ថ្លៃថ្លាជាថវិកានិងសម្ភារៈនានា សំដៅរួមចំណែកលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជានៅតាមបណ្តារាជធានី/ខេត្ត និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។ ឯកឧត្តមបានសង្កត់ធ្ងន់ថា សកម្មភាពសប្បុរសធម៌នេះមិនត្រឹមតែរួមចំណែកជួយដោះស្រាយនូវភាពខ្វះខាតជូនដល់ប្រជាជនទីទ័លក្រ និងងាយរងគ្រោះប៉ុណ្ណោះទេ ប៉ុន្តែក៏បានជួយពូនជ្រំកិច្ចសហប្រតិបត្តិការល្អរវាងរដ្ឋាភិបាលនៃប្រទេសទាំងពីរផងដែរ។





*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

**ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានសម្តែងនូវមោទនភាពនិងវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-សាធារណរដ្ឋកូរ៉េ ដែលត្រូវបានពង្រឹង និងពង្រីកជាប្រចាំលើគ្រប់វិស័យរួមទាំងវិស័យនយោបាយការបរទេស សន្តិសុខ ការពារជាតិ សេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ សិល្បៈ វប្បធម៌ អប់រំ សុខាភិបាល កីឡា ជំនួយមនុស្សធម៌ ការផ្លាស់ប្តូរប្រជាជន និងប្រជាជន ក្រោយពីការផ្សារភ្ជាប់ទំនាក់ទំនងការទូតឡើងវិញនៅឆ្នាំ១៩៩៧ ដែលមានសម្តេចតេជោ **ហ៊ុន សែន** និងឯកឧត្តម **គីម យ៉ុងសាំ** អតីតប្រធានាធិបតីសាធារណរដ្ឋកូរ៉េ ជាសហស្ថាបនិក។ ឯកឧត្តមបានបន្ថែមថា ទំនាក់ទំនងដ៏ល្អប្រសើរនេះត្រូវបានដំឡើងកម្រិតជា «ដៃគូយុទ្ធសាស្ត្រ» ក្នុងអំឡុងពេលទស្សនកិច្ចរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋកូរ៉េ កាលពីខែឧសភា ឆ្នាំ២០២៤។

**ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** ជឿជាក់យ៉ាងមុតមាំថា កិច្ចសហការដ៏ល្អរវាងមូលនិធិ ជាមួយគណៈកម្មការទី១០ព្រឹទ្ធសភា ដឹកនាំដោយ ឯកឧត្តម **ម៉ម ប៊ុននាង** និងក្រុមមិត្តភាពសមាជិកព្រឹទ្ធសភាកម្ពុជា-សាធារណរដ្ឋកូរ៉េ នឹងបន្តរីកចម្រើនថែមទៀត ព្រមទាំងរួមចំណែកដ៏សំខាន់ដល់ការលើកកម្ពស់ទំនាក់ទំនងនិងមិត្តភាពកម្ពុជា-សាធារណរដ្ឋកូរ៉េ។ ក្នុងឱកាសនោះផងដែរ ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា ក៏បានជម្រាបជូនគណៈប្រតិភូកូរ៉េអំពីបរិយាកាសអនុគ្រោះសម្រាប់ការវិនិយោគនៅកម្ពុជា និងស្នើគណៈប្រតិភូកូរ៉េពិចារណាវិនិយោគក្នុងវិស័យសក្តានុពល ជាពិសេសវិស័យកសិ-ឧស្សាហកម្ម ពីព្រោះថា កម្ពុជាមានសក្តានុពលខ្ពស់ក្នុងវិស័យនេះនិងមានដំណាំយុទ្ធសាស្ត្រ ជាច្រើន រួមមាន៖ ស្វាយចន្ទី ដំឡូងមី និងដំណាំស្រូវ ដែលទាមទារឱ្យមានការវិនិយោគកែច្នៃក្នុងស្រុកដើម្បីបង្កើតតម្លៃបន្ថែម។

នៅក្នុងជំនួបនោះ **លោកប្រធានមូលនិធិ** បានកត់សម្គាល់នូវការអភិវឌ្ឍយ៉ាងឆាប់រហ័សក្រោមម្លប់នៃសុខសន្តិភាពនៅកម្ពុជា និងបញ្ជាក់ថា «លោកពិតជាស្រលាញ់ប្រទេសកម្ពុជាខ្លាំងណាស់»។ លោកបានសង្កេតឃើញពីសកម្មភាពយ៉ាងផុសផុលរបស់ព្រឹទ្ធសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោ** ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត ក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ។ ជាមួយគ្នានេះ លោកបានថ្លែងអំណរគុណចំពោះការគាំទ្រប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់ថ្នាក់ដឹកនាំនិងក្រុមការងារព្រឹទ្ធសភា ដែលបានអនុញ្ញាតឱ្យសកម្មភាពមនុស្សធម៌របស់មូលនិធិនៅកម្ពុជា ប្រព្រឹត្តទៅដោយផ្លែផ្កា មានតម្លាភាព ចំគោលដៅនិងមានប្រសិទ្ធភាពខ្ពស់។ លោកប្រធានមូលនិធិ បានជម្រាបជូនភាគីកម្ពុជា អំពីការប្តេជ្ញាចិត្តនិងផែនការរបស់មូលនិធិក្នុងការបន្ថែមទឹកប្រាក់និងបង្កើនសកម្មភាពសប្បុរសធម៌នៅកម្ពុជា ក្នុងគោលបំណងរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ថែមទៀត៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា
រូបភាព៖ នាយកដ្ឋានព័ត៌មាន



ឯកឧត្តម អ៊ុច បូររិទ្ធ ថតរូបអនុស្សាវរីយ៍

# ឯកឧត្តម អ៊ុច បូររិទ្ធ អនុញ្ញាតឱ្យគណៈប្រតិភូសភាតួកគីយេ ប្រចាំអន្តរសភាអាស៊ាន ចូលជួបសម្តែងការគួរសម



ឯកឧត្តម អូស្មាន សាហ្គុឡាម និងឯកឧត្តម អ៊ុច បូររិទ្ធ



ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម

នាព្រឹកថ្ងៃអង្គារ ទី១៥ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បានអនុញ្ញាតឱ្យ ឯកឧត្តម **អូស្មាន សាហ្គុឡាម** សមាជិករដ្ឋសភា និងជាប្រធានគណៈប្រតិភូសភាតួកគីយេប្រចាំអន្តរសភាអាស៊ាន (AIPA) ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។

នៅក្នុងជំនួបនោះ **ឯកឧត្តមអនុប្រធានទី១** បានសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈប្រតិភូតួកគីយេ ក្នុងដំណើរទស្សនកិច្ចមកកម្ពុជា ដើម្បីចូលរួម «កិច្ចប្រជុំអ្នកនយោបាយនៃអន្តរសភាអាស៊ានលើកទី១៦» (16th AIPA Caucus) ចាប់ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៥។ **ឯកឧត្តមអនុប្រធានទី១** បានគូសបញ្ជាក់ថា កិច្ចប្រជុំនេះ គឺជាវេទិកាដ៏សំខាន់មួយសម្រាប់ពង្រឹងសហប្រតិបត្តិការសភា ការទូត និងការអភិវឌ្ឍប្រកបដោយចីរភាព នៅក្នុងអាស៊ាន និងដៃគូអាស៊ាន។

**ឯកឧត្តមអនុប្រធានទី១** ក៏បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងនិងសហប្រតិបត្តិការរវាងកម្ពុជា-តួកគីយេ ដែលត្រូវបានពង្រឹងនិងពង្រីកជាលំដាប់ គ្របដណ្តប់វិស័យសំខាន់ៗ ជាពិសេស វិស័យសេដ្ឋកិច្ច ទេសចរណ៍ វប្បធម៌ ការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន ព្រមទាំងវិស័យអប់រំ។ ជាមួយគ្នានេះ ឯកឧត្តមក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះជំនួយឧបត្ថម្ភដ៏ថ្លៃថ្លាដែលរដ្ឋាភិបាលតួកគីយេ បានផ្តល់តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការ និងសម្របសម្រួលតួកគី (TIKA) ដល់កម្ពុជា ក្នុងវិស័យអភិវឌ្ឍន៍ធនធានមនុស្សនិងសង្គម។

ក្នុងឱកាសនោះ ឯកឧត្តម **អូស្មាន សាហ្គុឡាម** បានបង្ហាញពីក្តីសោមនស្សរីករាយក្នុងការអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជា ដើម្បីចូលរួមកិច្ចប្រជុំអ្នកនយោបាយនៃអន្តរសភាអាស៊ានលើកទី១៦ (16th AIPA Caucus) ដែលនេះគឺជាលើកទីមួយរបស់តួកគីយេ បន្ទាប់ពីបានក្លាយជាអ្នកសង្កេតការណ៍របស់ «អាយប៉ា» កាលពីខែសីហា ឆ្នាំ២០២៣។ ឯកឧត្តមបានគូសបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ប្រទេសតួកគីយេនៅក្នុងការពង្រឹងចំណងទាក់ទង និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យជាមួយកម្ពុជា រួមទាំងអាស៊ាន។

ជាចុងក្រោយ **ឯកឧត្តមអនុប្រធានទី១** បង្ហាញពីជំនឿជឿជាក់យ៉ាងមុតមាំថា ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូសភាតួកគីយេនាពេលនេះ នឹងរួមចំណែកបន្ថែមទៀត ដល់ការលើកកម្ពស់ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការទ្វេភាគី និងតំបន់ ឱ្យឡើងខ្ពស់ថែមមួយកម្រិតទៀត។ ឯកឧត្តម ក៏បានជូនពរ ឯកឧត្តម **អូស្មាន សាហ្គុឡាម** និងគណៈប្រតិភូទទួលបានជោគជ័យជាផ្លែផ្កានៅក្នុង «កិច្ចប្រជុំអ្នកនយោបាយនៃអន្តរសភាអាស៊ានលើកទី១៦» និងទទួលបានភាពសប្បាយរីករាយក្នុងឱកាសស្នាក់នៅប្រទេសកម្ពុជា ៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម អ៊ុច បូររិទ្ធ ទទួលជួបពិភាក្សាការងារជាមួយលោកស្រីភារធារីស្តីទី នៃស្ថានទូតសហរដ្ឋអាម៉េរិកប្រចាំកម្ពុជា





*លោកស្រី ប្រែហ្គេត អែល កែឃីរ និងឯកឧត្តម អ៊ុច បូររិទ្ធ*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១៧ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យ លោកស្រី **ប្រែហ្គេត អែល ខ័កឃីរ** ភារធារីស្តីទីនៃស្ថានទូតសហរដ្ឋអាម៉េរិកប្រចាំកម្ពុជា និងសហការី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅវិមានព្រឹទ្ធសភា។

នៅក្នុងកិច្ចសន្ទនា **ឯកឧត្តមអនុប្រធានទី១** និងលោកស្រី **ប្រែហ្គេត អែល ខ័កឃីរ** បានពិភាក្សាគ្នាអំពីបញ្ហានានាទាក់ទងនឹងកិច្ចសហប្រតិបត្តិការទ្វេភាគី និងបានផ្លាស់ប្តូរយោបល់គ្នាអំពីស្ថានការណ៍វិវត្តថ្មីៗនៅក្នុងតំបន់ និងអន្តរជាតិ។

ជាកិច្ចចាប់ផ្តើម ជាមួយនឹងការស្វាគមន៍ចំពោះគណៈប្រតិភូ **ឯកឧត្តមអនុប្រធានទី១** បានសម្តែងការអបអរសាទរចំពោះព្រឹត្តិការណ៍សំខាន់ៗដែលបានរៀបចំនៅក្នុងឱកាសខួបលើកទី៧៥ នៃទំនាក់ទំនងការទូតរវាងកម្ពុជា និងអាម៉េរិក ដែលជាសក្ខីភាពបញ្ជាក់ពីការរីកចម្រើននៃទំនាក់ទំនងមិត្តភាពនិងកិច្ចសហប្រតិបត្តិការល្អប្រសើររវាងប្រទេសទាំងពីរ។ ឯកឧត្តមក៏បានអបអរសាទរផងដែរចំពោះជោគជ័យនៃ «កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយសហរដ្ឋអាម៉េរិក» ដែល ឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានធ្វើជាសហប្រធានដឹកនាំកិច្ចប្រជុំជាមួយ ឯកឧត្តម **ម៉ាកូ រ៉ូប៊ីអូ** (Marco Rubio) រដ្ឋមន្ត្រីការបរទេសអាម៉េរិក នាពេលថ្មីៗនេះ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី ក្នុងតួនាទីកម្ពុជាជាប្រទេសសម្របសម្រួលដៃគូសន្ទនាអាស៊ាន-សហរដ្ឋអាម៉េរិក។

ពាក់ព័ន្ធនឹងបញ្ហាព្រំដែនកម្ពុជា-ថៃ **លោកស្រីភារធារីស្តីទី** បានលើកទឹកចិត្តឱ្យភាគីទាំងពីរដោះស្រាយជម្លោះដោយសន្តិវិធី និងត្រៀមខ្លួនរួចជាស្រេចក្នុងការចូលរួមជួយគាំទ្ររកដំណោះស្រាយ ប្រសិនបើមានសំណូមពរ។ ទន្ទឹមគ្នានេះ លោកស្រី បានចែករំលែកនូវការព្រួយបារម្ភអំពីបទល្មើសឆបោកអនឡាញ ដែលបានកើតឡើងនៅទូទាំងសកលលោក រួមទាំងតំបន់អាស៊ីអាគ្នេយ៍ ដែលបានបង្កផលប៉ះពាល់ដល់ពលរដ្ឋអាម៉េរិកនិងប្រជាជននៅលើសកលលោក។ លោកស្រី សង្ឃឹមថា កម្ពុជា និងសហរដ្ឋអាម៉េរិក នឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា ដើម្បីប្រយុទ្ធប្រឆាំងបទល្មើសឆបោកអនឡាញ ដែលជាក្តីកង្វល់រួម។

ជាការឆ្លើយតប **ឯកឧត្តមអនុប្រធានទី១** បានគូសបញ្ជាក់ថា ស្ថិតនៅចំពោះមុខការបង្កហេតុរំលោភបំពានមកលើអធិបតេយ្យនិងបូរណភាពដែនដីកម្ពុជា ភាគីកម្ពុជាបានប្រកាន់ជំហរអត់ធ្មត់មិនប្រើកម្លាំងតបតនិងស្វែងរកដោះស្រាយបញ្ហាដោយសន្តិវិធីតាមរយៈតុលាការយុត្តធម៌អន្តរជាតិ លើមូលដ្ឋានគោរពច្បាប់អន្តរជាតិ ធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន។ ឯកឧត្តម បានបន្ថែមថា គ្រប់ដំណើរការនៃការចរចាទ្វេភាគីកម្ពុជា-ថៃ និងចាប់ផ្តើមឡើងវិញ

នៅក្រោយពេលដែល ភាគីថៃបើកច្រកព្រំប្រទល់ឡើងវិញទាំងអស់ និងបានចោទសួរពីសុឆន្ទៈពិតប្រាកដរបស់ថៃក្នុងការដោះស្រាយបញ្ហាវិវាទព្រំប្រទល់រវាងប្រទេសទាំងពីរ តើហេតុអ្វីបានជាប្រទេសថៃខ្លាចរអាមិនហ៊ានទៅតុលាការយុត្តិធម៌អន្តរជាតិ។

**ឯកឧត្តមអនុប្រធានទី១** បានសង្កត់ធ្ងន់ពីសារៈសំខាន់នៃការគោរពឱ្យបានម៉ឺងម៉ាត់នូវលិខិតុបករណ៍គតិយុត្តជាពិសេស អនុសញ្ញារវាងបារាំងនិងសៀម ឆ្នាំ១៩០៤ សន្ធិសញ្ញាបារាំង-សៀម ឆ្នាំ១៩០៧ និង MOU រវាងកម្ពុជានិងថៃ ស្តីពីការវាស់វែង និងការបោះបង្គោលព្រំដែនគោក ឆ្នាំ២០០០ ដែលភាគីថៃខ្លួនឯងជាភាគីហត្ថលេខី ដែលនឹងនាំទៅរកដំណោះស្រាយមួយយូរអង្វែងជានិច្ចនិរន្តរ៍ ដើម្បីជាគុណប្រយោជន៍ដល់សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍសម្រាប់ប្រជាជនប្រទេសទាំងពីរ ( កម្ពុជា-ថៃ )។

ចំពោះបញ្ហាឆបោកតាមអនឡាញ **ឯកឧត្តមអនុប្រធានទី១** បានគូសបញ្ជាក់ថាកម្ពុជា ជាប្រទេសរងគ្រោះ ដោយសារបទល្មើសឆបោកតាមអនឡាញ ដែលកំពុងកើតមាននៅក្នុងបណ្តាប្រទេសជាច្រើននៅលើសកលលោក។ ប្រឈមមុខចំពោះបាតុភាពអសកម្មនៅក្នុងសង្គមនេះ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កាលពី ខែកុម្ភៈ កន្លងទៅនេះ បានប្រកាសដាក់ចេញនូវវិធានការដ៏មុតស្រួចមួយ ក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសឆបោកតាមអនឡាញនិងឧក្រិដ្ឋកម្មជួញដូរមនុស្សនៅកម្ពុជា ដោយបង្កើតឱ្យមានគណៈកម្មការមួយ ដែលដឹកនាំដោយ**សម្តេច**ផ្ទាល់ អមដោយឧបនាយករដ្ឋមន្ត្រីនិងក្រសួងស្ថាប័នពាក់ព័ន្ធ។ ឯកឧត្តម ក៏បានលើកជាអនុសាសន៍ថា ជាមួយនឹងការរឹតបន្តឹងការអនុវត្តច្បាប់ គួរតែបណ្តាប្រទេសដែលមានប្រជាជនរងគ្រោះ ខិតខំអប់រំនិងផ្សព្វផ្សាយអំពីល្បិចកល និងផលវិបាកនានា ឱ្យបានទូលំទូលាយដល់ប្រជាជនខ្លួន។

ជាការឆ្លើយតប លោកស្រី **ប្រែហ្គេត អែល ប៉័កឃីរ** បានសម្តែងនូវអំណរគុណចំពោះ **ឯកឧត្តមអនុប្រធានទី១** ដែលផ្តល់ឱកាសឱ្យលោកស្រី និងសហការី បានចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ។ លោកស្រីបានបង្ហាញពីការប្តេជ្ញាចិត្តរបស់សហរដ្ឋអាម៉េរិកនៅក្នុងការពង្រឹងនិងពង្រីកទំនាក់ទំនងទ្វេភាគីជាមួយកម្ពុជា ក៏ដូចជាអាស៊ាន ដែលក្នុងនោះលោកស្រីបានរំលេចថា ឯកឧត្តម **ម៉ាកូ រ៉ូប៊ីអូ** បានវាយតម្លៃខ្ពស់ចំពោះការចូលរួមនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន នាពេលកន្លងទៅ និងបានថ្លែងអំណរគុណកម្ពុជាសម្រាប់កិច្ចខិតខំប្រឹងប្រែងក្នុងនាមជាប្រទេសសម្របសម្រួលដៃគូសន្ទនាអាស៊ាន-សហរដ្ឋអាម៉េរិក។ លោកស្រី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការបកស្រាយបំភ្លឺរបស់ **ឯកឧត្តមអនុប្រធានទី១** អំពីបញ្ហាវិវាទព្រំដែនកម្ពុជា-ថៃ និងបានសម្តែងនូវក្តីសង្ឃឹមថា ភាគីទាំងពីរនឹងឆាប់រកបាននូវដំណោះស្រាយដោយសន្តិវិធីឱ្យបានឆាប់រហ័សនិងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងបទល្មើសឆបោកអនឡាញ ព្រមទាំងបានគូសបញ្ជាក់ពីការត្រៀមខ្លួនរបស់សហរដ្ឋអាម៉េរិក ក្នុងការសហការជាមួយកម្ពុជា សំដៅអនុវត្តកិច្ចការនេះឱ្យបានជោគជ័យ៕

ខ្លឹមសារ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា
រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបពិភាក្សាការងារ*

# ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញធ្វើបទអន្តរាគមន៍ក្រោមប្រធានបទ៖ «ហ្វ្រង់កូហ្វូនី ជាយុថ្កានៅក្នុងពិភពលោកមួយដែលកំពុងមានវិបត្តិ» នៅសភាប្រេីភាសាបារាំង





*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញធ្វើបទអន្តរាគមន៍ក្នុងសភាប្រេីភាសាបារាំង*

នៅសភាប្រេីភាសាបារាំង នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភាកម្ពុជា ប្រធានក្រុមសភាជាតិកម្ពុជា នៃសភាប្រេីភាសាបារាំង និងជាអនុប្រធានសភាប្រេីភាសាបារាំង បានជម្រាបដល់ប្រធាន សមាជិក សមាជិកា នៃសភាប្រេីភាសាបារាំងទាំងអស់ អំពីបញ្ហាប្រទេសថៃរំលោភដែនអធិបតេយ្យកម្ពុជា និងមិនគោរពចំពោះយុត្តាធិការតុលាការអន្តរជាតិ។

ក្នុងបទអន្តរាគមន៍ដែលមានរយៈពេល៣នាទី ក្រោមប្រធានបទ៖ «ហ្វ្រង់កូហ្វូនី ជាយុថ្កានៅក្នុងពិភពលោកមួយដែលកំពុងមានវិបត្តិ» **ឯកឧត្តមអនុប្រធានទី១** បានមានប្រសាសន៍ថា «នៅក្នុងបរិបទអន្តរជាតិដ៏ច្របូកច្របល់ដែលគោលការណ៍គ្រឹះនៃច្បាប់អន្តរជាតិត្រូវបានចោទសួរ ជាមួយនឹងភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយកំពុងតែកើនឡើងខ្លាំងនោះ អង្គការហ្វ្រង់កូហ្វូនីត្រូវតែដើរតួជាកម្លាំងស្ថិរភាពនិងជាត្រីវិស័យសីលធម៌ជាងពេលណាទាំងអស់»។

**ឯកឧត្តមអនុប្រធានទី១** បានសង្កត់ធ្ងន់ថា «បន្ទាប់ពីសកម្មភាពឈ្លានពានបង្កឡើងដោយកងទ័ពថៃ លើទឹកដីកម្ពុជាដែលត្រូវបានទទួលស្គាល់ដោយលិខិតុបករណ៍អន្តរជាតិ កាលពីថ្ងៃទី២៨ ខែឧសភាកន្លងទៅ ហើយដែលបានបណ្តាលឱ្យយោធាកម្ពុជាម្នាក់បាត់បង់ជីវិត ព្រះរាជាណាចក្រកម្ពុជាបានជ្រើសរើសផ្លូវច្បាប់ ដោយបានដាក់ពាក្យបណ្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិ ដើម្បីដោះស្រាយជម្លោះព្រំដែនដោយសន្តិវិធី ដែលពាក់ព័ន្ធតំបន់សេីបចំនួន៤។ ជាមួយគ្នានេះ កម្ពុជាក៏បានស្វែងរកការគាំទ្រពីប្រធានអាស៊ានផងដែរ។ ក៏ប៉ុន្តែ ភាគីថៃបានបដិសេធមិនទទួលស្គាល់យុត្តាធិការតុលាការយុត្តិធម៌អន្តរជាតិនោះទេ។ ការបដិសេធនេះធ្វើឱ្យមូលដ្ឋានគ្រឹះនៃច្បាប់អន្តរជាតិចុះខ្សោយនិងត្រូវបានចោទជាសំណួរដ៏សំខាន់មួយថា តើមានអ្នកណាដែលខ្លាចយុត្តិធម៌ ក្រៅតែពីអ្នកដែលភ័យខ្លាចចំពោះសច្ចភាពនៃច្បាប់នោះ?»

**ឯកឧត្តមអនុប្រធានទី១** បានគូសបញ្ជាក់បន្ថែមថា «យើងខ្ញុំមិនស្នើសុំឱ្យមានការថ្កោលទោសនោះទេ ប៉ុន្តែស្នើសុំការគាំទ្រយ៉ាងច្បាស់លាស់ចំពោះការគោរពច្បាប់រួម។ ក្នុងនាមជាសមាជិកនៃអង្គការហ្វ្រង់កូហ្វូនី យើងខ្ញុំសូមអះអាងជាថ្មីនូវការប្រកាន់ខ្ជាប់របស់យើងខ្ញុំចំពោះគោលការណ៍ដែលជាមូលដ្ឋានគ្រឹះនៃអង្គការនេះ គឺ៖ ច្បាប់ ការសន្ទនា និងសន្តិភាព។ យើងខ្ញុំសូមអំពាវនាវឱ្យមានការគាំទ្រច្បាស់លាស់ចំពោះការគោរពបទដ្ឋានរួមដែលជាមូលដ្ឋានគ្រឹះនៃសហប្រតិបត្តិការរបស់យើង»។

នៅទីបញ្ចប់នៃបទអន្តរាគមន៍ **ឯកឧត្តមអនុប្រធានទី១** បានស្នើឱ្យសភាប្រេីភាសាបារាំង «នៅតែជាសំឡេងដ៏មានឥទ្ធិពលនៅក្នុងពិភពលោកមួយដែលពោរពេញទៅដោយភាពមិនច្បាស់លាស់។ ជាសំឡេងមួយដែលនឹងគ្មានថ្ងៃនៅស្ងៀមស្ងាត់ ឬព្រងើយកន្តើយនោះឡើយ។ ជាសំឡេងដែលអះអាងថា ទោះបីស្ថិតនៅកណ្តាលវិបត្តិក៏ដោយ ក៏នៅតែមានគោលការណ៍ដែលមិនអាចចរចាបាន»៕

ប្រភព៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ



❈នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជួបសំណេះសំណាលជាមួយសមាជិក សមាជិកាក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ នៅសាលាខេត្តព្រះវិហារ។



❈នាថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចុះពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ ស្ថិតក្នុងភូមិម៉ឺនជ័យ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។



❈នារសៀលថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញក្នុងពិធីសូត្រមន្តបុណ្យគម្រប់ខួប១០ឆ្នាំនិង១៦ឆ្នាំនៃមរណភាពសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** និងលោកជំទាវ **ញ៉ែម សឿន** នៅភូមិកន្លែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។



❈នាព្រឹកថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមក្នុងពិធីសាសនាផ្សេងៗ រួមទាំងពិធីបង្សុកូលនិងរាប់បាត្រ ក្នុងពិធីបុណ្យគម្រប់ខួប១០ឆ្នាំនិង១៦ឆ្នាំនៃមរណភាពសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** និងលោកជំទាវ **ញ៉ែម សឿន** នៅភូមិកន្លែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។



❈នាព្រឹកថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញសំណេះសំណាលជាមួយសិស្ស និស្សិត និងលោកគ្រូ អ្នកគ្រូ នៃមជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាល ជា ស៊ីម កំចាយមារ ស្រុកកំចាយមារ ខេត្តព្រៃវែង។

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❋នាល្ងាចថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** បានអញ្ជើញរៀបចំពិធីបុណ្យគម្រប់ខួប១០០ថ្ងៃ ដើម្បីឧទ្ទិសមហាកុសលជូនវិញ្ញាណក្ខន្ធអ្នកឧកញ៉ាឧត្តមមេត្រីវិសិដ្ឋ **ហ៊ុន សាន** នៅរាជធានីភ្នំពេញ។



❋នាព្រឹកថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៥ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមបណ្ឌិត **ឆន់ ខឡុនា** អនុប្រធានទី២ និងសមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីបុណ្យរុក្ខទិវា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅកសិដ្ឋានផលិតពូជដំណាំតំបន់ដីខ្ពស់ចម្ការលើ ស្ថិតក្នុងភូមិកសិដ្ឋាន ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម។



❋នាព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យគណៈប្រតិភូចិន ដឹកនាំដោយលោក **ម៉ាស៊្វែ ចិន** នាយកប្រតិបត្តិសមាគមចិន សម្រាប់ការលើកកម្ពស់លទ្ធកម្មនៃអង្គការសហប្រជាជាតិ និងគណៈកម្មការសេដ្ឋកិច្ចពាណិជ្ជកម្មអាស៊ី-ប៉ាស៊ីហ្វិក (CAPUN-PAPETC) ចូលជួបសម្តែងការគួរសម នៅសាលពិសេសវិមានព្រឹទ្ធសភា។



❋នាថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងជាអនុប្រធានសភាប្រើភាសាបារាំង បានអញ្ជើញចូលរួមពិធីបើកផ្លូវការនៃសម័យប្រជុំប្រចាំឆ្នាំសភាប្រើភាសាបារាំង លើកទី៥០ នៅព្រឹទ្ធសភាបារាំង។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាថ្ងៃព្រហស្បតិ៍ទី១០ ខែកក្កដា ឆ្នាំ ២០២៥ ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភានិងជាអនុប្រធានសភាប្រើភាសាបារាំង បានអញ្ជើញជួបពិភាក្សាការងារជាមួយលោកស្រី Amélia Lakrafi សមាជិការដ្ឋសភាបារាំង និងជាអគ្គប្រតិភូសភាប្រើភាសាបារាំង នៅវិមានរដ្ឋសភាបារាំង។



❈នារសៀលថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភានិងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានអញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឡុនា** អនុប្រធានទី២ព្រឹទ្ធសភានិងជាប្រធានគណៈកម្មការពិសេសព្រឹទ្ធសភា បានដឹកនាំការប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅបន្ទប់ប្រជុំឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា។



❈នាថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឡុនា** អនុប្រធានទី២ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំប្រចាំខែរបស់ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា ដើម្បីពិនិត្យវឌ្ឍនភាពការងារនិងកំណត់ផែនការការងាររបស់ខុទ្ទកាល័យសម្រាប់ត្រីមាសខាងមុខ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ខឡុនា** អនុប្រធានទី២ព្រឹទ្ធសភា បានអនុញ្ញាតឱ្យគណៈប្រតិភូសមាគមកាហ្វេកម្ពុជា (Cambodia Coffee Association) ដឹកនាំដោយលោក **ឌុក ពិសិដ្ឋ** ចូលជួបសម្តែងការគួរសម និងគោរពសុំការណែនាំ លើទស្សនវិស័យអំពីអនាគតនៃឧស្សាហកម្មកាហ្វេនៅកម្ពុជា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នារសៀលថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំកិច្ចប្រជុំប្រចាំខែជាមួយប្រធានគណៈកម្មការទាំង១០ នៃព្រឹទ្ធសភា, ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨, ប្រធានក្រុមសមាជិកា និងប្រធានគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំមកពីសាកលវិទ្យាល័យជាតិ និងគ្រឹះស្ថានឧត្តមសិក្សាចំនួន ២០ ទូទាំងប្រទេសកម្ពុជា តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សមាគមកាហ្វេ និងវិស័យឯកជន សរុបចំនួន១២០នាក់ ដើម្បីពិភាក្សាអំពីការជំរុញការផលិតអាហារកែច្នៃនៅកម្ពុជា សេវាកម្ម និងការបង្កើតទីផ្សារសម្រាប់លក់ផលិតផលខ្មែរ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីថ្លែងសុន្ទរកថាគន្លឹះក្នុងកម្មវិធីផ្សព្វផ្សាយសៀវភៅ «ទិនានុប្បវត្តិលេខ៨ និងវេទិកាពិភាក្សាលើការស្រាវជ្រាវអំពីមហាតំបន់ទន្លេមេគង្គ» របស់វិទ្យាស្ថានខ្មែរសម្រាប់សហប្រតិបត្តិការនិងសន្តិភាព (CICP) នៅ Raffles Hotel Le Royal Phnom Penh។




❈នាព្រឹកថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បានអញ្ជើញថ្លែងសុន្ទរកថាបិទកិច្ចប្រជុំក្រុមអ្នកនយោបាយអន្តរសភាអាស៊ានលើកទី១៦ (The 16th AIPA Caucus) នៅវិមានរដ្ឋសភា។



# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ថាវឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីក្នុងពិធីចែកវិញ្ញាបនបត្រសម្គាល់អចលនវត្ថុតាមគោលការណ៍ ប្រទានកម្មរបស់រាជរដ្ឋាភិបាល ជូនវិទ្យាស្ថានជាតិកសិកម្មព្រែកលាប និងប្រជាពលរដ្ឋ៥១គ្រួសារ ក្នុងសហគមន៍ព្រែកខ្ចិត ស្ថិតក្នុងភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ។




❈នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ថាវឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ និងឯកឧត្តម លោកជំទាវ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានអញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់៧ថ្ងៃ លោក **សួន វាសនារិទ្ធិសក្តិ** ចៅរបស់ឯកឧត្តម **ង៉ែត ចន្ថាវី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា និងជាសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ នៅសង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។




❈នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ថាវឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងជាប្រធានគណៈកម្មការពិសេសព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការពិសេសព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាលើសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងឯកសារពាក់ព័ន្ធ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។



❈នារសៀលថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ឆន់ ថាវឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ បានដឹកនាំកិច្ចប្រជុំជាមួយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ ដើម្បីរៀបចំដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តពិនិត្យជំងឺជូនប្រជាពលរដ្ឋនិងរៀបចំកិច្ចសំណេះសំណាល ព្រមទាំងវេទិកាជាមួយអង្គបោះឆ្នោត នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា៕



# គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយអាជ្ញាធរ ខេត្តកំពង់ស្ពឺ ខេត្តកោះកុង និងមន្ទីរជំនាញពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់ខ្លួន

គណៈប្រតិភូគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ នៃព្រឹទ្ធសភា (គណៈកម្មការទី៧) ដឹកនាំដោយឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការទី៧ព្រឹទ្ធសភា នៅខេត្តកំពង់ស្ពឺ និងខេត្តកោះកុង កាលពីថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥។




*គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តកំពង់ស្ពឺ*

ក្នុងឱកាសជំនួបជាច់ដោយឡែករវាងខេត្តទាំងពីរនោះ តាងនាមឱ្យគណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា ឯកឧត្តម **ឈិត សុខុន** បានមានប្រសាសន៍ពាំនាំផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ និងឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា ជូនចំពោះថ្នាក់ដឹកនាំខេត្ត និងមន្ទីរជំនាញជុំវិញខេត្ត ព្រមទាំងបងប្អូនប្រជាពលរដ្ឋទូទាំងខេត្ត។

ឯកឧត្តម **ឈិត សុខុន** បានជម្រាបអំពីគោលបំណងនៃជំនួបពិភាក្សា គឺដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម វិធានការ និងចក្ខុវិស័យទៅមុខរបស់អាជ្ញាធរខេត្ត ពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការទី៧ព្រឹទ្ធសភា ព្រមទាំងជម្រាបជូនអំពី តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា។

បន្ទាប់ពីអាជ្ញាធរខេត្តទាំងពីរធ្វើសេចក្តីរាយការណ៍ដោយសង្ខេបអំពី វឌ្ឍនភាពការងារ បញ្ហាប្រឈម វិធានការដោះស្រាយ ដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការទី៧ព្រឹទ្ធសភារួចមក ឯកឧត្តម **ឈិត សុខុន** បានកោតសរសើរចំពោះថ្នាក់ដឹកនាំខេត្តទាំងពីរនិងមន្ទីរជំនាញពាក់ព័ន្ធជុំវិញខេត្ត ដែលបានខិតខំបំពេញតួនាទី ភារកិច្ចបានយ៉ាងល្អប្រសើរក្នុងការរួមចំណែកធ្វើឱ្យខេត្តនីមួយៗ ក្នុងចំណោមខេត្តបួនជាប់មាត់សមុទ្រ ដែលស្ថិតនៅប៉ែកនិរតីនៃប្រទេសកម្ពុជា ដែលមានធនធានធម្មជាតិនិងជីវចម្រុះដ៏សម្បូរបែប ទាក់ទាញអ្នកវិនិយោគជាច្រើនមកបណ្តាក់ទុនវិនិយោគជាពិសេសលើវិស័យទេសចរណ៍ ដែលជាកត្តាធ្វើឱ្យមានអាត្រាកំណើនការងារកាន់តែខ្ពស់ ប្រជាពលរដ្ឋមានជីវភាពល្អ




*គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តកោះកុង*





*គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំក្នុងស្រុកមណ្ឌលសីមា ខេត្តកោះកុង*

ប្រសើរ ហេតុនេះ សូមអាជ្ញាធរខេត្តបន្តរួមគ្នាថែរក្សាធនធានធម្មជាតិ ជីវចម្រុះដ៏សម្បូរបែប ដើម្បីបរិស្ថាន និងការអភិវឌ្ឍនូវសមិទ្ធផលនិងស្នាដៃថ្មីៗបន្ថែមទៀត។ ទន្ទឹមគ្នានេះ សូមថ្នាក់ដឹកនាំខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធ បន្តរួមគ្នាខិតខំដោះស្រាយបញ្ហាប្រឈមនិងសំណូមពរនានាដែលនៅសេសសល់ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្លួន ជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលានិងកាន់តែល្អប្រសើរថែមទៀត។

**ឯកឧត្តមប្រធានគណៈកម្មការ** បានជំរុញឱ្យអាជ្ញាធរទាំងអស់ត្រូវបន្តខិតខំឆ្ពោះទៅមុខជានិច្ច ដើម្បីភាពរីកចម្រើននិងបន្តពង្រឹងការអនុវត្តគោលនយោបាយភូមិឃុំ សង្កាត់មានសុវត្ថិភាពយ៉ាងខ្ជាប់ខ្ជួន បង្ការទប់ស្កាត់និងបង្ក្រាបបទល្មើសនានា ថែរក្សាសន្តិភាព ស្ថិរភាពនយោបាយសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងការអភិវឌ្ឍខេត្តឱ្យកាន់តែរីកចម្រើន ស្របតាមកម្មវិធីនយោបាយយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ ក្នុងការជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារ ធានាសមធម៌ បង្កើនប្រសិទ្ធភាព និងចីរភាពសំដៅឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ជាប្រទេសដែលមានចំណូលខ្ពស់។

**ឯកឧត្តមប្រធានគណៈកម្មការ** បានគូសបញ្ជាក់អំពីចំណុចសំខាន់ៗដែលពាក់ព័ន្ធនឹងមន្ទីរជំនាញក្នុងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការទី៧ព្រឹទ្ធសភា រួមមាន៖

១-វិស័យអប់រំ យុវជន និងកីឡា ដែលជាវិស័យគន្លឹះ នៃការអភិវឌ្ឍជាតិ ជាវិស័យអាទិភាពរបស់ជាតិ។

២-វិស័យធម្មការ និងសាសនា ដែលជាកម្លាំងដែលមិនចេះរីងស្ងួតរបស់ប្រទេសនីមួយៗ យើងត្រូវចេះទាញផលប្រយោជន៍ពីកម្លាំងនេះ ដើម្បីអភិវឌ្ឍប្រទេសជាតិ។

៣-វិស័យវប្បធម៌ និងវិចិត្រសិល្បៈ ពីព្រោះវប្បធម៌ជាព្រលឹងជាតិ ជាអត្តសញ្ញាណជាតិ ដែលកំណត់ភាពខុសប្លែកគ្នាពីប្រទេសមួយទៅប្រទេសមួយ ជាស៊ីម៉ងត៍ផ្សារភ្ជាប់សង្គម ជាកិត្យានុភាពជាតិ ជាកត្តាឯកភាពជាតិ និងសុខដុមនីយកម្មសង្គម។

៤-វិស័យទេសចរណ៍ គឺជាឧស្សាហកម្មគ្មានផ្សែង ជាកត្តាសេដ្ឋកិច្ច ដែលប្រទេសណាក៏អាចធ្វើទេសចរណ៍បានដែរ ដូច្នេះត្រូវតែបន្តរៀបចំនិងរកចំណុចពិសេស ដើម្បីទាញផលប្រយោជន៍សេដ្ឋកិច្ចពីទេសចរណ៍សម្រាប់អភិវឌ្ឍប្រទេសជាតិ។

ក្រៅពីជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តទាំងពីរ គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខក្រុមប្រឹក្សាឃុំប៉ាក់ខ្លង ឃុំពាមក្រសោប និងឃុំទួលគគីរ នៃស្រុកមណ្ឌលសីមា ខេត្តកោះកុង ដើម្បីជម្រាបជូនអំពី តួនាទីភារកិច្ចរបស់ព្រឹទ្ធសភា ការផ្តល់សេវាសាធារណៈ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព នៅសាលាស្រុកមណ្ឌលសីមា៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយក្រុមប្រឹក្សាឃុំក្នុងស្រុកមណ្ឌលសីមា ខេត្តកោះកុង*

# គណៈកម្មការទី១០ព្រឹទ្ធសភា ឈ្វេងយល់អំពីការអនុវត្តច្បាប់ពាក់ព័ន្ធនឹង វិស័យជាសមត្ថកិច្ចរបស់ខ្លួន នៅខេត្តស្ទឹងត្រែង ព្រះវិហារ និងខេត្តឧត្តរមានជ័យ

ក្នុងចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ ព្រឹទ្ធសភានីតិកាលទី៥ គណៈប្រតិភូគណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ នៃព្រឹទ្ធសភា (គណៈកម្មការទី១០) ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ និងឈ្វេងយល់អំពី ប្រសិទ្ធភាព និងបញ្ហាប្រឈមនៃការអនុវត្តច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ និងការអភិវឌ្ឍមូលដ្ឋាន នៅខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ ពីថ្ងៃទី២០ ដល់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥។



*ឯកឧត្តម ម៉ម ប៊ុននាង ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា*

ក្នុងឱកាសចុះបំពេញបេសកកម្មទៅកាន់ខេត្តទាំងបី គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងពិភាក្សាការងារដាច់ដោយឡែកពីគ្នា ជាមួយរដ្ឋបាលខេត្តស្ទឹងត្រែង ដឹកនាំដោយឯកឧត្តម **សរ សុពុទ្រា** អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង, រដ្ឋបាលខេត្តព្រះវិហារ ដឹកនាំដោយឯកឧត្តម **គីម រិទ្ធី** អភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ និងរដ្ឋបាលខេត្តឧត្តរមានជ័យ ដឹកនាំដោយឯកឧត្តម **ស៊ឹម ឧទ្ធា** អភិបាលរងនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ដោយមានការចូលរួមពីក្រុមប្រឹក្សាខេត្ត កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ រួមជាមួយនឹងប្រធានមន្ទីរនិងអង្គភាពនានាជុំវិញខេត្ត។

មានប្រសាសន៍សំណេះសំណាលក្នុងខេត្តនីមួយៗ ឯកឧត្តម **ម៉ម ប៊ុននាង** បានពាំនាំនូវការផ្តាំផ្ញើនូវការសាកសួរសុខទុក្ខ ប្រកបដោយសេចក្តីនឹករលឹកពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនដល់ថ្នាក់ដឹកនាំរដ្ឋបាលខេត្ត ព្រមទាំងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់និងប្រជាពលរដ្ឋ។

**ឯកឧត្តមប្រធាន** បានជម្រាបជូនអង្គប្រជុំអំពីសមិទ្ធផលនានារបស់ព្រឹទ្ធសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតខ្ពស់របស់ **សម្តេចតេជោប្រធានព្រឹទ្ធសភា** តាមរយៈការអនុវត្តការងារជាអាទិភាពចម្បងចំនួនពីរគឺៈ ទី១-ការលើកកម្ពស់ការទូតសភា និងទី២-ការជួបប្រាស្រ័យឱ្យកាន់តែជិតស្និទ្ធជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ បន្ថែមពីលើការអនុវត្តមុខងារស្នូលទាំងបីរបស់ព្រឹទ្ធសភា គឺមុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង។

នៅក្នុងឱកាសនោះ ថ្នាក់ដឹកនាំខេត្តទាំងបីបានធ្វើសេចក្តីរាយការណ៍អំពីលក្ខណៈភូមិសាស្ត្រ ប្រជាសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធ សក្តានុពលផ្នែកកសិកម្ម ឧស្សាហកម្ម សេវាកម្ម សុខាភិបាល អប់រំ ទេសចរណ៍ និងវិនិយោគ ជាពិសេស វឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ និងការអភិវឌ្ឍមូលដ្ឋាន។





*គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តស្ទឹងត្រែង*





*គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា ជួបពិភាក្សាការងារមួយអាជ្ញាធរខេត្តព្រះវិហារ*

ពាក់ព័ន្ធនឹងការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ ថ្នាក់ដឹកនាំខេត្តទាំងបីបានគូសបញ្ជាក់ថា រដ្ឋបាលខេត្តបានសហការនិងចូលរួមចំណែកផ្សព្វផ្សាយនូវខ្លឹមសារច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយយ៉ាងទូលំទូលាយ, បានលើកទឹកចិត្តឱ្យគ្រប់មន្ទីរ អង្គភាពដាក់តាំងនូវបដាពាក្យស្លោក ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងអំពើពុករលួយ, បានធ្វើការអប់រំផ្សព្វផ្សាយខ្លឹមសារនៃច្បាប់ប្រឆាំងអំពើពុករលួយតាមទូរទស្សន៍ វិទ្យុ និងបណ្តាញផ្សព្វផ្សាយសង្គមផ្លូវការ, បានរៀបចំឱ្យមានប្រអប់សំបុត្រ ដើម្បីទទួលនូវសំណូមពរ កង្វល់ និងបណ្តឹងនានាពីសាធារណជន នៅតាមទីសាធារណៈនិងតាមទីតាំងខាងមុខមន្ទីរ អង្គភាពជុំវិញខេត្ត ព្រមទាំងបានលើកទឹកចិត្តនិងជំរុញមន្ត្រីដែលជាប់កាតព្វកិច្ចធ្វើការប្រកាសទ្រព្យសម្បត្តិ និងបំណុលតាមការកំណត់នៃច្បាប់ ដោយមានជនបង្គោលប្រឆាំងអំពើពុករលួយ និងមន្ត្រីជំនាញថ្នាក់ខេត្តជាអ្នកសម្របសម្រួល។

បន្ទាប់ពីបានស្តាប់របាយការណ៍ និងពិភាក្សាគ្នាយ៉ាងល្អិតល្អន់ **ឯកឧត្តមប្រធានគណៈកម្មការ**បានវាយតម្លៃខ្ពស់ចំពោះប្រសិទ្ធភាពការងារ ក្រោមការដឹកនាំរបស់**ឯកឧត្តមអភិបាលខេត្ត ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត** មន្ទីរជំនាញ និងដោយមានការចូលរួមយ៉ាងសស្រាក់សស្រាំពីសំណាក់មន្ត្រីគ្រប់ជាន់ថ្នាក់និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ បានធ្វើឱ្យខេត្តទាំងបីមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ការអនុវត្តច្បាប់កាន់តែមានប្រសិទ្ធភាព ប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខសាន្ត ស្របតាមកម្មវិធីនយោបាយនិងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា។

**ឯកឧត្តមប្រធាន** បានលើកទឹកចិត្តដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ឱ្យបន្តអប់រំនិងផ្សព្វផ្សាយច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយឱ្យបានកាន់តែទូលំទូលាយ ហើយត្រូវនៅឱ្យឆ្ងាយពីអំពើពុករលួយ គោរពច្បាប់ឱ្យបានខ្ជាប់ខ្ជួន និងអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួនឱ្យបានល្អប្រសើរ ជាពិសេស គឺការផ្តល់សេវាសាធារណៈ ជូនដល់ប្រជាពលរដ្ឋប្រកបដោយតម្លាភាព ប្រសិទ្ធភាព គណនេយ្យភាព និងសមធម៌ សំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរ និងត្រូវរួមគ្នាបង្កើតមជ្ឈដ្ឋានមួយដែលធ្វើឱ្យមនុស្សម្នាក់មិនចង់ពុករលួយ មិនអាចពុករលួយ និងមិនហ៊ានពុករលួយ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*គណៈប្រតិភូគណៈកម្មការទី១០ព្រឹទ្ធសភា ជួបពិភាក្សាការងារ និងថតរូបអនុស្សាវរីយ៍មួយអាជ្ញាធរខេត្តស្ទឹងត្រែង*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ សំណេះសំណាលជាមួយ ក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ និងអាជ្ញាធរស្រុកស្រីស្នំ

នាព្រឹកថ្ងៃចន្ទ ទី២១ ខែកក្កដា ឆ្នាំ២០២៥ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ (ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងខេត្តប៉ៃលិន) ដឹកនាំដោយឯកឧត្តម **ប៉ុល លឹម** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ និងអាជ្ញាធរស្រុកស្រីស្នំ នៅសាលាស្រុកស្រីស្នំ ខេត្តសៀមរាប ដោយមានអ្នកចូលរួមសរុបចំនួន៩៦នាក់។



*ឯកឧត្តម ប៉ុល លឹម ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤*

ក្នុងឱកាសនោះ ឯកឧត្តម **ប៉ុល លឹម** បាននាំប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភាជូនអាជ្ញាធរស្រុក ក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំទាំងអស់ ព្រមទាំងបានគូសបញ្ជាក់អំពីគោលបំណងនៃពិធីសំណេះសំណាល គឺដើម្បីឈ្វេងយល់ និងផ្តល់ឱកាសជូនសមាជិកក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ បានលើកឡើងពីបញ្ហាប្រឈម កង្វល់ តម្រូវការ និងសំណូមពរ ជុំវិញការអនុវត្តតួនាទីភារកិច្ចក្នុងការអនុវត្តច្បាប់ ដោយផ្តោតសំខាន់ទៅលើការផ្តល់សេវាសាធារណៈ រួមមាន៖ **១**-ការងារស្ថិតិប្រជាពលរដ្ឋ **២**-ការងារអត្រានុកូលដ្ឋាននិងការកែតម្រូវអក្ខរាវិរុទ្ធ **៣**-ការងារធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ **៤**-ការងារមូលនិធិអភិវឌ្ឍន៍ឃុំ **៥**-ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពមាន៧ចំណុច និង**៦**-បញ្ហាផ្សេងៗ។

បន្ទាប់ពីលោកអភិបាលស្រុកស្រីស្នំ ឡើងមានមតិស្វាគមន៍និងរាយការណ៍អំពីស្ថានភាពភូមិសាស្ត្រ ស្ថានភាពរដ្ឋបាល ការងារដឹកនាំគ្រប់គ្រង វិធានការនៃការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ការផ្តល់សេវាសាធារណៈនិងសេវារដ្ឋបាលជូនប្រជាពលរដ្ឋ ការងារអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការពិភាក្សាផ្លាស់ប្តូរបទពិសោធគ្នាយ៉ាងផុលផុសរួចមក ឯកឧត្តម **ប៉ុល លឹម** បានថ្លែងនូវការកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះ





*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ សំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ និងអាជ្ញាធរស្រុកស្រីស្នំ*




*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ និងអាជ្ញាធរស្រុកស្រីស្នំ*

ថ្នាក់ដឹកនាំស្រុក និងក្រុមប្រឹក្សាឃុំ ស្មៀន នាយប៉ុស្តិ៍នគរបាលឃុំ ដែលបានខិតខំបំពេញតួនាទី ភារកិច្ចរបស់ខ្លួនយ៉ាងល្អប្រសើរ ជាពិសេសការងារដែលពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាល អត្រានុកូលដ្ឋាន ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ការអភិវឌ្ឍឃុំ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព។

ឯកឧត្តម **ម៉ុល លឹម** បានវាយតម្លៃខ្ពស់និងថ្លែងអំណរគុណចំពោះក្រុមប្រឹក្សាឃុំ ស្មៀន នាយប៉ុស្តិ៍នគរបាលឃុំ ដែលបានលើកឡើងនូវបញ្ហាប្រឈម សំណូមពរ និងចំណុចល្អៗជាច្រើន ជាព័ត៌មានដ៏ល្អ ដែលបានឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការរួមគ្នាប្រមូលគំនិត មតិយោបល់ បទពិសោធល្អៗដ៏មានតម្លៃ សម្រាប់ជាគុណប្រយោជន៍ក្នុងការបំពេញការងាររបស់យើងឱ្យកាន់តែល្អប្រសើរថែមទៀត។

ឯកឧត្តម **ម៉ុល លឹម** សង្ឃឹមយ៉ាងមុតមាំថា ថ្នាក់ដឹកនាំស្រុក អង្គភាពពាក់ព័ន្ធ និងសមាជិកក្រុមប្រឹក្សាឃុំ នឹងនាំយកចំណេះដឹង បទពិសោធល្អៗ ដែលទទួលបានពីពិធីសំណេះសំណាលនេះ ទៅចែករំលែកនិងខិតខំបំពេញតួនាទី ភារកិច្ចរបស់ខ្លួនជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានឱ្យកាន់តែប្រសើរ។ ជាមួយគ្នានោះ **ឯកឧត្តម**បានលើកទឹកចិត្តដល់រដ្ឋបាលស្រុក និងក្រុមប្រឹក្សាឃុំទាំងអស់ ឱ្យបន្តខិតខំលើកកម្ពស់ការបំពេញតួនាទី ភារកិច្ចរបស់ខ្លួនទៅតាមច្បាប់ បទដ្ឋានគតិយុត្តិនានានិងសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ព្រមទាំងលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយតម្លាភាព និងគណនេយ្យភាព ក្នុងនាមជាអ្នកបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋយ៉ាងពិតប្រាកដ។ ចំពោះបញ្ហាប្រឈម និងសំណូមពរនានា ដែលអាជ្ញាធរស្រុក ក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ បានលើកឡើង ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ នឹងរាយការណ៍ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីលើកជាអនុសាសន៍ជម្រាបដល់ក្រសួង ស្ថាប័នពាក់ព័ន្ធធ្វើការដោះស្រាយ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ថតរូបអនុស្សាវរីយ៍ជាមួយក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ និងអាជ្ញាធរស្រុកស្រីស្នំ*

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ សំណេះសំណាលជាមួយ អាជ្ញាធរស្រុកគិរីវង់ និងស្រុកទ្រាំង ខេត្តតាកែវ

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ (ខេត្តកំពត ខេត្តតាកែវ និងខេត្តកែប) ដឹកនាំដោយឯកឧត្តម **ឈួន ឆាម** ប្រធានស្តីទីក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បានអញ្ជើញជួបសំណេះសំណាលដាច់ដោយឡែកពីគ្នា ជាមួយថ្នាក់ដឹកនាំស្រុក ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ នៅស្រុកគិរីវង់ និងស្រុកទ្រាំង ខេត្តតាកែវ នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៥។



*ឯកឧត្តម ឈួន ឆាម ប្រធានស្តីទីក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥*

សូមជម្រាបថា ពិធីសំណេះសំណាលនេះ រៀបចំឡើងដើម្បីផ្សារភ្ជាប់ និងរួមប្រាស្រ័យទាក់ទងឱ្យកាន់តែជិតស្និទ្ធជាមួយអង្គបោះឆ្នោត ដែលជាសមាជិកក្រុមប្រឹក្សាឃុំ ព្រមទាំងឈ្វេងយល់ និងពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ រួមជាមួយនឹងការចូលរួមដោះស្រាយ នាំយកយោបល់ សំណូមពរ ឬបញ្ហាប្រឈមនានារបស់ក្រុមប្រឹក្សាឃុំ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។

នៅក្នុងឱកាសនោះ ឯកឧត្តម **ឈួន ឆាម** បានពាំនាំនូវការផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនចំពោះបងប្អូនប្រជាពលរដ្ឋ ថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការ និងកងកម្លាំងនៅមូលដ្ឋានគ្រប់លំដាប់ថ្នាក់ក្នុងខេត្តតាកែវ ប្រកបដោយក្តីនឹករលឹកបំផុត។ **ឯកឧត្តម**ក៏បានជម្រាបជូនអង្គពិធីអំពីតួនាទី ភារកិច្ច រចនាសម្ព័ន្ធរបស់ព្រឹទ្ធសភា ព្រមទាំងវឌ្ឍនភាពការងាររបស់ព្រឹទ្ធសភានីតិកាលទី៥។

**ឯកឧត្តមប្រធានស្តីទី** បានវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ក្នុងការបម្រើសេវាជូនប្រជាពលរដ្ឋក្នុងមូលដ្ឋានកន្លងទៅ ព្រមទាំងបានថ្លែងអំណរគុណចំពោះការសហការប្រឹងប្រែងរួមគ្នាដោះស្រាយបញ្ហាប្រឈមនិងសំណូមពរជូនប្រជាពលរដ្ឋ បានយ៉ាងល្អប្រសើរ ដោយរក្សាបាននូវសន្តិសុខ ស្ថិរភាព សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមក្នុងមូលដ្ឋាន។




*អាជ្ញាធរស្រុកគិរីវង់ ខេត្តតាកែវ ចូលរួមក្នុងពិធីសំណេះសំណាល*





*អាជ្ញាធរស្រុកទ្រាំង ខេត្តតាកែវ ចូលរួមក្នុងពិធីសំណេះសំណាល*

**ឯកឧត្តមប្រធានស្ដីទី** បានផ្តាំផ្ញើនិងសំណូមពរដល់ថ្នាក់ដឹកនាំស្រុក ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ នៃស្រុកទាំងពីរ សូមបន្តយកចិត្តទុកដាក់អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវកិច្ចការមួយចំនួនដូចជា៖ ១-បន្តរួមចំណែកថែរក្សាការពារសន្តិភាព ដែលជាកត្តាគន្លឹះនៅក្នុងការអភិវឌ្ឍប្រទេសជាតិ ដោយខិតខំប្រឹងប្រែងអនុវត្តតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាល ២-បន្តបម្រើមូលដ្ឋានរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពតាមរយៈការយកចិត្តទុកដាក់ខ្ពស់លើការបន្តអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ៣-បន្តលើកកម្ពស់ការផ្តល់សេវាសាធារណៈផ្សេងៗឱ្យមានប្រសិទ្ធភាពខ្ពស់ និងពង្រឹងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យបានល្អប្រសើរឡើងជាលំដាប់ ៤-រួមគ្នាលើកកម្ពស់ការផ្តល់សេវាសុខុមាលភាពនិងការអប់រំដល់ប្រជាពលរដ្ឋ ដែលកត្តាសុខភាពគឺត្រូវការអាហារូបត្ថម្ភជាចម្បង ចំណែកការអប់រំត្រូវការបង្កើនចំណេះផ្នែកភាសាអង់គ្លេស និងបច្ចេកវិទ្យា។

នៅក្នុងឱកាសនោះផងដែរ **ឯកឧត្តមប្រធានស្ដីទី** ក៏បានជម្រាបអំពី ស្ថានការណ៍នៃជម្លោះព្រំដែនកម្ពុជា-ថៃ ព្រមទាំងជំហរយ៉ាងម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរក្សាសុខសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍជាមួយប្រទេសជិតខាង ប៉ុន្តែប្តេជ្ញាដាច់ខាតការពារបូរណភាពទឹកដីមិនឱ្យបរទេសណាឈ្លានពានបានឡើយ។ ចំពោះតំបន់ជម្លោះទាំងបួន រួមមាន ប្រាសាទតាមាន់ធំ ប្រាសាទតាមាន់តូច ប្រាសាទតាក្របី និងតំបន់មុំបី ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា សម្រេចបញ្ជូនសំណុំរឿងទៅតុលាការយុត្តិធម៌អន្តរជាតិ (ICJ) ដើម្បីដោះស្រាយដោយសន្តិវិធី៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ សំណេះសំណាល និងថតរូបអនុស្សាវរីយ៍ជាមួយអាជ្ញាធរស្រុកទ្រាំង ខេត្តតាកែវ*

# ក្រុមសមាជិកាព្រឹទ្ធសភា សំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀន ក្នុងភូមិភាគទី៧

ដើម្បីពង្រឹងពង្រីកការអនុវត្តមុខងារតំណាងឱ្យមានគុណភាព តម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាព ក្រុមសមាជិកាព្រឹទ្ធសភាបានចែកគ្នាជាបីក្រុម ដើម្បីចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀន ក្នុងភូមិភាគទី៧ រួមមានខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កោះកុង និងខេត្តព្រះសីហនុ ដើម្បីពិគ្រោះយោបល់ ស្វែងយល់អំពីតម្រូវការ បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ពីថ្ងៃទី៧ ដល់ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥។




*ក្រុមសមាជិកាព្រឹទ្ធសភា សំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំជាស្ត្រី នៅក្នុងស្រុកកំពង់ត្រឡាច ស្រុកសាមគ្គីមានជ័យ និងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង*

ក្រុមសមាជិកាព្រឹទ្ធសភាទាំងបីក្រុមនោះ រួមមាន៖

- ក្រុមទី១ ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភាអញ្ជើញចុះទៅកាន់ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តកោះកុង។
- ក្រុមទី២ ដឹកនាំដោយលោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** អនុប្រធានក្រុមសមាជិកាព្រឹទ្ធសភាអញ្ជើញចុះទៅកាន់ខេត្តកំពង់ស្ពឺ និងខេត្តកោះកុង។
- ក្រុមទី៣ ដឹកនាំដោយលោកជំទាវ **ឃួន ឃុនឌី** លេខាធិការក្រុមសមាជិកាព្រឹទ្ធសភាអញ្ជើញចុះទៅកាន់ខេត្តព្រះសីហនុ និងខេត្តកោះកុង។




*ក្រុមសមាជិកាព្រឹទ្ធសភា សំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំជាស្ត្រី នៃស្រុកសំរោងទង និងស្រុកសាមគ្គីមុនីជ័យ ខេត្តកំពង់ស្ពឺ*

ក្នុងឱកាសចុះជួបសំណេះសំណាលដាច់ដោយឡែកពីគ្នា ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀន ក្នុងខេត្តនីមួយៗ ក្រុមសមាជិកាព្រឹទ្ធសភា បាននាំប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀន ប្រកបដោយក្តីនឹករលឹក។

ក្រុមសមាជិកាព្រឹទ្ធសភាបានជម្រាបអំពីសមិទ្ធផលរបស់ព្រឹទ្ធសភា នីតិកាលទី៥ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដែលបានដាក់ចេញនូវការងារជាអាទិភាពចម្បងចំនួនពីរ គឺទី**១**-ការលើកកម្ពស់ការទូតសភា និងទី**២**-ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គបោះឆ្នោត ជាពិសេសជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាតំណាងឱ្យប្រជាពលរដ្ឋនៅមូលដ្ឋាន។ បន្ថែមពីលើមុខងារស្នូលទាំងបីរបស់ព្រឹទ្ធសភា គឺមុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង។

ក្រុមសមាជិកាព្រឹទ្ធសភាក៏បានជម្រាបជូនផងដែរ អំពីសភាពការណ៍ធំៗ ដែលបាននិងកំពុងកើតមាននាពេលបច្ចុប្បន្ននេះ ដូចជា កាលពីពេលថ្មីៗនេះ រដ្ឋសភានិងព្រឹទ្ធសភា បានប្រជុំសមាជរដ្ឋសភានិងព្រឹទ្ធសភា ដោយបានសម្រេចលទ្ធផលគួរជាទីមោទនៈ ក្នុងការលើកកម្ពស់ឧត្តមប្រយោជន៍របស់ជាតិនិងប្រជាពលរដ្ឋ។ ក្នុងនោះ អង្គសមាជបានពិភាក្សាផ្តល់យោបល់លើប្រធានបទចំនួនបី រួមមាន៖ **១**-ប្រធានបទស្តីពី ប្រព័ន្ធគាំពារសង្គម **២**-ប្រធានបទស្តីពី សេដ្ឋកិច្ចក្រៅប្រព័ន្ធ និង**៣**-ប្រធានបទស្តីពីវិស័យកសិកម្ម ដោយបានអនុម័តចេញសេចក្តីសម្រេចចំនួនបី ទាក់ទងនឹងប្រធានបទទាំងបី ទុកជា




*ក្រុមសមាជិកាព្រឹទ្ធសភា សំណេះសំណាលជាមួយ*
*ក្រុមប្រឹក្សាឃុំ សង្កាត់ មកពីស្រុកស្ទឹងហាវ និងក្រុងព្រះសីហនុ*

ឯកសារគតិយុត្ត មានតម្លៃខ្ពស់បំផុតក្នុងការគាំទ្រលើកកម្ពស់ប្រសិទ្ធភាព ការអនុវត្តយុទ្ធសាស្ត្រគោលនយោបាយរបស់រាជរដ្ឋាភិបាលសម្រេចបាននូវចក្ខុវិស័យអភិវឌ្ឍន៍ជាតិ ឆ្នាំ២០៣០ និងឆ្នាំ២០៥០។ ជាមួយគ្នានោះ នាពេលខាងមុខរដ្ឋសភានិងព្រឹទ្ធសភា នឹងប្រជុំពិនិត្យពិភាក្សាលើសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបើកផ្លូវអនុញ្ញាតឱ្យមានការរៀបចំក្របខ័ណ្ឌច្បាប់ សម្រាប់ការដកសញ្ជាតិខ្មែរ ចំពោះពលរដ្ឋខ្មែរណាដែលបានប្រព្រឹត្តអំពើក្បត់ជាតិ ឬការធ្វើសកម្មភាពប៉ះពាល់ធ្ងន់ធ្ងរដល់ផលប្រយោជន៍ នៃព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋខ្មែរដោយគប់គិតជាមួយបរទេស។

បន្ថែមពីនេះ ក្រុមសមាជិកាព្រឹទ្ធសភាបានជម្រាបអំពីមូលហេតុនិងសាវតារ នៃជម្លោះព្រំដែនកម្ពុជា-ថៃ ដែលចាប់ផ្តើមឡើងដោយការគូរផែនទីជាឯកតោភាគីរបស់ថៃ ការចូលមកបាញ់សម្លាប់ទាហានខ្មែរយើង កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ និងការសម្រេចបិទព្រំដែនជាឯកតោភាគីរបស់ទាហានថៃ។ កម្ពុជាមិនចង់មានសង្គ្រាមជាមួយប្រទេសជិតខាងទេ កម្ពុជាចង់បានការដោះស្រាយដោយសន្តិវិធី ប្រើប្រាស់ច្បាប់អន្តរជាតិ តាមរយៈយន្តការតុលាការយុត្តិធម៌អន្តរជាតិ (ICJ)។ ចំពោះបញ្ហាព្រំដែននេះ សូមក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀន ប្រាប់បងប្អូនប្រជាពលរដ្ឋយើងឱ្យមានភាពស្ងប់ស្ងាត់និងជឿជាក់លើរាជរដ្ឋាភិបាលនិងកងកម្លាំងប្រដាប់អាវុធខ្មែរយើងក្នុងការដោះស្រាយបញ្ហានេះ តាមរយៈការរួមសាមគ្គីគ្នាជាមួយរាជរដ្ឋាភិបាល ផ្សារភ្ជាប់ និងផ្តល់ការគាំទ្រដល់កងកម្លាំងប្រដាប់អាវុធ ដើម្បីពង្រឹងខឿនការពារជាតិរបស់យើងឱ្យកាន់តែរឹងមាំ។

ឆ្លងតាមការពិភាក្សានិងផ្លាស់ប្តូរមតិយោបល់គ្នាយ៉ាងផុលផុស ក្រុមសមាជិកាព្រឹទ្ធសភា បានកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបាននិងកំពុងបន្តខិតខំលះបង់ទាំងកម្លាំងកាយ ចិត្ត បញ្ញា បំពេញតួនាទីភារកិច្ចរបស់ខ្លួនក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ប្រកបដោយការទទួលខុសត្រូវខ្ពស់។ ទន្ទឹមនឹងនោះ ក្រុមសមាជិកាព្រឹទ្ធសភាបានផ្តាំផ្ញើដល់សមាជិក សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀន សូមបន្តបម្រើប្រជាពលរដ្ឋឱ្យបានល្អ ជាពិសេសធានាឱ្យបាននូវការអនុវត្តភូមិ ឃុំ សង្កាត់មានសុវត្ថិភាព បន្តលើកកម្ពស់ការផ្តល់សេវាសាធារណៈឱ្យកាន់តែល្អប្រសើរនិងខិតខំដោះស្រាយបញ្ហាប្រឈមនានាក្នុងកម្រិតដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយយុត្តិធម៌ បរិយាបន្ន និងសមធម៌សង្គម។ ចំពោះបញ្ហាប្រឈមនិងសំណូមពរនានា ដែលក្រុមប្រឹក្សាឃុំ សង្កាត់ បានលើកឡើង ក្រុមសមាជិកាព្រឹទ្ធសភានឹងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីលើកអនុសាសន៍ជម្រាបដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ រួមគ្នាដោះស្រាយ។

បន្ទាប់ពីជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀន តាមខេត្តនីមួយៗរួចមក ក្រុមសមាជិកាព្រឹទ្ធសភាដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្ត មន្ទីរ និងអង្គភាពពាក់ព័ន្ធជុំវិញខេត្តកោះកុង ដឹកនាំដោយលោកជំទាវ **មិថុនា ភូថង** អភិបាលនៃគណៈអភិបាលខេត្តកោះកុង ដើម្បីឈ្វេងយល់អំពីតម្រូវការ បញ្ហាប្រឈម និងសំណូមពរនានារបស់ខេត្ត ព្រមទាំងនាំយកតម្រូវការ បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងខេត្តកោះកុង មកជម្រាបជូនអាជ្ញាធរខេត្ត ដើម្បីពិភាក្សានិងរកដំណោះស្រាយឱ្យឆ្លើយតបនឹងសំណូមពរ និងសេចក្តីត្រូវការរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ក្រុមសមាជិកាព្រឹទ្ធសភា ថតរូបអនុស្សាវរីយ៍ជាមួយថ្នាក់ដឹកនាំខេត្តកោះកុង*

# ក្រុមសមាជិកាព្រឹទ្ធសភា ចែកអំណោយជូនប្រជាពលរដ្ឋ នៅឃុំកំពង់ស្វាយ និងឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

ក្រុមសមាជិកាព្រឹទ្ធសភា ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងជាអនុប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកចង្ក្រានសន្សំសំចៃថាមពលនិងសារុង ចែកជូនប្រជាពលរដ្ឋរស់នៅឃុំកំពង់ស្វាយចំនួន៦៨៨គ្រួសារនិងឃុំត្រពាំងឫស្សី ចំនួន៧៤៤គ្រួសារ សរុបចំនួន១.៤៣២គ្រួសារ ស្ថិតក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីថ្ងៃអាទិត្យ ទី២០ ខែកក្កដា ឆ្នាំ២០២៥។




*លោកជំទាវ មាន សំអាន ប្រធានក្រុមសមាជិកាព្រឹទ្ធសភា*

បន្ទាប់ពីលោកអភិបាលរងស្រុកកំពង់ស្វាយ បានឡើងមានមតិស្វាគមន៍និងជម្រាបអង្គពិធីជ្រាបអំពី វឌ្ឍនភាព បញ្ហាប្រឈម និងតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងស្រុកកំពង់ស្វាយរួចមក លោកជំទាវ **មាន សំអាន** បានថ្លែងនូវការកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរស្រុកកំពង់ស្វាយ ដែលបានខិតខំបំពេញភារកិច្ចរបស់ខ្លួននិងយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហានានាក្នុងមូលដ្ឋានរបស់ខ្លួន។ ទន្ទឹមគ្នានោះ លោកជំទាវបានជម្រាបនូវប្រសាសន៍ផ្ដាំផ្ញើសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនអាជ្ញាធរស្រុកនិងបងប្អូនប្រជាពលរដ្ឋប្រកបដោយក្ដីនឹករលឹក។

**លោកជំទាវប្រធានក្រុម** បានមានប្រសាសន៍បន្ថែមថា ចាប់តាំងពីថ្ងៃទី២៨ ខែមិថុនា រហូតមកដល់ថ្ងៃនេះមានរយៈពេលជិតពីរខែហើយ ដែលមានបញ្ហាកើតឡើងនៅព្រំដែនកម្ពុជា-ថៃ។ ការប្រឈមនឹងភាពតានតឹងនៅតាមព្រំដែនបានធ្វើឱ្យប្រជាពលរដ្ឋយើងមានទឹកចិត្តពុះកញ្ជ្រោល មានមនសិការស្នេហាជាតិ ចង់បានសន្តិភាពយូរអង្វែង រួមកម្លាំងកាយចិត្តនិងសម្ភារៈ ដើម្បីការពារទឹកដីជាតិមាតុភូមិរបស់យើង។

**លោកជំទាវប្រធានក្រុម** បានជម្រាបអំពីមូលហេតុនៃជម្លោះព្រំដែនកម្ពុជា-ថៃ ដែលបានកើតឡើងពីការគូរផែនទីជាឯកតោភាគីរបស់ថៃ ការចូលមកបាញ់សម្លាប់ទាហានយើង ការបិទព្រំដែនជាឯកតោភាគីរបស់ទាហានថៃ ការគំរាមកាត់ផ្ដាច់អគ្គិសនី ថាមពល និងការប្រមាថ។ **លោកជំទាវ**បានបញ្ជាក់ថា កម្ពុជាយើងមិនចង់មានជម្លោះជាមួយ





*ក្រុមសមាជិកាព្រឹទ្ធសភា សំណេះសំណាលជាមួយប្រជាពលរដ្ឋនៅឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ*





*លោកជំទាវ មាន សំអាន សំណេះសំណាលជាមួយប្រជាពលរដ្ឋនៅឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ*

ប្រទេសជិតខាងទេ ប៉ុន្តែបើគេនៅតែឈ្លានពាន នោះយើងនឹងប្រើសិទ្ធិការពារខ្លួននិងវាយបកវិញ។ រហូតមកដល់ពេលនេះ ទាំង**សម្តេចតេជោ**និង**សម្តេចធិបតី** បានខិតខំដោះស្រាយបញ្ហាព្រំដែនដោយសន្តិវិធី តាមរយៈការចរចាទ្វេភាគី និងការនាំយកបញ្ហានៅតំបន់មុំបី តំបន់ប្រាសាទតាមាន់តូច ប្រាសាទតាមាន់ធំ និងប្រាសាទតាក្របី ទៅតុលាការយុត្តិធម៌អន្តរជាតិ (ICJ) ។

ជាមួយគ្នានោះ លោកជំទាវប្រធានក្រុមក៏បានជម្រាបផងដែរ អំពីមូលហេតុនៃការធ្វើវិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបើកផ្លូវឱ្យមានការរៀបចំឯកសារគតិយុត្តិនានាសម្រាប់ដកសញ្ជាតិ ដោយសារតែមានក្រុមជនជ្រុលនិយមមួយក្តាប់តូចគប់គិតជាមួយបរទេស ព្យាយាមបិទបាំងអំពើឈ្លានពានរបស់បរទេស ធ្វើសកម្មភាពប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍ជាតិនិងប្រជាពលរដ្ឋ ដែលនេះឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងជាក់ស្តែងពីភាពគ្មានទំនួលខុសត្រូវចំពោះជាតិនិងបំផ្លាញផលប្រយោជន៍ជាតិខ្លួនឯង។

មុននឹងបញ្ចប់ លោកជំទាវប្រធានក្រុម បានគូសបញ្ជាក់ថា ការចែកចង្ក្រានសន្សំសំចៃថាមពលជូនបងប្អូន គឺដើម្បីឱ្យយើងទាំងអស់គ្នាចូលរួមសន្សំសំចៃថាមពលនិងការការពារបរិស្ថាន រួមចំណែកការពារសុខុមាលភាពរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន និងចូលរួមចំណែកក្នុងការកាត់បន្ថយនូវការចំណាយរបស់បងប្អូនប្រជាពលរដ្ឋ។ អំណោយដែលចែកជូនដល់រដ្ឋបាលឃុំទាំងពីរ រួមមាន ចង្ក្រានសន្សំសំចៃថាមពល ដែលជាអំណោយរបស់ក្រុមហ៊ុន SIPCO និងសារុង ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*លោកជំទាវ មាន សំអាន ចែកអំណោយ និងថតរូបអនុស្សាវរីយ៍ជាមួយប្រជាពលរដ្ឋនៅឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ*

# កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមតួមិភាគ និងក្រុមនានានៃព្រឹទ្ធសភា

## ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១ព្រឹទ្ធសភា ចំនួន១លើក

នាថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៥ នៅសាលប្រជុំពិសេស ក្រោមព្រឹទ្ធសភា ឯកឧត្តម **ខឹ ច័ន្ទ្រផល**ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-របាយការណ៍សកម្មភាពនិងលទ្ធផលការងាររបស់គណៈកម្មការប្រចាំខែកក្កដា និងទិសដៅការងារសម្រាប់ខែសីហា ឆ្នាំ២០២៥

២-សេចក្តីព្រាងកម្មវិធីចុះបេសកកម្មរបស់គណៈកម្មការ

៣-បញ្ហាផ្សេងៗ។

## ❈គណៈកម្មការទី១ព្រឹទ្ធសភា ជួបជាមួយក្រសួង ស្ថាប័នចំនួន១លើក



នាថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៥ នៅសាលប្រជុំពិសេស ក្រោម វិមានព្រឹទ្ធសភា ឯកឧត្តម **ខឹ ច័ន្ទ្រផល** ប្រធានគណៈកម្មការ បានជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក.ជ.ក.ស ដឹកនាំដោយលោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធាន ក.ជ.ក.ស ដើម្បីឈ្វេងយល់ពីវឌ្ឍនភាពការងារទាក់ទងនឹងការលើកកម្ពស់សិទ្ធិស្ត្រី និងកិច្ចសហការការងារ។

## ❈គណៈកម្មការទី១ព្រឹទ្ធសភា ជួបភ្ញៀវជាតិ ចំនួន១លើក

នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ខឹ ច័ន្ទ្រផល** ប្រធានគណៈកម្មការ បានទទួលជួបជាមួយតំណាងប្រជាពលរដ្ឋ៤៤គ្រួសារ មកពីភូមិតំណាក់សង្កែ សង្កាត់ព្រែកកំពឹស ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលអញ្ជើញមកថ្លែងអំណរគុណចំពោះ**សម្តេចតេជោប្រធាន**



**ព្រឹទ្ធសភា** ដែលបានជួយអន្តរាគមន៍ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោះស្រាយបណ្តឹងរបស់ពួកគាត់ទទួលបានជោគជ័យ ដោយប្រជាពលរដ្ឋនឹងទទួលប័ណ្ណកម្មសិទ្ធិដីធ្លីនាពេលខាងមុខ។

## ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី២ព្រឹទ្ធសភា ចំនួន១លើក



នាថ្ងៃព្រហស្បតិ៍ ទី២៦ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បី៖

១-ពិនិត្យរបាយការណ៍ប្រចាំខែ

២-ពិភាក្សាអំពីការត្រៀមចុះបេសកកម្មចន្លោះសម័យប្រជុំ

៣-ស្តាប់បទបង្ហាញអំពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករធ្វើដោយក្រុមការងារធុរវឌ្ឍន៍

៤-ពិនិត្យលើបញ្ហាផ្សេងៗ។

## ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា



**(ក្រុមទី១) ចំនួន១លើក**

នារសៀលថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **យស ផានីត្តា** ប្រធានក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី១) បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី១) ដើម្បីពិនិត្យពិភាក្សា និងត្រៀមយោបល់លើសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបញ្ហាផ្សេងៗ។

**❉កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ចំនួន១លើក**



នាព្រឹកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ដើម្បីត្រៀមរៀបចំពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលក្នុងខេត្តកំពង់ស្ពឺ និងកម្មវិធីសម្ពោធស្រះទឹកមួយកន្លែង នៅភូមិសំរោងជើងភ្នំ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងបញ្ហាផ្សេងៗ។

**❉កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) ចំនួន១លើក**



នាថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) ដើម្បី៖

១-ពិនិត្យនិងពិភាក្សាលើសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

២-ចាត់តំណាងក្រុមឡើងមានយោបល់ក្នុងកិច្ចប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥

៣-បញ្ហាផ្សេងៗ។

**❉កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ចំនួន១លើក**



នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ បានដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ លើ៖

១-គម្រោងចុះបេសកកម្មជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តរតនគិរី

២-ការប្រកាសទទួលស្គាល់លោកជំទាវ **ចឹក ហេង** ជាសមាជិកាក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨។

**❉កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា ចំនួន១លើក**

នាព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ចែម វីឌ្យា** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-សេចក្តីរាយការណ៍ស្តីពី វឌ្ឍនភាពទំនាក់ទំនងវិស័យការទូតសភា ប្រចាំឆមាសទី១ ឆ្នាំ២០២៥ (ឯកឧត្តម **ឡូន សុខវេង** អគ្គនាយកពិធីការ និងទំនាក់ទំនងអន្តរជាតិ)

២-បូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២៥

៣-បូកសរុបចំណូល-ចំណាយថវិកាប្រចាំខែមិថុនានិង

ប្រចាំឆមាសទី១ ឆ្នាំ២០២៥

៤.បញ្ហាផ្សេងៗ។

**❈គណៈកម្មការទី៥ព្រឹទ្ធសភា ជួបភៀវអន្តរជាតិ ចំនួន១លើក**



នារសៀលថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ចែម វីយ៉ា** ប្រធានគណៈកម្មការ បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម Nikoloz Samkharadze សមាជិកសភា និងជាប្រធានគណៈកម្មាធិការទំនាក់ទំនងអន្តរជាតិ នៃសភាប្រទេសហ្សកហ្ស៊ី នៅការិយាល័យរបស់ឯកឧត្តមបណ្ឌិត។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៦ព្រឹទ្ធសភា ចំនួន២លើក**



នាថ្ងៃទី១១-១២ ខែកក្កដា ឆ្នាំ២០២៥ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិភាក្សាលើសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបញ្ហាផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) ចំនួន១លើក**

នារសៀលថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៥ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** អនុប្រធានក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៣) បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា



(ក្រុមទី៣) ដើម្បីពិនិត្យពិភាក្សានិងត្រៀមយោបល់លើសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងពិនិត្យលើបញ្ហាផ្សេងៗ។



**❈កិច្ចប្រជុំអន្តរគណៈកម្មការ ចំនួន១លើក**

នាព្រឹកថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៥ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំគណៈកម្មការនានា នៃព្រឹទ្ធសភា ជាមួយក្រុមតំណាងរាស្ត្រហត្ថលេខី ដឹកនាំដោយឯកឧត្តម **អេង ចាន់ ចន្ទ្រា** ប្រធានគណៈកម្មការទី៦រដ្ឋសភា និងតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម **កើត រិទ្ធ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីពិនិត្យសិក្សាលើសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៧ព្រឹទ្ធសភា ចំនួន២លើក**



នាថ្ងៃទី៨ និងថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការដើម្បី៖

១-ពិនិត្យនិងពិភាក្សាលើឯកសារសំខាន់ៗ សម្រាប់ត្រៀមចុះបំពេញបេសកកម្មនៅ ខេត្តកំពង់ស្ពឺ និងខេត្តកោះកុង

២-ពិនិត្យរបាយការណ៍ ស្តីពីលទ្ធផលការងាររបស់គណៈកម្មការទី៧ព្រឹទ្ធសភា ប្រចាំខែកក្កដា និងទិសដៅការងារបន្តខែសីហា ឆ្នាំ២០២៥

៣-ពិនិត្យឯកសារជំនួយស្មារតីត្រៀមជួបពិភាក្សាការងារជាមួយក្រសួងធម្មការ និងសាសនា

៤-បញ្ហាផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៨ព្រឹទ្ធសភា ចំនួន១លើក**

នាព្រឹកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យនិងពិភាក្សាលើ៖



១-បូកសរុបលទ្ធផលការងាររបស់គណៈកម្មការប្រចាំខែមិថុនា ឆ្នាំ២០២៥ និងទិសដៅខែកក្កដា ឆ្នាំ២០២៥

២-បូកសរុបលទ្ធផលការងាររបស់គណៈកម្មការប្រចាំឆមាសទី១ ឆ្នាំ២០២៥

៣-អំពីការត្រៀមចុះបេសកកម្មរបស់គណៈកម្មការនៅចន្លោះសម័យប្រជុំលើកទី៣និងលើកទី៤ នីតិកាលទី៥ នៃព្រឹទ្ធសភា

៤-បូកសរុបចំណូល-ចំណាយថវិការបស់គណៈកម្មការប្រចាំឆមាសទី១ ឆ្នាំ២០២៥

៥-បញ្ហាផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ចំនួន១លើក**

នាព្រឹកថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ដើម្បីពិភាក្សាអំពីកម្មវិធីរៀបចំវេទិកា នៅខេត្តព្រៃវែងនិងខេត្តស្វាយរៀង។

**❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកាព្រឹទ្ធសភា ចំនួន១លើក**

នារសៀលថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកាព្រឹទ្ធសភា បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកាព្រឹទ្ធសភា ដើម្បីពិនិត្យលើខ្លឹមសាររបាយការណ៍ចុះជួបសំណេះសំណាល ឈ្វេងយល់ពីតម្រូវការ បញ្ហាប្រឈមនិងសំណូមពររបស់ក្រុមប្រឹក្សាឃុំសង្កាត់ជាស្ត្រី នៅក្នុងភូមិភាគទី៧ (ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តកោះកុង និងខេត្តព្រះសីហនុ)។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៩ព្រឹទ្ធសភា ចំនួន១លើក**



នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិភាក្សាលើ៖

១-ការត្រៀមចុះបេសកកម្ម និងទស្សនកិច្ចវិទ្យាស្ថានរបស់ក្រសួងមួយចំនួនពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ

២-បញ្ហាផ្សេងៗ។

**❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ចំនួន១លើក**

នាព្រឹកថ្ងៃចន្ទ ទី១៤ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការ ដើម្បីពិនិត្យសម្រេចលើសេចក្ដីព្រាងរបាយការណ៍ស្តីពី សកម្មភាពលទ្ធផលការងារប្រចាំខែកក្កដា



និងលើកទិសដៅការងារបន្ត។

## ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៥) ចំនួន១លើក



នារសៀលថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុនណាង** អនុប្រធានក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៥) បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី៥) ដើម្បីពិនិត្យពិភាក្សានិងត្រៀមឱ្យយោបល់លើសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

## ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ ចំនួន១លើក

នាព្រឹកថ្ងៃសៅរ៍ ទី១៩ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុនណាង** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ ដើម្បីពិនិត្យ និងពិភាក្សាលើ៖

១-គម្រោងចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំសង្កាត់ នៃ១៣ក្រុង ស្រុក ទូទាំងខេត្តកណ្តាល នៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤

២-កំណត់យកប្រធានបទសម្រាប់ធ្វើបទបង្ហាញជូនអង្គពិធីសំណេះសំណាល

៣-ការងារផ្សេងៗ។

## ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ចំនួន២លើក



នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ខៀវ មុត** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បានដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ដើម្បីពិនិត្យនិងពិភាក្សាលើ៖

១-របាយការណ៍សកម្មភាពប្រចាំខែមិថុនានិងឆមាសទី១ ឆ្នាំ២០២៥

២-របាយការណ៍អំពីលទ្ធផលនៃការចុះពិនិត្យស្រះទឹកនៅខេត្តកំពត និងខេត្តកែប

៣-ផែនការសកម្មភាពក្នុងចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ (ខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០២៥)

៤-សិក្សាស្រាវជ្រាវអំពីវឌ្ឍនភាពនៃការដីកព្រែកហ្វូណនតេជោ

៥-បញ្ហាផ្សេងៗ។



ឯកឧត្តម **ឈួន ឆាម** អនុប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បានដឹកនាំប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ដើម្បីត្រៀមរៀបចំពិធីសំណេះ-សំណាលជាមួយក្រុមប្រឹក្សាឃុំ សៀនឃុំ នៅស្រុកគិរីវង់ និងស្រុកទ្រាំង នៃខេត្តតាកែវ និងបញ្ហាផ្សេងៗ នារសៀលថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៥៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារ នៅតាមបណ្ដាភូមិភាគទាំង៨

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋមកកំសាន្តនៅតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ព្រមទាំងទទួលជួបភ្ញៀវជនជាតិជប៉ុនចំនួន៤នាក់ និងដឹកនាំពួកគាត់ចុះពិនិត្យហេដ្ឋារចនាសម្ព័ន្ធនានា វិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងនាំយកកូនត្រីប្រាចំនួន៧០.០០០កូនមកប្រលែងបន្ថែមក្នុងស្រះទឹកថ្មីទើបតែបានជីករួចរាល់ជាស្ថាពរ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៥។

-ទទួលដំណើររបស់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សមកពីសាលាមីគីរ៉េ និងសាលាសុវណ្ណភូមិ សរុបចំនួន៣៨៧នាក់ អញ្ជើញមកទស្សនកិច្ចសិក្សាឈ្វេងយល់ និងទស្សនាទីលានប្រណាំងរថយន្ត សួនសត្វ សម្ភារចេតិយរូបសំណាកប្រាសាទព្រះវិហារ ទំនប់ទឹក ស្រះទឹក និងហេដ្ឋារចនាសម្ព័ន្ធនានា ព្រមទាំងជិះឡូរីកម្សាន្ត នៅក្នុងតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ និងទទួលជួបភ្ញៀវជនជាតិចិនមានបំណងចង់ពង្រឹងពង្រីកមូលដ្ឋានវិស័យកសិកម្ម កសិ-ឧស្សាហកម្ម នៅក្នុងតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នាព្រឹកថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៥។

-ពិនិត្យអំពីរបៀបចិញ្ចឹមត្រីខ្ញឹង នៅក្នុងវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប នារសៀលថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៥។

-ទទួលដំណើររបស់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សកុមារា និងកុមារី មកពីសាលាបឋមសិក្សា ឪខេម អញ្ជើញមកទស្សនកិច្ចសិក្សាក្នុងគោលបំណងផ្ដល់ឱកាសដល់សិស្សានុសិស្ស បានក្រេបជញ្ជក់ចំណេះដឹងជាក់ស្ដែងក្នុងតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែន-ជ័យ នៅឃុំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៥។

-ទទួលជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពល-រដ្ឋដែលអញ្ជើញមកពីសហគមន៍ផលិតថ្នាំងក្អមនៃខេត្តកំពង់-ឆ្នាំង និងបានទិញផើងផ្កាចំនួន១៥០ផើង ព្រមទាំងដឹកនាំពួកគាត់ជិះឡូរី និងទស្សនាហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៥។

-ទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូមកពីវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប ដើម្បីសិក្សាស្វែងយល់បន្ថែមពីវិស័យកសិកម្ម ដំណាំឈើហូបផ្លែ ការដាំដើមឈើព្រៃ ការចិញ្ចឹមត្រី និងហេដ្ឋារចនាសម្ព័ន្ធនានា នៅក្នុងតំបន់រមណីយ-ដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៥។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋដែលប្រកបរបររកអុស ព្រមទាំងបានជូនថវិកាមួយចំនួនដល់ពួកគាត់ នៅភូមិសំរោងជើងភ្នំ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៥។

-ជាអធិបតីក្នុងពិធីសំណេះសំណាល និងបើកការដ្ឋានសាងសង់សួនទឹកថ្មី នៅក្នុងតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នារសៀលថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥។

-ទទួលដំណើរដ៏ខ្ពង់ខ្ពស់របស់សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា និងគណៈប្រតិភូអញ្ជើញដាំដើមធ្នង់ជានិមិត្តរូប ទស្សនាសួនសត្វ ដំណាំឈើហូបផ្លែ ប្រាសាទព្រះវិហារនិមិត្តរូប សម្ភារភាពចេតិយ៍ និងជិះឡូរីកម្សាន្ត នៅតំបន់រមណីយដ្ឋានអភិវឌ្ឍន៍

កសិទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅឃុំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៥។



-ជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយអាជ្ញាធរមូលដ្ឋានឃុំតានៃ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនជូនដល់ពួកគាត់ នៅឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥។



-ជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយអាជ្ញាធរមូលដ្ឋានឃុំកែវផុស និងចូលរួមដាំដើមឈើគីនីនចំនួន២០០ដើម នៅតាមផ្លូវឧកញ៉ាម៉ុង ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនជូនដល់ពួកគាត់ នៅឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នារសៀលថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥។



❈ថ្ងៃអាទិត្យ ទី៦ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលនិងសួរសុខទុក្ខប្រជាពលរដ្ឋដែលជួបការលំបាកក្នុងភូមិអណ្ដូងធំ ចំនួន២១០គ្រួសារ ព្រមទាំងបាននាំយកនូវអំណោយមួយចំនួនដូចជា៖ អង្ករ ទឹកត្រី ត្រីខស្ករ-ស ត្រីងៀត សាច់ក្រក មី អំបិល ក្រមា សារុង នំប៉ាវ ទឹកផ្លែឈើ និងថវិកាមួយចំនួន នៅភូមិអណ្ដូងធំ ឃុំគោក-ព្រេជ ស្រុកគីរីវង្ស ខេត្តតាកែវ។

❈នាថ្ងៃសៅរ៍ ទី១៩ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំបូកសរុបសភាពការណ៍ទូទៅ និងលទ្ធផលការងារប្រចាំឆមាសទី១ និងលើកទិសដៅអនុវត្តឆមាសទី២ ឆ្នាំ២០២៥ នៅសាលប្រជុំសាលាខេត្តកោះកុង។

❈នាព្រឹកថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និង



ឯកឧត្តម **ហេង ហាលីម** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញសួរសុខទុក្ខលោក **អៀង សុខុម** ប្រធានក្រុមប្រឹក្សាឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ដែលកំពុងសម្រាកព្យាបាលជំងឺ នៅមន្ទីរពេទ្យកាល់ម៉ែត រាជធានីភ្នំពេញ។

❈នាព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមរំលែកទុក្ខបុណ្យគម្រប់៧ថ្ងៃភរិយាលោកអនុសេនីយ៍ត្រី **គីម សារិ** ដែលជាកងទ័ពបម្រើការងារនៅកងពលលេខ៩ នៅខេត្តព្រះវិហារ ព្រមទាំងបាននាំយកថវិកាមួយចំនួនរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ និងថវិកាមួយចំនួនរបស់សមាគមនារីដើម្បីចូលបច្ច័យបុណ្យ នៅភូមិកន្សោមអក ឃុំកន្សោមអក

ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។

❈ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីប្រគេនទានព្រះវស្សា ចំនួន១៤វត្ត ក្នុងខេត្តព្រៃវែង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ **ញ៉ៀម សាខន សខេង** នៅគេហដ្ឋានសម្តេចផ្ទាល់ ក្នុងក្រុងព្រៃវែង ខេត្តព្រៃវែង នាព្រឹកថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៥។

-ចូលរួមពិធីប្រគេនទានព្រះវស្សាចំនួន៣២វត្ត ក្នុងស្រុកពាមជរ ក្រោមអធិបតីភាពឯកឧត្តម **ជា សុមេធី** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងលោកជំទាវ **ជា ផល្លុន** នៅក្នុងគេហដ្ឋានឯកឧត្តមផ្ទាល់ ស្ថិតក្នុងស្រុកពាមជរ ខេត្តព្រៃវែង នាព្រឹកថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៥។



❈នាថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តមសន្តិបណ្ឌិត **តេង សាវឌ្ឍ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តមបណ្ឌិត **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីសូត្រមន្តប្រគេនទៀនចំណាំព្រះវស្សានិងទេយ្យទានបច្ច័យរបស់លោកជំទាវ **ញ៉ៀម សាខន សខេង** ដល់ព្រះសង្ឃ ចំនួន១៦វត្ត ក្នុងនោះមានវត្តគណៈធម្មយុត្តិកនិកាយ ចំនួន៣វត្ត និងគណៈមហានិកាយ ចំនួន១៣វត្ត ស្ថិតនៅភូមិគ្រឹះសម្តេចក្រឡាហោម **ស ខេង** ភូមិព្រែកមហាទេព សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។



❈នាថ្ងៃសៅរ៍ ទី២៦ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខគណៈបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តកោះកុង រួមមាន ស្នងការនគរបាលខេត្ត វរសេនាតូចលេខ៣៣៧ ផ្នែកសឹករងមណ្ឌលសីមា វរសេនាតូចការពារព្រំដែនគោកលេខ៨២៧ ព្រមទាំងបានឧបត្ថម្ភជាថវិកាមួយចំនួនដល់អង្គភាពទាំង៥ នៅទីបញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹករងខេត្តកោះកុង។



❈នាថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាមួយកាកបាទក្រហម និងក្រុមការងារសមាគមសិស្ស និស្សិត អ.ម.ត ខណ្ឌទួលគោក ជួបសំណេះសំណាលសួរសុខទុក្ខប្រជាពលរដ្ឋចាស់ជរា ជនពិការ តាមខ្នងផ្ទះ សរុបចំនួន៥៩គ្រួសារ ព្រមទាំងបានឧបត្ថម្ភអង្ករ កន្សែងពោះគោ និងថវិកាមួយចំនួន ក្នុងសង្កាត់ទាំង១០ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

❈នាព្រឹកថ្ងៃចន្ទ ទី២៨ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញជាគណៈអធិបតីក្នុងកិច្ចប្រជុំជាមួយមន្ត្រីថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ ព្រមទាំងបានឧបត្ថម្ភថវិកា

មួយចំនួន នៅឃុំព្រះពន្លា ស្រុកកំពង់ពោធិ៍ ខេត្តស្វាយរៀង។

❈នាថ្ងៃអង្គារ ទី២៩ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ស៊ាក ឡេង** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និវត្តជន ដែលអតីតជាថ្នាក់ដឹកនាំក្នុងរដ្ឋបាលខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម ព្រមទាំងបានផ្តល់ជូននូវអំណោយមួយចំនួនរួមមាន នាឡិកាដៃ បំពង់ទឹកក្តៅ និងថ្នាំពេទ្យ។

❈នាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **ជឹម លាច** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំត្រពាំងគរ ដើម្បីឈ្វេងយល់អំពី ការអនុវត្តច្បាប់របស់ក្រុមប្រឹក្សាឃុំ នៅសាលាស្រុកជើងព្រៃ ខេត្តកំពង់ចាម។

❈ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖

-ដឹកនាំកិច្ចប្រជុំជាមួយរដ្ឋបាលឃុំក្រពុំឈូក និងក្រុមការងារពាក់ព័ន្ធ ចាស់ព្រឹទ្ធាចារ្យ នាយកសាលា ទាំង២កម្រិតសិក្សានិងមណ្ឌលសុខភាព ដើម្បីពង្រឹងប្រសិទ្ធភាពការងារក្នុងឃុំ និងបម្រើសេវាជូនប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធភាព ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន នៅឃុំក្រពុំឈូក ស្រុកកោះអណ្តែត ខេត្តតាកែវ នាព្រឹកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥។

-ចូលរួមខួបលើកទី១៦២ ទិវាកាកបាទក្រហមកម្ពុជា ក្រោមប្រធានបទ «រួមគ្នាស្ម័គ្រចិត្ត ដើម្បីសហគមន៍មានសុខភាពល្អ និងមានភាពធន់នឹងអាកាសធាតុ» នៅខេត្តតាកែវ នាព្រឹកថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៥។

❈ឯកឧត្តមបណ្ឌិត **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមជាគណៈអធិបតីក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នូវលទ្ធផលការងាររដ្ឋបាលស្រុក មូលនិធិថវិកាស្រុក របស់ក្រុមប្រឹក្សា និងគណៈអភិបាលស្រុក សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា នៅឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង




នាថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៥។



-ចូលរួមក្នុងពិធីប្រគេនទៀនព្រះវស្សា ទេយ្យទាន និងបច្ច័យមួយចំនួនប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា នៅវត្តក្តីកណ្តាល ( ហៅវត្តម្រាក ) ក្នុងឃុំស្វាយចេក ស្រុករំដួល ខេត្តស្វាយរៀង នាថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៥។

❈ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមពិធីសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ សម្ភារៈប្រើប្រាស់ និងថវិកាមួយចំនួនជូនដល់ប្រជាពលរដ្ឋដែលកំពុងវិលត្រឡប់ពីប្រទេសថៃ និងប្រជាការពារ ចំនួន៥សង្កាត់ និងកងកម្លាំងបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោក រួមមាន៖ ៨០៧, ៨១៥, ៨៩១, ៩១១ ក្រោមអធិបតីភាពឯកឧត្តម **កែ គឹមយ៉ាន** ឧត្តមប្រឹក្សាផ្ទាល់

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅច្រកអន្តរជាតិស្ទឹងបត់ ច្រកអន្តរជាតិប៉ោយប៉ែត និងទីបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨៩១ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥។



-ចូលរួមពិធីសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយជាគ្រឿងឧបភោគ បរិភោគ សម្ភារៈប្រើប្រាស់ ឧបត្ថម្ភដីភ្នំ១៥០ឡាន ថ្មមិច៣៧ឡាន និងថវិកាមួយចំនួន ជូនដល់កងទ័ពជួរមុខទិសទី១ មូលដ្ឋានខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពឯកឧត្តម **កៃ គឹមយ៉ាន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៥។



-ចូលរួមពិធីប្រកាសបញ្ចប់ការវាស់វែង និងប្រគល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ជូនប្រជាពលរដ្ឋចំនួន ៦.៣៥៥ប័ណ្ណ នៅភូមិសាស្ត្រ ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពឯកឧត្តម **សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ និងឯកឧត្តម **ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅសាលប្រជុំធំសាលាខេត្តបន្ទាយមានជ័យ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥។

-ចូលរួមជាមួយក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ក្នុង



ពិធីប្រគេនទៀនព្រះវស្សា ទេយ្យទាន និងបច្ច័យប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា ក្រោមអធិបតីភាពឯកឧត្តម **កៃ គឹមយ៉ាន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅវត្តទក្ខិណគង្គារាមអញ្ចាញ ស្រុកមង្គលបូរី និងវត្តចមសុទ្ធាវាស ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥។



-ចូលរួមកិច្ចប្រជុំបូកសរុបសកម្មភាព និងលទ្ធផលការងារប្រចាំឆមាសទី១ និងលើកទិសដៅអនុវត្តឆមាសទី២ ឆ្នាំ២០២៥ របស់ក្រុមការងាររាជរដ្ឋាភិបាល ចុះជួយខេត្តបន្ទាយមានជ័យ នៅសាលាខេត្តបន្ទាយមានជ័យ នាថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៥។



-ចូលរួមជាមួយក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ក្នុងពិធីប្រគេនទៀនព្រះវស្សា ទេយ្យទាន និងបច្ច័យប្រគេនព្រះសង្ឃគង់ចាំព្រះវស្សា នៅវត្តទាំង៣១ តាមបណ្តោយ

ព្រំដែនកម្ពុជា-ថៃ ក្នុងក្រុង ស្រុក ចំនួន៥រួមមាន៖ ស្រុកម៉ាឡៃ ក្រុងប៉ោយប៉ែត ស្រុកអូរជ្រៅ ស្រុកស្វាយចេក និងស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាព ឯកឧត្តម **កែ គឹមយ៉ាន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៥។



-ចូលរួមដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម នាយឧត្តមសេនីយ៍ **សុខ ឆាព** រដ្ឋលេខាធិការក្រសួងការពារជាតិ ដែលបានទទួលមរណភាព ក្នុងជន្មាយុ៧៣ឆ្នាំ ដោយរោគាពាធ ក្រោមអធិបតីភាព ឯកឧត្តម **កែ គឹមយ៉ាន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅគេហដ្ឋានសព ភូមិកូនដំរី សង្កាត់និមិត្ត ក្រុងប៉ោយ-ប៉ែត ខេត្តបន្ទាយមានជ័យ នារសៀលថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៥។

❋លោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញ៖




-ជួបសំណេះសំណាល ចែកចង្រ្កានសន្សំសំចៃថាមពល និងសារុងជូនប្រជាពលរដ្ឋចំនួន៦៧៩គ្រួសារ មកពីភូមិទាំង ១៤ ក្នុងឃុំសាន់គ ស្ថិតនៅសាលាឃុំសាន់គ ស្រុកកំពង់-ស្វាយ ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥។



-ជួបសំណេះសំណាលចែកចង្រ្កានសន្សំសំចៃថាមពល និងសារុងជូនប្រជាពលរដ្ឋចំនួន៦៨៨គ្រួសារ មកពីភូមិទាំង ១៥ ក្នុងឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នៅសាលាឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ រសៀលថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៥។

❋ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលសួរសុខទុក្ខ និវត្តជនចំនួន២រូប ដែលអតីតជាថ្នាក់ដឹកនាំរដ្ឋបាលស្រុកពញាក្រែក និងបានផ្តល់ជូននូវអំណោយមួយចំនួន ជាអាទិ៍៖ នាឡិកាដៃ បំពង់-ទឹកក្តៅ និងថ្នាំពេទ្យ នៅខេត្តត្បូងឃ្មុំ នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលសួរសុខទុក្ខក្រុមប្រឹក្សាឃុំរកាពប្រាំ និងឃុំស្រឡប់ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងសំណូមពរនានា នៅឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥។

❋ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋ និងចូលរួមគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋដែលរស់នៅក្នុង

ភូមិកំពង់ក្រុង (អណ្តូងត្របែក) ឃុំកំពង់ក្រែង និងនៅភូមិព្រៃថ្នង ឃុំព្រៃថ្នង និងភូមិរ៉ៃញៀន ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត និងនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប នារសៀលថ្ងៃទី២៧-២៨ និងថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៥។



-ទទួលស្វាគមន៍ដំណើរនិវត្តន៍វិញរបស់សាសនិកឥស្លាមកម្ពុជា មកពីទីក្រុងម៉ាកាស់ ប្រទេសអារ៉ាប៊ីសាអូឌីត ចំនួន ១៤០នាក់ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាល្ងាចថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៥។



-ចុះសួរសុខទុក្ខថ្នាក់ដឹកនាំវិហារឥស្លាមដែលទើបត្រឡប់មកពីបំពេញធម្មយាត្រាហាជី នៅប្រទេសអារ៉ាប៊ីសាអូឌីត នៅភូមិទទឹងថ្ងៃ សង្កាត់បឹងទូក ក្រុងបូកគោ, នៅភូមិម៉ាក់ប្រាង ឃុំកំពង់ក្រែង, នៅភូមិទ្វាថ្មី ឃុំព្រៃថ្នង និងភូមិកំពង់កណ្តាល ឃុំជុំក្រៀល, នៅមណ្ឌលភូមិដំណាក់ហ្លួង ឃុំព្រៃថ្នង ស្រុកទឹកឈូ ខេត្តកំពត នាថ្ងៃទី២ ទី៤ ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៥។

-ចូលរួមរំលែកមរណទុក្ខនិងគោរពវិញ្ញាណក្ខន្ធសព ប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិម៉ាក់ប្រាង ឃុំកំពង់ក្រែង ស្រុកទឹកឈូ ខេត្តកំពត និងពេលរសៀលគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋ នៅភូមិទទឹងថ្ងៃ សង្កាត់បឹងទូក ក្រុងបូកគោ



ខេត្តកំពត នាព្រឹកថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៥។



-ជួបសំណេះសំណាលនិងពិសាអាហារសាមគ្គីជាមួយបងប្អូនប្រជាពលរដ្ឋ នៅភូមិកំពង់សំរោង ឃុំកំពង់សំរោង នៅភូមិកំពង់ក្រុង (អណ្តូងត្របែក) ឃុំកំពង់ក្រែង ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី១០ និងថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៥។



-ចូលរួមរំលែកមរណទុក្ខនិងគោរពវិញ្ញាណក្ខន្ធសព ប្រជាពលរដ្ឋ នៅភូមិបឹងតាព្រាម និងបានបន្តជួបសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋ នៅភូមិស្រែ សង្កាត់ត្រើយកោះ ក្រុងកំពត ព្រមទាំងនៅភូមិត្រពាំងសង្កែ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី១០ ដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៥។

❈ឯកឧត្តម **គង់ មុនីភា** សមាជិកគណៈកម្មការទី១ ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ ឃុំបឹងព្រះ និងឃុំរក្សជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង ព្រមទាំងជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ នៅឃុំរំចេក ស្រុកព្រះស្ដេច ខេត្តព្រៃវែង នាថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ នៅឃុំកំពង់ត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង នាព្រឹកថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៥។

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ នៅឃុំពោធិ៍រៀង ស្រុកពោធិ៍រៀង ខេត្តព្រៃវែង និងជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ នៅឃុំព្រែកខ្សាយ-ក ស្រុកពាមរក៍ ខេត្តព្រៃវែង នាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៥។

❈លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖



-ប្រគេនទេយ្យវត្ថុ ទេយ្យទាន ទៀនចំណាំព្រះវស្សា អំពូលសូឡា និងបច្ច័យ វត្តចំនួន៥ រួមមាន៖ វត្តអង្គតាសោម វត្តអង្គត្នោត វត្តអង្គខ្វាយ វត្តវេឡុវ៉ន និងវត្តប្រាសាទ ព្រមទាំងប្រគេនព្រះសង្ឃ៥អង្គ ដោយមួយអង្គទទួលបាន ស្លាដក់ ១កញ្ចប់ ចង្ហាន់១ស្រាក់ និងបច្ច័យមួយចំនួន ស្ថិតក្នុងស្រុកត្រាំកក់ ខេត្តតាកែវ នាព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៥។

-ជាធិបតីក្នុងពិធីសម្ពោធសមិទ្ធផលនានាក្នុងវិទ្យាល័យហ៊ុនសែន ជើងធ្នុក និងសាលាបឋមសិក្សាជើងធ្នុក ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួនជូនប្រជាជន កងកម្លាំង សេនា-ជន និងសិស្សានុសិស្ស ស្ថិតក្នុងភូមិជើងធ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១២ ខែកក្កដា



ឆ្នាំ២០២៥។

❈ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ស្មៀននាយប៉ុស្តិ៍នគរបាល និងជំនួយការឃុំស្រែខ្វាវ ដើម្បីឈ្វេង-យល់អំពីការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ការអភិវឌ្ឍមូលដ្ឋាន និងបញ្ហាប្រឈមនានា នៅឃុំស្រែខ្វាវ ស្រុកអង្គរជុំ ខេត្តសៀមរាប នាថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៥។




-ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្មៀនឃុំ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ជំនួយការឃុំ ប្រធានភូមិ ប្រជាពលរដ្ឋក្រីក្រ និងសិស្សានុសិស្ស ព្រមទាំងបានឧបត្ថម្ភថវិកា និងសម្ភារៈសិក្សាមួយចំនួន នៅឃុំគោល ស្រុកអង្គរជុំ ខេត្តសៀមរាប នាថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥។

❈ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៥ ព្រឹទ្ធសភា បានអញ្ជើញ៖

-គោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **សុត ខា** ស្ថិតក្នុងសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥។

-ចុះទៅពិនិត្យវឌ្ឍនភាពនៃការកសាងសាលាបុណ្យមួយខ្នងដែលកំពុងកសាងជិតរួចរាល់ និងឧបត្ថម្ភបង្អួចចំនួន២ផ្ទាំង និងដីក្រហម១០ឡានបន្ថែមទៀត ដើម្បីជំរុញការកសាងផ្លូវមួយខ្សែ និងសាលាបុណ្យ ជូនពុទ្ធបរិស័ទ និងប្រជាពលរដ្ឋដើម្បីធ្វើដំណើរ នៅភូមិស្នាកណ្ដាល ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៥។



-នាំយកទៀនចំណាំព្រះវស្សា ទេយ្យទានទៅប្រគេនព្រះសង្ឃគង់ចាំព្រះវស្សានៅវត្តសុវណ្ណគិរី វត្តក្ងោកមាសលើ និងវត្តក្ងោកមាសក្រោម នៅឃុំព្រៃគ្រី ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៥។

❈លោកជំទាវ **មុំ សណ្ដាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមកិច្ចប្រជុំបូកសរុបរបាយការណ៍ប្រចាំខែមិថុនា និងលើកទិសដៅការងារខែកក្កដា ឆ្នាំ២០២៥ ជាមួយសមាជិក សមាជិកាក្រុមប្រឹក្សាសង្កាត់ មកពីសង្កាត់ទាំង៥ ក្នុងខណ្ឌចំការមន រាជធានីភ្នំពេញ នារសៀលថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៥។



-ជាអធិបតីភាពក្នុងពិធីជួបសំណេះសំណាលជាមួយនឹងសមាជិកក្រុមប្រឹក្សាសង្កាត់ជានារី មកពីភូមិទាំង៥ នៃសង្កាត់ផ្សារដើមថ្កូវ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន នៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ នាថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៥។



-ជាអធិបតីក្នុងពិធីជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋជាក្រុមសហជីព មកពីភូមិទាំង៥ នៃសង្កាត់ផ្សារដើមថ្កូវ ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន នៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ នារសៀលថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥។

❈ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២៥ និងលើកទិសដៅអនុវត្តបន្ត នៅសាលាស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៥។

-ជាអធិបតីក្នុងពិធីបិទវគ្គបណ្ដុះបណ្ដាលជូនក្រុមប្រឹក្សាស្រុក ឃុំ និងស្មៀន សរុបចំនួន៦៤២រូប នៅសាលាស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៥។



-ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាស្រុក ឃុំ ស្មៀន មន្ត្រីកសិកម្មឃុំ ប្រធានមណ្ឌលសុខភាពឃុំ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំស្វាយ ត្បែងខ្ពស់ សេដ្ឋី ធ្លកវៀន ខ្នារឆ្មារ និងឃុំក្រាំងល្វា ដើម្បីឈ្វេងយល់ពីវឌ្ឍនភាពទូទៅរបស់ឃុំ បញ្ហាប្រឈម និងសំណូមពរនានា ព្រមទាំងជួបសំណេះសំណាល និងសួរសុខទុក្ខភរិយាអតីតប្រធានឃុំធ្លកវៀន ស្ថិតនៅគេហដ្ឋាន ក្នុងឃុំធ្លកវៀន ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៥។



-ចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់អគារទីស្នាក់ការសមាគមអតីតយុទ្ធជនកម្ពុជាខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍កិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ស្ថិតនៅភូមិទួលក្រឡាញ់ សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង នាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៥។

❈ឯកឧត្តម **អ៊ុន ចាន់ណា** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញ៖

-នាំយកទៀនចំណាំព្រះវស្សា សម្ភារៈបរិក្ខារ ទេយ្យទាន និងបច្ច័យប្រគេនព្រះសង្ឃ ដែលគង់ចាំព្រះវស្សាចំនួន៣វត្ត (វត្តដុងឧត្តម វត្តភ្នំមាស និងវត្តព្រៃផ្តៅ) ស្ថិតនៅក្នុងឃុំព្រៃផ្តៅ ព្រមទាំងជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយប្រជាពលរដ្ឋតាមខ្នងផ្ទះ នៅឃុំព្រៃផ្តៅ ស្រុកព្រៃកប្បាស



ខេត្តតាកែវ នាព្រឹកថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៥។



-នាំយកទៀនចំណាំព្រះវស្សា សម្ភារៈបរិក្ខារ ទេយ្យទាន និងបច្ច័យប្រគេនព្រះសង្ឃ ដែលគង់ចាំព្រះវស្សា ស្ថិតនៅវត្តត្រៃយ៍លក្ខណៈញាណ នៅសង្កាត់រការ ក្រុងដូនកែវ ខេត្តតាកែវ នាព្រឹកថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៥។

❈ឯកឧត្តម **សេខ ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាល សួរសុខទុក្ខនិងពិភាក្សាការងារ ជាមួយក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងប្រជាពលរដ្ឋ នៅភូមិតាកុត ឃុំនរា ស្រុកសង្កែ ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥។

-ជួបសំណេះសំណាល សួរសុខទុក្ខនិងពិភាក្សាការងារ ជាមួយក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងប្រជាពលរដ្ឋ នៅភូមិក្របៅ ឃុំគូលែនត្បូង ស្រុកគូលែន ខេត្តព្រះវិហារ នារសៀលថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៥។

❈នាថ្ងៃពុធ ទី២ ខែកក្កដា ឆ្នាំ២០២៥ លោកជំទាវ **ឯម ផល្លាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញនាំយកទេយ្យទាន និងបច្ច័យមួយចំនួនប្រគេនព្រះសង្ឃនៅវត្តព្រះឥន្ទកោសីយ៍ និងវត្តព្រះឥន្ទកោសា ស្ថិតនៅក្រុងសៀមរាប ខេត្តសៀមរាប៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ




❈នាព្រឹកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៥ សមាជិក សមាជិកា ព្រឹទ្ធសភា ចំនួន១០រូប បានអញ្ជើញចូលរួមក្នុងពិធីអបអរ-សាទរ «ទិវាមច្ឆជាតិ ១កក្កដា ២០២៥» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅបឹងទន្លេបាទី ភូមិថ្នល់ទក្សិណ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ។



❈នាថ្ងៃទី១៤-១៥ ខែកក្កដា ឆ្នាំ២០២៥ សមាជិក សមាជិកាព្រឹទ្ធសភា បានយាង/អញ្ជើញចូលរួមក្នុងកិច្ចប្រជុំ the 16th AIPA Caucus Meeting «សន្តិភាពតាមរយៈការសន្ទនា មាគ៌ាឆ្ពោះទៅមុខរបស់សភា» ជាមួយគណៈប្រតិភូសភាសមាជិកអាយប៉ា នៅវិមានរដ្ឋសភា។

❈នាថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៥ សមាជិក សមាជិកា ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីជប់លៀងពិសាអាហារពេលល្ងាចជាមួយគណៈប្រតិភូសភាសមាជិកអាយប៉ា ក្រោមអធិបតីភាពឯកឧត្តម **ខង សួត** អនុប្រធានទី២រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា។

❈នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៥ សមាជិក សមាជិកា ព្រឹទ្ធសភា បានអញ្ជើញ ចូលរួមក្នុងពិធីលៀងសាយភោជន៍ ជូនគណៈប្រតិភូបរទេសទាំងអស់ដែលបានអញ្ជើញចូលរួម កិច្ចប្រជុំក្រុមអ្នកនយោបាយអន្តរសភាអាស៊ានលើកទី១៦ ដែលសភាកម្ពុជាធ្វើជាម្ចាស់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ Sofitel Phnom Penh Phokeethra។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមកិច្ចប្រជុំក្រុមការងារផ្នែកឯកជន វេទិការាជរដ្ឋាភិបាលផ្នែកឯកជន ដើម្បីពិគ្រោះពិភាក្សាយោបល់បន្ទាន់រកគ្រប់វិធីជួយសម្រួលដល់ការលំបាករបស់កសិករ ពាណិជ្ជករ អាជីវករ ទេសចរណ៍ និងការដឹកជញ្ជូន នៅសភាពាណិជ្ជកម្មកម្ពុជា នាព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥។

-ជាគណៈអធិបតីចូលរួម និងផ្តល់បទបាឋកថាលើប្រធានបទ «ការផ្លាស់ប្តូរពីការធ្វើកសិកម្មបែបប្រពៃណី ទៅជាកសិកម្មកែច្នៃតាមបែបទំនើប» នៅក្នុងវេទិកាធុរកិច្ច និងនវានុវត្តន៍ នៅសណ្ឋាគាររ៉េស៊ីដង់ សុខាភ្នំពេញ នារសៀលថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៥។



❈នារសៀលថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ចែម វីឌ្យ៉ា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា ឯកឧត្តម **ខ៉ែត ចដ្ឋាវី** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា និងលោកជំទាវ **មុំ សណ្តាប់** សមាជិកា គណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាល និងពិសាអាហារសាមគ្គីមហាគ្រួសារសហគ្រាសធុនតូច មធ្យមនិងសិប្បកម្មកម្ពុជា ក្រោមអធិបតី-

ភាពដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត ពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ។

❈នាព្រឹកថ្ងៃទី៨ខែកក្កដា ឆ្នាំ២០២៥ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **ខ៉ាន់ ចំរើន** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា ឯកឧត្តម **សាយ ឫរិន** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **ញ៉ូវ សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សា ផ្ទះស្នាក់នៅគ្រូ ទីចាត់ការនិងសមិទ្ធផលនានា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងវិទ្យាល័យឧដុង្គ ភូមិក្រាំងពន្លៃ សង្កាត់វាំងចាស់ ក្រុងឧដុង្គម៉ែជ័យ ខេត្តកំពង់ស្ពឺ។

❈ឯកឧត្តមបណ្ឌិត **ចែម វីឌ្យ៉ា** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីជប់លៀងបុណ្យជាតិបារាំង នៅនិវេសនដ្ឋាន នាល្ងាចថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៥។

-ចូលរួមកម្មវិធីបុណ្យទក្ខិណានុប្បទានគម្រប់៧ថ្ងៃ និង ១០០ថ្ងៃ ឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ហូ ពតស៊ុន** ម្តាយមីងរបស់ឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស នៅវត្តប្រាសាទវជ្ជី វត្តត្បូង ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៥។




❈នារសៀលថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៥ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញថ្លែងបទអន្តរាគមន៍ ក្រោមប្រធានបទស្តីពី «ការដោះស្រាយបញ្ហាប្រឈម និងហានិភ័យនាពេលបច្ចុប្បន្នតាមរយៈកិច្ចសហប្រតិបត្តិការសភា» ក្នុងកិច្ចសន្ទនាសភា (Parliamentary Dialogue) នៃកិច្ចប្រជុំ AIPA Caucus លើកទី១៦ នៅវិមានរដ្ឋសភា ។

❈ឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖



-ជាអធិបតីក្នុងពិធីទទួលស្គរអបអរសាទរការដាក់បញ្ចូល «បូជនីយដ្ឋានចងចាំនៃកម្ពុជា៖ ពីទីតាំងឧក្រិដ្ឋកម្មមកជាមណ្ឌលផ្សះផ្សានិងសន្តិភាព» ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នៅមុខសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា នាព្រឹកថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៥។



-ចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការមជ្ឈមណ្ឌលផ្កាឈូក អង្គភាពការពារកុមារ នៃអង្គការមូលនិធិកុមារកម្ពុជាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិបត្តាដី១ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៥។

❈នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **ឃួន ឃុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **សុត ខា** អតីតអនុប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ នៅសង្កាត់បឹងត្របែក ខណ្ឌចំការមន

រាជធានីភ្នំពេញ។

❈នាថ្ងៃសុក្រ ទី២៥ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា រួមជាមួយលោក Kim Jung Nam និងគណៈប្រតិភូ បានអញ្ជើញចូលទស្សនានៅស្រះស្រង់ ប្រាសាទបន្ទាយស្រី និងប្រាសាទនាគព័ន្ធ ស្ថិតនៅក្នុងខេត្តសៀមរាប។

❈ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមជាមួយលោក Kim Jung Nam និងគណៈប្រតិភូ បាននាំយកអំណោយមនុស្សធម៌ ប្រគល់ជូនមណ្ឌលកុមារកំព្រាក្នុងក្តីស្រមៃថ្មី ស្ថិតនៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥។



-ជូនដំណើរគណៈប្រតិភូមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ធ្វើមាតុភូមិនិវត្តន៍ទៅកាន់ប្រទេសកូរ៉េវិញ បន្ទាប់ពីបានបំពេញទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាយប់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៥។

❈នាយប់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ស៊ាក ឡេង** អនុប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញពិសាអាហារសាមគ្គីជាមួយលោក Kim Jung Nam ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ និងគណៈប្រតិភូ ស្ថិតនៅរាជធានីភ្នំពេញ។

❈នាព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា រួមជាមួយលោក Kim Jung Nam និងគណៈប្រតិភូ បានអញ្ជើញនាំយកនូវអនុស្សរណៈស្តីពី ការផ្តល់ជំនួយមនុស្សធម៌ ប្រគល់ជូនដល់រដ្ឋបាលខេត្តតាកែវ ដឹកនាំដោយឯកឧត្តម **អ៊ី សំណាង** អភិបាលខេត្តតាកែវ នៅសាលាខេត្តតាកែវ និងរដ្ឋបាលខេត្តកំពត ដឹកនាំដោយឯកឧត្តម **ម៉ៅ ធនិន** អភិបាលខេត្តកំពត នៅសាលាខេត្តកំពត ព្រមទាំងទស្សនកិច្ចនៅចំការទុរេន មង្ឃុត និងសារម៉ាវ នៅខេត្តកំពត។

❈នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **ឈួន ឆាម** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុន ខណ្ណា** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារថ្មី និងសម្ពោធឆ្លងសមិទ្ធផលនានានៅវត្តពោធិ៍ព្រឹក្សាខារាម (វត្តតូប) ក្រោមអធិបតីភាពលោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** អគ្គស្នងការសមាគមកាយឫទ្ធិនារីកម្ពុជា នៅឃុំត្រពាំងព្រីង-ខាងជើង ស្រុកទឹកឈូ ខេត្តកំពត។





❈នាថ្ងៃសុក្រ ទី១៨ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីអបអរសាទរការដាក់បញ្ចូល «បូជនីយដ្ឋានចងចាំនៃកម្ពុជា៖ ពីទីតាំងឧក្រិដ្ឋកម្មមកជាមណ្ឌលផ្សះផ្សា

និងសន្តិភាព» ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅពហុកីឡដ្ឋានជាតិអូឡាំពិក ខណ្ឌ៧មករា រាជធានីភ្នំពេញ។

❈នាព្រឹកថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **គង់ មុនីកា** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **សេង ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីប្រារព្ធទិវាឯករាជ្យជាតិខួបលើកទី២៤៩នៃសហរដ្ឋអាម៉េរិក នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។

❈នាថ្ងៃព្រហស្បតិ៍ ទី១៧ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **គង់ មុនីកា** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តមឯកអគ្គរាជទូតប្រទេសអង់គ្លេស ប្រចាំព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅស្ថានទូតអង់គ្លេស ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។

❈លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមកិច្ចប្រជុំគណៈកម្មការរៀបចំមហាសន្និបាតវិសាមញ្ញសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងការអភិវឌ្ឍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវិមាន៧មករា នាថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៥។

-អមដំណើរសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា អញ្ជើញជួបសំណេះសំណាល



សួរសុខទុក្ខ និងចែកអំណោយជូនប្រជាពលរដ្ឋងាយរងគ្រោះបំផុតចំនួន៦២១គ្រួសារ (មកពីស្រុកស្អាង១០០គ្រួសារ ស្រុកកោះធំ ៤២១គ្រួសារ និងក្រុងសំពៅពូន ១០០គ្រួសារ) នៅកីឡដ្ឋាន ស្រុកកោះធំ ខេត្តកណ្តាល នាព្រឹកថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៥។

-អមដំណើរសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា អញ្ជើញអុជទៀនចំណាំ



ព្រះវស្សា ថ្ងៃទី១នៃថ្ងៃចូលព្រះវស្សា និងប្រគេនទេយ្យវត្ថុដល់វត្តមុនីសុវណ្ណ (ហៅវត្តចំពុះក្អែក) ស្ថិតក្នុងខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នាថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥។



❈នាថ្ងៃសៅរ៍ ទី២៦ ខែមិថុនា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ឹង លាងហ៊្វ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **សុក សុខា** អតីតអនុប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ ឪពុកក្មេករបស់សម្តេចមហាមន្ត្រី **គុយ សុផល** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង នៅសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។




❈នាថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៥ សម្តេចរាជបុត្រីព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាងចូលរួមរំលែកមរណៈទុក្ខជាមួយក្រុមគ្រួសារ ឯកឧត្តមសាស្ត្រាចារ្យ **គង់ សន្យា** អគ្គនាយកមន្ទីរពេទ្យកាលម៉ែត ដែលលោកជំទាវ **ហួ បូរ៉ាលីន** ត្រូវជាភរិយា បានទទួលមរណៈភាពក្នុងជន្មាយុ៥៨ឆ្នាំ ដោយរោគាពាធ ស្ថិតនៅសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស



❈នាថ្ងៃទី៧ និងថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តមបណ្ឌិត **ចែម វីឌ្យា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមមហាសន្និបាតប្រចាំឆ្នាំនៃបណ្ដាញហ្វ្រង់កូហ្វូនសីលធម៌ និងក្រមសីលធម៌សមាជិកសភា នៅរដ្ឋសភាបារាំង។

❈ឯកឧត្តមបណ្ឌិត **ចែម វីឌ្យា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមក្នុងកិច្ចប្រជុំបណ្ដាញសមាជិកសភាយុវជន នៅរដ្ឋសភាបារាំង នាព្រឹកថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥។





-ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការកិច្ចការសេដ្ឋកិច្ច សង្គម និងបរិស្ថាន នៅព្រឹទ្ធសភាបារាំង នាថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៥។



❈នាថ្ងៃទី៩ ដល់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំប្រចាំឆ្នាំលើកទី៥០ នៃសភាប្រើភាសាបារាំង (APF) និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងប៉ារីស សាធារណរដ្ឋបារាំង៕

# ការទទួលពាក្យបណ្ដឹង

❈ក្នុងខែកក្កដា ឆ្នាំ២០២៥ គណៈកម្មការទី១ព្រឹទ្ធសភា បានទទួលពាក្យបណ្ដឹងចំនួន៨បណ្ដឹង បញ្ជូនពាក្យបណ្ដឹងចេញទៅក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធចំនួន៤បណ្ដឹង ធ្វើលិខិតរំលឹកជំរុញការដោះស្រាយចំនួន៥បណ្ដឹង កំពុងពិនិត្យសិក្សាចំនួន៦បណ្ដឹង បានទទួលលិខិតថ្លែងអំណរគុណពីម្ចាស់បណ្ដឹងគោរពជូន**សម្ដេចតេជោប្រធានព្រឹទ្ធសភា** តាមរយៈគណៈកម្មការចំនួន១បណ្ដឹង ធ្វើកំណត់បង្ហាញគោរពរាយការណ៍ជូនសម្ដេចតេជោប្រធានព្រឹទ្ធសភា អំពីការឆ្លើយតបលទ្ធផលដោះស្រាយបណ្ដឹងរបស់ក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធចំនួន១បណ្ដឹង ផ្ដល់ព័ត៌មានទៅម្ចាស់បណ្ដឹងចំនួន៩បណ្ដឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការចំនួន៥បណ្ដឹង៕

# ឯកឧត្តម ឡាយ សំកុល ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារ ប្រចាំខែមិថុនា និងកំណត់ទិសដៅការងារខែកក្កដា ឆ្នាំ២០២៥




*ឯកឧត្តម ឡេាក ឆាយ* *ឯកឧត្តម ឡាយ សំកុល* *ឯកឧត្តម អោក ប៉ូ៉*

នារសៀលថ្ងៃចន្ទ ទី១៤ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែមិថុនា និងកំណត់ទិសដៅការងារខែកក្កដា ឆ្នាំ២០២៥ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីតំណាងខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានឋានៈចាប់ពីប្រធាននាយកដ្ឋានឡើង។

ក្នុងឱកាសនោះ **ឯកឧត្តមអគ្គលេខាធិការ** បានជម្រាបជូនអង្គប្រជុំដោយសង្ខេបអំពីព្រឹត្តិការណ៍ជាតិធំៗ ជាពិសេសបញ្ហាជម្លោះព្រំដែនកម្ពុជា-ថៃ ដែលផ្តើមចេញពីការចូលមកបាញ់សម្លាប់ទាហានកម្ពុជា កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥ និងការសម្រេចបិទព្រំដែនជាឯកតោភាគីរបស់ទាហានថៃ។ **សម្តេចតេជោ** និងរាជរដ្ឋាភិបាល បាននិងកំពុងខិតខំប្រឹងប្រែងដោះស្រាយបញ្ហាព្រំដែន ដោយប្រើប្រាស់យន្តការនានា ដើម្បីដោះស្រាយបញ្ហាដោយសន្តិវិធី។ ទន្ទឹមគ្នានោះ **ឯកឧត្តមអគ្គលេខាធិការ** ក៏បានជម្រាបអំពីការងារដ៏មមាញឹករបស់**សម្តេចតេជោប្រធានព្រឹទ្ធសភា** ដែលបានឆ្លៀតពេលអញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខកងកម្លាំងការពារព្រំដែនក្នុងខេត្តឧត្តរមានជ័យ និងជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ ក្នុងខេត្តព្រះវិហារ។

**ឯកឧត្តមអគ្គលេខាធិការ** បានលើកឡើងអំពីមូលហេតុនៃការធ្វើវិសោធនកម្មមាត្រា៣៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលព្រឹទ្ធសភាបានបើកសម័យប្រជុំជាវិសាមញ្ញ កាលពីព្រឹកថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៥ ដោយសារតែមានក្រុមជ្រុលនិយមមួយក្តាប់តូចគប់គិតជាមួយបរទេស ព្យាយាមបិទបាំងអំពើឈ្លានពានរបស់បរទេស បកស្រាយព្រឹត្តិការណ៍ខុសស្រឡះពីការពិត និងធ្វើសកម្មភាពប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍ជាតិនិងប្រជាពលរដ្ឋ។

ពាក់ព័ន្ធនឹងការអភិវឌ្ឍស្ថាប័ន **ឯកឧត្តមអគ្គលេខាធិការ** បានមានប្រសាសន៍កោតសរសើរគណៈកម្មការបេឡាសោធននិវត្តន៍ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលបានរៀបចំរបាយការណ៍វិភាគអំពី ដំណើរការគ្រប់គ្រងបេឡាសោធននិវត្តន៍ តាមឆ្នាំនីមួយៗ ក្នុងរយៈពេល២០ឆ្នាំទៅមុខទៀត ដែលមានលក្ខណៈច្បាស់លាស់និងសុក្រឹត។ ឯកឧត្តមក៏បានណែនាំដល់គណៈកម្មការបេឡាសោធននិវត្តន៍ រៀបចំរបាយការណ៍ស្តីពី ដំណើរការគ្រប់គ្រងបេឡាសោធននិវត្តន៍ជូន**សម្តេចតេជោប្រធានព្រឹទ្ធសភា** ដើម្បីពិនិត្យសម្រេច។

ព្រមជាមួយគ្នានោះ **ឯកឧត្តមអគ្គលេខាធិការ**បាន ជម្រាបជូនអង្គប្រជុំអំពី ការបង្កើតក្រុមការងារស្រាវជ្រាវ អំពីស្ថាបត្យកម្មរបស់ព្រឹទ្ធសភា ដើម្បីប្រមូលឯកសារទាំងអស់ នោះ រៀបចំចងក្រងធ្វើជាសៀវភៅប្រវត្តិអគារព្រឹទ្ធសភា សម្រាប់អបអរសាទរក្នុងពិធីសម្ពោធអគារព្រឹទ្ធសភាថ្មី នាពេលខាងមុខ។ បន្ថែមពីនេះ ឯកឧត្តមបានស្នើដល់អង្គភាព ពាក់ព័ន្ធពិនិត្យជ្រើសរើសមន្ត្រីដែលមានសមត្ថភាពចូលរួមក្នុង ក្រុមTask Force ដើម្បីជួយពិនិត្យលើការងារបច្ចេកវិទ្យា ព័ត៌មាន ការស្រាវជ្រាវ ការវាយតម្លៃផែនការយុទ្ធសាស្ត្រ...។ ចំពោះអាហារូបករណ៍ដែលផ្តល់ឱ្យពីសាកលវិទ្យាល័យនានា ដល់មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា **ឯកឧត្តម អគ្គលេខាធិការ**បានណែនាំឱ្យមានការជួបពិភាក្សាជាមួយ សាកលវិទ្យាល័យ ដើម្បីទទួលបានព័ត៌មានលម្អិត មុននឹង ផ្សព្វផ្សាយសេចក្តីជូនដំណឹងជូនមន្ត្រីរាជការ។

មុននឹងបញ្ចប់ **ឯកឧត្តមអគ្គលេខាធិការ**បានណែនាំ ដល់អង្គភាពទាំងអស់ ត្រូវមានការប្រុងប្រយ័ត្នក្នុងការទុកដាក់ ឯកសារនិងសម្ភារៈផ្សេងៗ ពីព្រោះថា ពេលនេះជារដូវវស្សា ដែលអាចមានភ្លៀងច្រើន ពេលខ្លះអាចធ្វើឱ្យមានការជន់លិច ដោយសារទឹកភ្លៀង នៅកន្លែងខ្លះក្នុងបរិវេណព្រឹទ្ធសភា។ ជាមួយគ្នានោះ ឯកឧត្តមក៏បានអំពាវនាវដល់មន្ត្រីរាជការ ត្រូវមានការប្រុងប្រយ័ត្នក្នុងការបើកបរម៉ូតូក្នុងពេលមេឃភ្លៀង ជៀសវាងគ្រោះថ្នាក់កើតឡើងជាយថាហេតុ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន









*ទិដ្ឋភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមិថុនា និងកំណត់ទិសដៅការងារខែកក្កដា ឆ្នាំ២០២៥*

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

❈នាព្រឹកថ្ងៃសៅរ៍ ទី៥ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងលោកជំទាវ បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព លោកជំទាវ **ហូ បូរ៉ាលីន** ភរិយារបស់ឯកឧត្តមសាស្ត្រាចារ្យ **គង់ សន្យា** អគ្គនាយកមន្ទីរពេទ្យកាល់ម៉ែត្រ នៅគេហដ្ឋាននៃសព ស្ថិតក្នុងសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។




❈នាព្រឹកថ្ងៃចន្ទ ទី២១ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **ខេង សិទ្ធិគុណា** អគ្គលេខាធិការរងព្រឹទ្ធសភា តំណាងឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអមដំណើរឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា អញ្ជើញចុះត្រួតពិនិត្យមើលវឌ្ឍនភាពនៃដំណើរការសាងសង់អគារថ្មី នៃព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៥ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមិថុនា ឆ្នាំ២០២៥ និងទិសដៅការងារបន្តរបស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអគ្គនាយកដ្ឋានស្រាវជ្រាវ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំចំណុះអគ្គនាយកដ្ឋានទាំងពីរ ចាប់ពីប្រធាននាយកដ្ឋានឡើង នៅសាលប្រជុំពិសេសក្រោម វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

❈នារសៀលថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៥ នៅសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តតាកែវ លោក **អ៊ឹុខ ចិន្តា** អគ្គនាយករង នៃអគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី បានដឹកនាំមន្ត្រីការិយាល័យក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ អញ្ជើញជួបពិភាក្សាការងារជាមួយលោក **ភាន់ វ៉ា** ប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ខេត្តតាកែវ នៅទីស្នាក់ការសមាគម។



❈ចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានសហការជាមួយនឹងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ រៀបចំចុះធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនសមាជិក សមាជិកាព្រឹទ្ធសភា មន្ត្រី និងបុគ្គលិកនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងក្រុមគ្រួសារ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



❈នាថ្ងៃសុក្រ ទី២៥ ខែកក្កដា ឆ្នាំ២០២៥ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញបរិច្ចាគឈាមមនុស្សធម៌ នៅអគារពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ ដើម្បីសង្គ្រោះជីវិតអ្នកទទួលគ្រោះថ្នាក់ ឬអ្នកជំងឺដែលត្រូវការឈាមជាបន្ទាន់ និងត្រៀមបម្រុងសម្រាប់វីរកងទ័ពជួរមុខ ឬប្រជាពលរដ្ឋ ក្នុងករណីដែលទទួលរងរបួស ឬគ្រោះថ្នាក់ដោយសារសង្គ្រាមឈ្លានពានទឹកដីកម្ពុជា៕



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ
ទូរសព្ទ: (855) 23 211 441, 211 442, 211 443 ទូរសារ: (855) 23 211 446
E-mail: secretariat@senate.gov.kh
www.senate.gov.kh www.elibrary.senate.gov.kh
E-Library
senate of cambodia